ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
MINISTRY OF INDUSTRY, SCIENCE,
TECHNOLOGY & INNOVATION

របាយការណ៍
លទ្ធផលការងារឆ្នាំ២០២៤
និងទិសដៅការងារឆ្នាំ២០២៥

របាយការណ៍
លទ្ធផលការងារឆ្នាំ២០២៤
និងទិសដៅការងារឆ្នាំ២០២៥

មាតិកា

I- សេចក្តីផ្តើម ១

II- ក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងគតិយុត្តតាមវិស័យ

១. ច្បាប់ ៥

២. គោលនយោបាយ ៦

៣. អនុក្រឹត្យ ៦

៤. ប្រកាស ៧

៥. ផែនការយុទ្ធសាស្ត្រ ១០

៦. លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ១០

III- សមិទ្ធផលសម្រេចបានឆ្នាំ២០២៤ .... ១៥

១. វិស័យឧស្សាហកម្ម ១៥

១.១. ការងារឧស្សាហកម្ម ១៥

១.២. ការងារបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ២១

១.៣. ការងារកម្មសិទ្ធិឧស្សាហកម្ម ២៤

១.៤. ការងារបង្កើនផលិតភាព ២៨

១.៥. ការងារគម្រោង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូ ៣១

២. វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ៣២

២.១. ការងារចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ៣២

២.២. ការងារកសាងលិខិតបទដ្ឋានគតិយុត្ត និងផ្សព្វផ្សាយ ៤០

២.៣. ការងារបណ្តុះបណ្តាលក្នុង/ក្រៅប្រទេស ៤១

២.៤. ការងារសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ៤១

២.៥. ការងារត្រួតពិនិត្យអនុលោមភាព និងពិគ្រោះយោបល់ ៤២

២.៦. ការងារស្រែអំបិល ៤៤

៣. ការងារស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ៤៦
៣.១. ការងារព័ត៌មាន ៤៦
៣.២. ការងារអភិវឌ្ឍន៍ស្តង់ដា ៤៧
៣.៣. ការងារវិញ្ញាបនបត្រកម្ម ៤៩
៣.៤. ការងារបញ្ញត្តកម្ម ៥០
៣.៥. ការងារពង្រឹងសមត្ថភាព ៥១
៣.៦. ការងារកិច្ចសហប្រតិបត្តិការ ៥១
៤. ការងារមាត្រាសាស្ត្រ ៥៤
៤.១. ការផ្តល់សេវាសាធារណៈ ៥៤
៤.២. ការងារផ្សព្វផ្សាយ និងកសាងលិខិតបទដ្ឋានគតិយុត្ត ៦០
៤.៣. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា ៦០
៤.៤. ការងារសហប្រតិបត្តិការ ៦០
៥. ការងារវាយតម្លៃទទួលស្គាល់នៃកម្ពុជា ៦១
៥.១. ការងារពង្រឹងស្ថាប័ន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៦១
៥.២. ការអភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ប្រកបដោយបរិយាបន្ន ៦២
៥.៣. ការងារវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោម ៦៣
៥.៤. ការងារបណ្តុះបណ្តាល ៦៤
៥.៥. ការងារផ្សព្វផ្សាយ ៦៥
៦. ការងារមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៦៥
៧. វិស័យទឹកស្អាត ៦៧
៧.១. ការងារទិន្នន័យទឹកស្អាតទូទាំងប្រទេស ៦៨
៧.២. ការងារកសាងផែនការ ៧៣
៧.៣. ការងារបញ្ញត្តកម្មទឹកស្អាត ៧៦
៧.៤. ការងារគម្រោង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ៧៧
៧.៥. ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ៧៧
៧.៦. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា ៧៨

៨. ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៧៨

៨.១. ការងារគោលនយោបាយ ៧៩

៨.២. ការងារផ្ទេរបច្ចេកវិទ្យា ៧៩

៨.៣. ការងារគ្រប់គ្រងព័ត៌មាន ៧៩

៨.៤. ការងារសហប្រតិបត្តិការ ៨០

៨.៥. ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ... ៨២

៨.៦. ការងារគណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែក វ.ប.ន ៨២

៨.៧. ការងារក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន.) ៨៣

៩. ការងារវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៨៣

៩.១. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ ៨៦

៩.២. ការងារបណ្តុះបណ្តាល ពិគ្រោះយោបល់ និងសិក្ខាសាលា ៨៦

៩.៣. កិច្ចសហប្រតិបត្តិការ ៨៧

៩.៤. ការងារជំរុញ និងផ្សព្វផ្សាយ ៨៨

១០. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ...................................... ៨៨

១០.១. ក្របខណ្ឌគណៈកម្មាធិការសម្របសម្រួល ៨៩

១០.២. ក្របខណ្ឌក្រសួងឧ.វ.ប.ន. ក្នុងនាមជាសេនាធិការ........................ ៩០

១១. ការងារកិច្ចការទូទៅ.. ៩១

១១.១. ការងាររដ្ឋបាល ៩១

១១.២. ការងារបុគ្គលិក.. ៩១

១១.៣. ការងារគណនេយ្យ និងហិរញ្ញវត្ថុ.. ៩៣

១១.៤. ការងារនីតិកម្ម ៩៤

១១.៥. ការងារផែនការ ស្ថិតិ សហប្រតិបត្តិការ និងអាស៊ាន........................ ៩៦

១២. ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ៩៧

១៣. ការងារយេនឌ័រ ៩៨

១៤. ការងារមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត.. ១០១

១៤.១. ការងារឧស្សាហកម្ម និងសិប្បកម្ម ១០១
១៤.២. ការងារទឹកស្អាត ១០២
១៤.៣. ការងារស្តង់ដា និងមាត្រាសាស្ត្រ ១០២
១៤.៤. ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១០៣
១៥. សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត ១០៣
IV- **បញ្ហាប្រឈម ១០៩**
V- **ទិសដៅការងារអនុវត្តឆ្នាំ២០២៥ .... ១១៣**
១. វិស័យឧស្សាហកម្ម ១១៣
២. វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ១១៥
៣. ការងារស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងការវាយតម្លៃភាពអនុលោម ១១៧
៤. ការងារមាត្រាសាស្ត្រជាតិ ១១៨
៥. ការងារវាយតម្លៃទទួលស្គាល់នៃកម្ពុជា ១២០
៦. ការងារមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១២១
៧. វិស័យទឹកស្អាត ១២១
៨. ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១២២
៩. ការងារវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១២៣
១០. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ១២៤
១១. ការងារកិច្ចការទូទៅ ១២៥
១២. ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ១២៦
១៣. ការងារយេនឌ័រ ១២៧
១៤. ការងារមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី-ខេត្ត១២៧
១៥. សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត. ១២៨
VI- **សេចក្តីសន្និដ្ឋាន ១២៩**

អក្សរកាត់

ក.ជ.វ.ប.ន	ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	National Council of Science, Technology and Innovation
គ.ស.អ.ស.ក	គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ	Coordinating Committee for the Development of Informal Economy
ប.ស.ស	បេឡាជាតិសន្តិសុខសង្គម	National Social Security Fund
ផ.ស.ស	ផលិតផលក្នុងស្រុកសរុប	Gross Domestic Product
ម.ជ.វ.ប.ន	មន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍	Science, Technology and Innovation National Laboratory
ឧ.វ.ប.ន	ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	Industry, Science, Technology and Innovation
ACCMSME	គណៈកម្មាធិការសម្របសម្រួលអាស៊ានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម	ASEAN Coordinating Committee on Micro, Small and Medium Enterprises
ACCSQ/WG2	គណៈកម្មាធិការពិគ្រោះយោបល់អាស៊ាន ផ្នែកស្តង់ដា និងគុណភាព (ក្រុមការងារទី២)	ASEAN Consultative Committee for Standards and Quality (Working Group 2)
ACFS	ការិយាល័យជាតិនៃទំនិញកសិកម្ម និងស្តង់ដាចំណីអាហារ (ថៃ)	National Bureau of Agricultural Commodity and Food Standards (Thailand)
ADB	ធនាគារអភិវឌ្ឍន៍អាស៊ី	Asian Development Bank
APAC	ស្ថាប័នវាយតម្លៃទទួលស្គាល់តំបន់អាស៊ីប៉ាស៊ីហ្វិក	Asia Pacific Accreditation Cooperation

APO	អង្គការផលិតភាពអាស៊ី	Asian Productivity Organization
BEEP	កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត	Basic Education Equivalency Programme
BLA-DSS	ការិយាល័យវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍, នាយកដ្ឋានសេវាកម្មវិទ្យាសាស្ត្រ (ថៃ)	Bureau of Laboratory Accreditation, Department of Science Service (Thailand)
BLQS-DM-Sc	ការិយាល័យស្តង់ដាគុណភាពមន្ទីរពិសោធន៍-នាយកដ្ឋានវិទ្យាសាស្ត្រវេជ្ជសាស្ត្រ	The Bureau of Laboratory Quality Standards– Department of Medical Sciences
BoA	អង្គភាពវាយតម្លៃទទួលស្គាល់(វៀតណាម)	Bureau of Accreditation (Vietnam)
CABs	អង្គភាពវាយតម្លៃភាពអនុលោម	Conformity Assessment Bodies
CamDX	ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា	Cambodia Data Exchange
CAPRED	កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយភាពធន់	Cambodia Australia Partnership for Resilient Economic Development
CASCO	គណៈកម្មការវាយតម្លៃភាពអនុលោម	Committee on Conformity Assessment
CDI-IDC	កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ	Centrist Democrat International
CLV-DTA	កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍	Cambodia Laos Vietnam Development Triangle Area

CNIPA	អង្គការកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋប្រជាមានិតចិន	China National Intellectual Property Administration
CNRIFFI	វិទ្យាស្ថានស្រាវជ្រាវជាតិចិន ផ្នែកចំណីអាហារ និងឧស្សាហកម្ម	China National Research Institute of Food and Fermentation Industries
CS	ស្តង់ដាកម្ពុជា	Cambodia Standards
EPO	អង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប	European Patent Office
FDI	វិនិយោគផ្ទាល់ពីបរទេស	Foreign Direct Investment
FMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	Financial Management Information System
FTC	មជ្ឈមណ្ឌលកែច្នៃអាហារ	Food Processing Task Center
GGGI	វិទ្យាស្ថានកំណើនបៃតងសកល	Global Green Growth Institute
GHP	ការអនុវត្តអនាម័យល្អ	Good Hygiene Practices
GHS	ប្រព័ន្ធស្របគ្នាជាសកល	Globally Harmonized System
GIS	ទីតាំងរោងចក្រតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ	Geographic Information System
GIZ	ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ	Deutsche Gesellschaft fur International Zusammenarbeit (GIZ)GmbH
GMP	ការអនុវត្តផលិតកម្មល្អ	Good Manufacturing Practice
HACCP	ការវិភាគភាពគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យចាំបាច់	Hazard Analysis and Critical Control Point
IAS	ស្ថាប័នផ្តល់សេវាវាយតម្លៃទទួលស្គាល់អន្តរជាតិ (សហរដ្ឋអាមេរិក)	International Accreditation Service (United State)

ICAPP12th	មហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២	12th International Conference of Asian Political Parties
IHAF	ស្ថាប័នវាយតម្លៃទទួលស្គាល់អន្តរជាតិផ្នែកផលិតផលហាឡាល	International Halal Accreditation Forum
ILAC	ស្ថាប័នវាយតម្លៃទទួលស្គាល់អន្តរជាតិផ្នែកមន្ទីរពិសោធន៍	International Laboratory Accreditation Cooperation
ILO	អង្គការពលកម្មអន្តរជាតិ	International Labour Organization
IPAS-4	ប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិឧស្សាហកម្មជំនាន់ទី៤	Industrial Property Automation System 4
IPOS	អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី	Intellectual Property Office of Singapore
IPTP11th	សម័យប្រជុំពេញអង្គនៃសភាអន្តរជាតិសម្រាប់ការអត់ឱន និងសន្តិភាពលើកទី១១	11th International Parliament for Tolerance and Peace
ISICRev.4 Code	ការចាត់ថ្នាក់ឧស្សាហកម្មស្តង់ដាអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់,ការពិនិត្យឡើងវិញលើកទី៤	International Standard Industrial Classification of All Economic Activities (ISIC) Revision 4
ISO/IEC	អង្គការអន្តរជាតិផ្នែកស្តង់ដារូបនីយកម្ម/គណៈកម្មាធិការអេឡិចត្រូនិចអន្តរជាតិ	International Organization for Standardization /International Electrotechnical Commission
JAS-ZAN	ប្រព័ន្ធវាយតម្លៃទទួលស្គាល់រួមគ្នានៃប្រទេស អូស្ត្រាលី និងនូវែលសេឡង់	The Joint Accreditation System of Australia and New Zealand
JEMAI	សមាគមគ្រប់គ្រងបរិស្ថានជប៉ុនសម្រាប់ឧស្សាហកម្ម	Japan Environmental Management Association for Industry

JICA	ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន	Japan International Cooperation Agency
KIPO	អង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ	Korean Intellectual Property Office
KPI	សូចនាករគន្លឹះអនុវត្តការងារ	Key Performance Indicators
LEAN	ប្រព័ន្ធផលិតកម្មលីន	LEAN Manufacturing
METI	ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន	Ministry of Economy, Trade and Industry
MLA	កិច្ចសម្រុះសម្រួលទទួលស្គាល់ពហុភាគី	Multilateral Recognition Arrangement
MRA	កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក	Mutual Recognition Arrangement
NATA	សមាគមជាតិនៃអាជ្ញាធរធ្វើតេស្ត(អូស្ត្រាលី)	National Association of Testing Authorities (Australia)
NPCC	មជ្ឈមណ្ឌលផលិតភាពជាតិ	National Productivity Centre of Cambodia
NRMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ	Non-Tax Revenue Management Information System
ONSC	ការិយាល័យក្រុមប្រឹក្សាស្តង់ដាជាតិ	The Office of the National Standardization Council
PTB	វិទ្យាស្ថានមាត្រាសាស្ត្រជាតិនៃប្រទេសអាល្លឺម៉ង់	The Physikalisch-Technische Bundesanstalt
RCEP	ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់	Regional Comprehensive Economic Partnership
RIA	វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត	Regulatory Impact Assessment

SAC	ក្រុមប្រឹក្សាវាយតម្លៃទទួលស្គាល់នៃប្រទេសសិង្ហបុរី	Singapore Accreditation Council
SARMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ	State Asset Register Management Information System
SPS	អនាម័យ និងភូតគាមអនាម័យ	Sanitary and Phytosanitary
STINL	មន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍	Science, Technology and Innovation National Laboratory
TBT	របាំងបច្ចេកទេសពាណិជ្ជកម្ម	Technical Barriers to Trade
UNDESA	នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ	United Nations Department of Economic and Social Affairs
UNECE	គណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប	United Nations Economic Commission for Europe
UN-ESCAP	គណៈកម្មការសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក	United Nations Economic and Social Commission for Asia and the Pacific
UNICEF	មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ	United Nations Children's Fund
UNIDO	អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ	United Nations Industrial Development Organization
UPOV	សហភាពសម្រាប់ការការពារពូជថ្មីនៃរុក្ខជាតិ	Union for the Protection of New Varieties of Plants
WIPO	អង្គការកម្មសិទ្ធិបញ្ញាពិភពលោក	World Intellectual Property Organization



I.

សេចក្តីផ្តើម

I- សេចក្តីផ្តើម

ស្ថិតក្រោមម្លប់សន្តិភាពនៃ **«នយោបាយ ឈ្នះ ឈ្នះ»** ដែលជាចក្ខុវិស័យដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា កម្ពុជាបានប្រមូលផ្តុំកម្លាំងជាតិ ធនធាន និងលទ្ធភាពគ្រប់យ៉ាង ដើម្បីជំរុញការអភិវឌ្ឍលើគ្រប់វិស័យក្នុងល្បឿនដ៏លឿន និងនាំមកនូវការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ ដែលស្ទើរតែពុំនឹកស្មានដល់។ ក្នុងរយៈពេលជាង២៦ឆ្នាំនៃសន្តិភាពពេញលេញ កម្ពុជាបានខិតខំកសាងប្រទេស ដោយសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ក្នុងការស្តារ កសាង និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ធ្វើឱ្យភាពក្រីក្ររបស់ប្រជាជនត្រូវបានកាត់បន្ថយជាបន្តបន្ទាប់មកក្រោម ១0% មុនពេលមានវិបត្តិជំងឺកូវីដ-១៩។ កម្ពុជាមានសមត្ថភាពគ្រប់គ្រងវិបត្តិជាតិបានដោយភាពម្ចាស់ការ ថែមទាំងមានទុនបម្រុងដើម្បីធានាស្ថិរភាពសេដ្ឋកិច្ច និងលំនឹងជីវភាពរបស់ប្រជាជនព្រមទាំងទប់ទល់នឹងវិបត្តិ និងគ្រោះមហន្តរាយផ្សេងៗ។ បច្ចុប្បន្ន កម្ពុជាកំពុងត្រៀមខ្លួនដើម្បីចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៩ និងបានកំណត់បង្គោលចរក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០។

ក្នុងឆ្នាំ ២០២៤ កន្លងទៅនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានសម្រេចសមិទ្ធផលធំៗយ៉ាងច្រើនក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់ខ្លួន។ ជាក់ស្តែង សន្តិភាព ស្ថិរភាព នយោបាយ ខឿនឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីត្រូវបានការពារយ៉ាងគត់មត់, សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមមានភាពល្អប្រសើរ, សេដ្ឋកិច្ចជាតិសម្រេចបានកំណើនក្នុងរង្វង់ ៦%, អត្រាប្តូរប្រាក់មានស្ថិរភាព, អតិផរណាស្ថិតក្នុងកម្រិតទាបដែលអាចគ្រប់គ្រងបាន, ស្ថានភាពការងារ និងជីវភាពប្រជាជនក៏មានស្ថិរភាព។ កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដើម្បីផលប្រយោជន៍សេដ្ឋកិច្ចជាតិ និងពង្រឹងឯករាជ្យ ខាងនយោបាយលើការដឹកជញ្ជូនផ្លូវទឹក។ រាជរដ្ឋាភិបាល បានប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀង ស្តីពីសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ (CLV-DTA) ឯកិច្ចសហប្រតិបត្តិការទូទៅរវាង

ប្រទេសទាំង៣ នៅតែត្រូវបានបន្តពង្រឹង ពង្រីកជាធម្មតា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានផ្តួចផ្តើមបង្កើតមូលនិធិកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវតាមបណ្តោយព្រំដែន ដែលនឹងផ្តល់សារៈប្រយោជន៍ដល់ការអភិវឌ្ឍតំបន់ព្រំដែន និងការការពារបូរណភាពទឹកដី។ នៅចុងឆ្នាំ២០២៤ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះ និងធ្វើជាប្រធានដឹកនាំកិច្ចប្រជុំជាអន្តរជាតិប្រកបដោយជោគជ័យចំនួន ៤ គឺ (១) កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ (CDI-IDC), (២)មហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP 12th), (៣)សម័យប្រជុំពេញអង្គនៃសភាអន្តរជាតិសម្រាប់ការអត់ឱន និងសន្តិភាពលើកទី១១ (IPTP 11th) និង(៤) កិច្ចប្រជុំកំពូលសៀមរាប-អង្គរ ស្តីពីពិភពលោកមួយដែលគ្មានមីន។ កិច្ចប្រជុំទាំងនេះបានលើកស្ទួយថែមទៀត នូវកិត្យានុភាពរបស់កម្ពុជា ហើយប្រទេសជាច្រើនបានទទួលយកនូវមេរៀនពិសោធន៍ដ៏មានតម្លៃបំផុតរបស់កម្ពុជា ក្នុងការស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិ។

ដោយឡែក វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន) ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ជាឧបករណ៍យុទ្ធសាស្ត្រចាំបាច់មួយ ដើម្បីឈានទៅសម្រេចនូវចក្ខុវិស័យនានាដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ **និងជាកំលាំងចលករមួយជំរុញកំណើន ដើម្បីរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា**។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២៤ កន្លងទៅ សេដ្ឋកិច្ចកម្ពុជាបន្តនិន្នាការកើនឡើង ក្នុងរង្វង់ ៦% នៃ ផ.ស.ស. ស្របពេលដែលចំណូលមធ្យមសម្រាប់ពលរដ្ឋម្នាក់ៗបានកើនឡើងដល់ ២.៧១៣ដុល្លារអាមេរិក បើធៀបនឹងប្រមាណ ១.៩១៧ដុល្លារអាមេរិកក្នុងឆ្នាំ២០២៣។ កំណើននេះត្រូវបានគាំទ្រដោយវិស័យសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ក្នុងនោះវិស័យឧស្សាហកម្មបន្តនិន្នាការកើនឡើងក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ២០២៤ ពីប្រមាណ ៥% ក្នុងឆ្នាំ២០២៣។ សម្រាប់ឆ្នាំ២០២៥ នេះ ផ្អែកតាមក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច សេដ្ឋកិច្ចកម្ពុជានឹងបន្តមាននិន្នាការកើនឡើងក្នុងរង្វង់ ៦,៣% នៃ ផ.ស.ស. ហើយចំណូលមធ្យមសម្រាប់ពលរដ្ឋម្នាក់ៗត្រូវបានរំពឹងថានឹងកើនឡើងដល់ ២.៩២៤ដុល្លារអាមេរិក។ វិស័យឧស្សាហកម្មត្រូវបានព្យាករណ៍ថានឹងបន្តនិន្នាការកើនឡើងក្នុងរង្វង់ ៨,៦%ក្នុងឆ្នាំ២០២៥ ដែលគាំទ្រដោយការរក្សាបានតុល្យភាពនៃអនុវិស័យកាត់ដេរ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប។





II

ក្របខណ្ឌ
គោលនយោបាយ
យុទ្ធសាស្ត្រ
និងគតិយុត្តតាមវិស័យ

II- ក្របខណ្ឌគោលនយោបាយយុទ្ធសាស្ត្រ និងគតិយុត្តតាមវិស័យ

បច្ចុប្បន្ន ក្រសួងឧ.វ.ប.ន. មានច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តមួយចំនួន សម្រាប់គាំទ្រដល់ការបំពេញបេសកកម្ម និងអនុវត្តតួនាទីភារកិច្ចការងាររបស់ខ្លួន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដូចខាងក្រោម៖

១. ច្បាប់

» ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម (ព្រះរាជក្រមលេខ នស/រកម/០១៣០/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣)

» ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦)
» ច្បាប់ស្តីពីស្តង់ដាកម្ពុជា (ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដាកម្ពុជា)
» ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ (ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨)
» ច្បាប់ស្តីពីមាត្រាសាស្រ្ត (ព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩)
» ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (ព្រះរាជក្រមលេខ នស/រកម/១០១៤/ ០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤)
» ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម(ព្រះរាជក្រមលេខ នស/រកម/១១១៧/ ០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧)
» ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីស្តង់ដាកម្ពុជា (ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តង់ដាកម្ពុជា)
» ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០២ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣

២. គោលនយោបាយ

» គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
» គោលនយោបាយថ្នាក់ជាតិស្តីអំពីរបៀបវារៈស្រាវជ្រាវជាតិ២០២៥
» គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យយានយន្តអគ្គិសនី២០២៤-២០៣០
» គោលនយោបាយជាតិស្តីពីវិទ្យាសាស្រ្ត និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០
» គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០
» គោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

៣. អនុក្រឹត្យ

» អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចស្តង់ដាកម្ពុជា

- អនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការដំឡើងនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ទៅជាអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជា ចំណុះក្រសួងឧ.វ.ប.ន.
- អនុក្រឹត្យលេខ ៣៣៧ អ.ន.ក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោង និងមន្ទីរពិសោធន៍ផ្លូវការ
- អនុក្រឹត្យលេខ ៣៧០ អ.ន.ក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- អនុក្រឹត្យលេខ ១៥ អនក្រ.បប ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ស្ដីពីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម
- អនុក្រឹត្យលេខ ១៤១ អ.ន.ក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការបង្កើតមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ២៨៩ អ.ន.ក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៤. ប្រកាស

- ប្រកាសឱ្យប្រើសេចក្ដីពន្យល់លម្អិតនៃស្តង់ដាអន្តរជាតិចំណាត់ថ្នាក់ឧស្សាហកម្មផ្នែកកម្មន្តសាល (ISIC Rev.4 Code) (លេខ ១០២៧ ឧវថ.កឧ.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០)
- ប្រកាសលេខ ១៩៨ MIH/2016 ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម
- ប្រកាសលេខ ១៩៩ MIH/2016 ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម
- ប្រកាសលេខ ០៤១ MIH/2017 ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ស្ដីពីការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ និងសិប្បកម្ម
- ប្រកាសលេខ ៣១០ MISTI/២០២២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីនីតិវិធីនៃការចុះបញ្ជី និងបែបបទផ្ដល់ទិន្នន័យ និងរបាយការណ៍ សម្រាប់រោងចក្រដែលមិនស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧ.វ.ប.ន.
- ប្រកាសលេខ ០៣៨ MISTI/២០២៣ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការធ្វើប្រតិភូកម្មអំណាចនៃការចេញសេចក្ដីសម្រេចបង្កើត និងចុះបញ្ជីរោងចក្រជូនដល់រដ្ឋបាលរាជធានី-ខេត្ត
- ប្រកាសលេខ ១៥២ MIH/2017 ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការគ្រប់គ្រង

លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឧបករណ៍ គ្រឿងចក្រគ្រឿងម៉ាស៊ីនដែលមានហានិភ័យ

» ប្រកាសលេខ ២០៦ MIH/2017 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មក្នុងរោងចក្រ និងសិប្បកម្ម

» ប្រកាសលេខ ១៣៦ MISTI/២០២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីវិធានសម្រាប់គ្រប់គ្រង និងដំណើរការផលិតកម្មរោងចក្រ សហគ្រាស និងសិប្បកម្មផលិតទឹកពិសាដប

» ប្រកាសលេខ ០៥៩ MISTI/២០២១ ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

» ប្រកាសលេខ ០៦០ MISTI/២០២១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

» ប្រកាសលេខ ២៣១ ឧវបន កសឧ ប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ អន្តរក្រសួង ស្តីពីការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅកម្ពុជា

» ប្រកាសលេខ ២១៦ MINSTI/២០២០ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រង និងនីតិវិធីការចុះបញ្ជីការពារពូជថ្មីនៃដំណាំ

» ប្រកាស លេខ ១៩៨ MIH/២០១៦ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម

» ប្រកាសលេខ ១៣២ MIH/2016 ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការធ្វើសេវាកម្មវាយតម្លៃទទួលស្គាល់ ដល់អង្គភាពវាយតម្លៃភាពអនុលោមនៅព្រះរាជាណាចក្រកម្ពុជា ដោយអង្គភាពវាយតម្លៃទទួលស្គាល់មកពីក្រៅប្រទេស

» ប្រកាសលេខ ៣៤១ ឧវបន.អវទក.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់នៃកម្ពុជា

» ប្រកាសលេខ១៩០ MISTI/២០២៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់វិញ្ញាបនបត្រវាយតម្លៃភាពអនុលោមតាមស្តង់ដាដែលភ្ជាប់ជាមួយទំនិញនាំចេញ-នាំចូល

» ប្រកាសលេខ ១៥១ MIH/2016 ស្តីពីបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ផលិតផលអគ្គិសនី និងអេឡិចត្រូនិក ចំនួន១១៩

» ប្រកាសលេខ ១៥០ MIH/2016 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសសម្រាប់យានយន្ត ចំនួន ១៩

» ប្រកាសលេខ ១៦៦ MIH/2018 ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រង និងការតម្រូវសុវត្ថិភាព សម្រាប់ផលិតផលម្ហូបអាហារ

» ប្រកាសលេខ ២៥២MISTI/២០២២ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការអនុវត្ត

គោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

» ប្រកាសលេខ ១១២ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីសញ្ញាសម្គាល់ស្តង់ដាឧស្សាហកម្ម

» ប្រកាសលេខ ១១០ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យ ការប្រើប្រាស់ នាំចូល នាំចេញ និងចែកចាយសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

» ប្រកាសលេខ ០៦៣ ឧវបន.វសក.ប្រក ស្តីពីសមាសភាពក្រុមប្រឹក្សាស្តង់ដាជាតិ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤

» ប្រកាសលេខ ០៦៤ ឧវបន.វសក.ប្រក ស្តីពីសមាជិកបម្រុងនៃក្រុមប្រឹក្សាស្តង់ដាជាតិ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤

» ប្រកាសលេខ ១៩១ MISTI/២០២៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ក្នុងរោងចក្រ និងសិប្បកម្ម

» ប្រកាសលេខ ៣៤១ ឧវបន.អវទក.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់នៃកម្ពុជា

» ប្រកាសលេខ ៣៤២ ឧវបន.វសក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីសារធាតុគីមីស្ថិតក្រោមលក្ខខណ្ឌ(Restricted Chemicals) ក្នុងវិស័យឧស្សាហកម្ម

» ប្រកាសលេខ ២០៤ ឧវបន.បល.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍

» ប្រកាសលេខ ០០៦ ឧវបន.ទស.ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

» ប្រកាសលេខ ២០៣ ឧវបន.ទស.ប្រក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងទឹកគ្មានចំណូល

» ប្រកាសលេខ១១៩ ឧ.វ.ប.ន. ប្រក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្រ្ត ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានារបស់ក្រសួងឧ.វ.ប.ន.

» ប្រកាសលេខ១១១ ឧ.វ.ប.ន. គ.ហ. ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មការដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ដើម្បីរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្រសួងឧ.វ.ប.ន.

» ប្រកាសលេខ១១២ ឧ.វ.ប.ន. ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មការនីតិកម្ម នៃក្រសួងឧ.វ.ប.ន.

៥. ផែនការយុទ្ធសាស្ត្រ

» ផែនការយុទ្ធសាស្ត្រក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២៥-២០២៨

» យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨

» យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអំបិលកម្ពុជាឆ្នាំ២០២២-២០២៦

» ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ២០២៣-២០២៧

» ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧

» កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ២០២៥-២០២៧

៦. លិខិតបទដ្ឋានគតិយុត្តផ្សេងៗ

» ព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/១០២៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤)

» សេចក្តីសម្រេច ០១ សសរ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវ និងអភិវឌ្ឍន៍

» សេចក្តីសម្រេច ០៩៣ ឧ.វ.ប.ន. សតម.សសរ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំ រៀបចំ និងធ្វើបច្ចុប្បន្នភាពសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមកម្ពុជា

» សេចក្តីសម្រេចលេខ ៣២៣ ឧវបន.អឧ.សសរ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងក្រុមការងារដឹកនាំ និងអនុវត្តគម្រោងស្តីពី«ការពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យម និងរោងចក្រធំ លើការគ្រប់គ្រងសំណល់»

» សេចក្តីសម្រេចលេខ ៣២៨ ឧវបន.មមជ.សសរ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការតម្រង់ទិសសម្រាប់សម្របសម្រួល និងតាមដានការអនុវត្តគម្រោងស្តីពីការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិក្នុងប្រទេសកម្ពុជា

» សេចក្តីសម្រេចលេខ ៣៤៧ ឧវបន.អវបន.សសរ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៃក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ៣៤៨ ឧវបន.អវបន.សសរ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារដឹកនាំ និងជំរុញឌីជីថលលូបនីយកម្មនៃក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ៣៦២ ឧវបន.នក.សសរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសិក្សាសមិទ្ធិលទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យានុយក្លេអ៊ែរ ដើម្បីសម្លាប់មេរោគលើពហុផលិតផលកម្ពុជា របស់ក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ៣៦៣ ឧវបន.គហ.សសរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ៣៦៤ ឧវបន.បល.សសរ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតយន្តការដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ៣៧០ ឧវបន.បល.សសរ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ២២៥ ឧ.វ.ប.ន. គហ.សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារចុះពិនិត្យ និងធ្វើអត្តសញ្ញាណកម្មដីទំនាស់នៅខេត្តកំពង់ស្ពឺ
» សេចក្តីសម្រេចលេខ ០១៣ ឧវបន.គហ.សសរ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ០១៤ ឧវបន.គហ.សសរ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៃអង្គភាពប្រើប្រាស់របស់ក្រសួងឧ.វ.ប.ន.
» សេចក្តីសម្រេចលេខ ០២៩ ឧវបន.សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
» សេចក្តីសម្រេចលេខ ១៤៧ ឧវបន.គអរស.សសរ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការអធិការកិច្ចរោងចក្រ សហគ្រាស និងសិប្បកម្មនៃក្រសួងឧ.វ.ប.ន.
» សេចក្តីណែនាំអំពីការហាមប្រាមការប្រើប្រាស់ឈ្មោះរដ្ឋាករទឹកនៅតាមទីតាំងប្រតិបត្តិករទឹកស្អាតឯកជន ដើម្បីចៀសវាងការភាន់ច្រឡំពីសាធារណជន និងជាការពង្រឹងដែនសមត្ថកិច្ចទទួលខុសត្រូវ
» គោលការណ៍ណែនាំអាស៊ាន អំពីវិធានការជាក់ស្តែងសម្រាប់សម្ភារសេរ៉ាមិចប៉ះពាល់ផ្ទាល់ជាមួយម្ហូបអាហារ (FCM), ក្របខណ្ឌកិច្ចព្រមព្រៀង ផ្នែកបញ្ញត្តកម្មឱសថអាស៊ាន, ផែនទីបង្ហាញផ្លូវអំពីស្តង់ដាពាណិជ្ជកម្មឌីជីថលក្នុងអាស៊ាន, នីតិវិធីចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោមក្រោមរបបបញ្ញត្តកម្មអាស៊ានផ្នែកឧបករណ៍អគ្គិសនី និង

អេឡិចត្រូនិក និងគោលការណ៍ ណែនាំអាស៊ានអំពីការផ្លាស់ប្តូរព័ត៌មានក្រោយទីផ្សារសម្រាប់បរិក្ខាពេទ្យ

» ក្របខណ្ឌក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងកូរ៉េ អាស៊ាន និងចិន អាស៊ាន និងកាណាដា
» ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា២០២៤-២០៣៥
» ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាតាមវិស័យចំនួន ៦ សំខាន់ៗ រួមមាន៖ វិស័យអប់រំ កសិកម្ម សុខាភិបាល ថាមពល ទេសចរណ៍ និងឌីជីថល
» ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០៣០





III

សមិទ្ធផល សម្រេចបាន ឆ្នាំ២០២៤

III- សមិទ្ធផលសម្រេចបានឆ្នាំ២០២៤

ជាមួយចក្ខុវិស័យវែងឆ្ងាយប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងឆ្នាំ២០២៤ កន្លងមក ក្រសួងឧ.វ.ប.ន បានខិតខំអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តនានា ឱ្យជោគជ័យ និងសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ដូចខាងក្រោម៖

១. វិស័យឧស្សាហកម្ម

អនុលោមតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្រសួងបានខិតខំពង្រឹង និងបង្កើនកម្លាំងធនធាន ផ្តោតការយកចិត្តទុកដាក់លើការងារគ្រប់គ្រងរោងចក្រ ការងារបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ការងារកម្មសិទ្ធិឧស្សាហកម្ម និងការងារជំរុញចលនាផលិតភាព។ ជាក់ស្តែងក្នុងឆ្នាំ២០២៤ វិស័យឧស្សាហកម្មអនុវត្តសម្រេចបានលទ្ធផល ដូចខាងក្រោម៖

១.១. ការងារឧស្សាហកម្ម

ក. រោងចក្រ

ការងារគ្រប់គ្រងទិន្នន័យ និងស្ថិតិរោងចក្រ មានដូចខាងក្រោម៖

» រោងចក្រធុនធំដំណើរការមានចំនួន ២.៤២៥ រោងចក្រ ក្នុងនោះរោងចក្រធុនធំកើតថ្មីមានចំនួន ៣២៦ រោងចក្រ និងរោងចក្រធុនធំបិទទ្វារមានចំនួន ២៦ រោងចក្រ។



ចំនួនរោងចក្រធុនធំដំណើរការក្នុង ២៥ រាជធានី-ខេត្ត ក្នុងឆ្នាំ២០២៤

ចំនួនរោងចក្រតាម ២៤ ជំពូក ផ្នែកកម្មន្តសាល ក្នុងឆ្នាំ២០២៤



ខ. កម្លាំងពលកម្ម

ក្នុងឆ្នាំ២០២៤ កម្លាំងពលកម្មសរុបមានចំនួន ១.១៦០.១៨១ នាក់ ក្នុងនោះមានស្រី ចំនួន ៨៥៤.៨១៩ នាក់ ស្មើនឹង ៧៣,៦៨% មានការកើនឡើងចំនួន ១១៩.៨៤៨ នាក់ ស្មើនឹង ១១,៥២% បើធៀបទៅនឹងឆ្នាំ២០២៣។

ចំនួនកម្លាំងពលកម្មសរុប កើតថ្មី ថយចុះ និងបាត់បង់ការងារ (រោងចក្របិទទ្វារ) ប្រចាំឆ្នាំនីមួយៗ





គ. តំបន់សេដ្ឋកិច្ចពិសេស

ក្នុងឆ្នាំ២០២៤ តំបន់សេដ្ឋកិច្ចពិសេសដែលមានរោងចក្រដំណើរការសរុបមានចំនួន ៣០ តំបន់ ស្ថិតនៅក្នុង ១២ រាជធានី-ខេត្ត មានការកើនឡើងចំនួន ៤ តំបន់ ស្មើនឹង ១៥,៣៨% បើធៀបទៅនឹងឆ្នាំ២០២៣។





ឃ. សួនឧស្សាហកម្ម

ក្នុងឆ្នាំ២០២៤ សួនឧស្សាហកម្មដែលមានរោងចក្រដំណើរការសរុប មានចំនួន ២០សួន ស្ថិតនៅក្នុង៥ រាជធានី-ខេត្ត មានការកើនឡើងចំនួន ៣ សួន ស្មើនឹង ១៧,៦៥% បើធៀបទៅនឹងឆ្នាំ២០២៣។

ចំនួនសួនឧស្សាហកម្មប្រចាំឆ្នាំនីមួយៗ



ចំនួនសួនឧស្សាហកម្មក្នុង ៥ រាជធានី-ខេត្តក្នុងឆ្នាំ២០២៤



សរុប ២០ សួន

ង. ប្រភពវិនិយោគ

ក្នុងឆ្នាំ២០២៤ ប្រភពវិនិយោគក្នុង និងក្រៅស្រុកសរុបមានចំនួន ៣២ ប្រភព មានការកើនឡើងចំនួន ២ ប្រភព ស្មើនឹង ៦,៦៧% បើធៀបទៅនឹងឆ្នាំ២០២៣។

ចំនួនប្រភពវិនិយោគប្រចាំឆ្នាំនីមួយៗ



ច. ទុនវិនិយោគ

ក្នុងឆ្នាំ២០២៤ ទុនវិនិយោគសរុបមានចំនួនជាង ២០.៤៥៦,៦ លានដុល្លារអាមេរិក មានការកើនឡើងចំនួន ១.៨៩០,២ លានដុល្លារអាមេរិក ស្មើនឹង ១០,១៨% បើធៀបទៅនឹងឆ្នាំ២០២៣។ ទុនវិនិយោគក្នុងស្រុកមានចំនួន ៣.៩៦១,៧ លានដុល្លារអាមេរិក ស្មើនឹង ១៩,៣៧% នៃទុនវិនិយោគសរុប។

ចំនួនទុនប្រចាំឆ្នាំនីមួយៗ



(ឯកតា៖លានដុល្លារអាមេរិក)

ចំនួនទុនវិនិយោគក្នុង ២៥ រាជធានី-ខេត្ត ក្នុងឆ្នាំ២០២៤



ឆ. តម្លៃបរិមាណផលិតផល

តម្លៃបរិមាណផលិតផលសរុបអនុវត្តឆ្នាំ២០២៤ សរុបមានចំនួនជាង ១៥.១៤៩ លានដុល្លារអាមេរិក មានការថយចុះចំនួនជាង ១.២១៥ លានដុល្លារអាមេរិក ស្មើនឹង ៧,៤៣% បើធៀបទៅនឹងឆ្នាំ២០២៣។ ក្នុងនោះ តម្លៃបរិមាណផលិតផលបម្រើទីផ្សារក្នុងស្រុក និងសម្រាប់ធ្វើការនាំចេញ មានដូចខាងក្រោម៖

» **ក្នុងស្រុក៖** មានចំនួន ៣.៨៩១ លានដុល្លារអាមេរិក មានការថយចុះចំនួន ២៣៣ លានដុល្លារអាមេរិក ស្មើនឹង ៥,៦៥% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ និង

» **នាំចេញ៖** មានចំនួន ១១.២៥៨ លានដុល្លារអាមេរិក មានការថយចុះចំនួន ៩៨២ លានដុល្លារអាមេរិក ស្មើនឹង ៨,០៣% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។

តម្លៃបរិមាណផលិតផល ប្រចាំឆ្នាំនីមួយៗ (លានដុល្លារអាមេរិក)



ជ. កម្រងសេវាសាធារណៈ

ការផ្ដល់សេវាសាធារណៈក្នុងឆ្នាំ២០២៤ កន្លងមក មានចំនួន ១.០៣១ ឯកសារ មានការកើនឡើងចំនួន ១៧៦ ឯកសារ ស្មើនឹង ២០,៥៨% បើធៀបទៅនឹងឆ្នាំ២០២៣។

ចំនួនការផ្ដល់សេវាសាធារណៈប្រចាំឆ្នាំនីមួយៗ (ឯកសារ)



ការផ្តល់សេវាសាធារណៈតាមប្រភេទប្រចាំឆ្នាំនីមួយៗ (ឯកសារ)



ឈ. សកម្មភាព និងការងារកិច្ចសហប្រតិបត្តិការ៖

» ចុះពិនិត្យទីតាំងគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៥ តំបន់, គម្រោងស្នើសុំបង្កើតរោងចក្រថ្មីចំនួន ២២៨ រោងចក្រ, គម្រោងស្នើសុំពង្រីកចំនួន ១១ រោងចក្រ, គម្រោងស្នើសុំប្តូរទីតាំងចំនួន ២០ រោងចក្រ, ករណីស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការចំនួន ២៦០ រោងចក្រ, ករណីស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការបានចំនួន ២៦៩ រោងចក្រ, និងចុះធ្វើអធិការកិច្ចរោងចក្រចំនួន ៣៤ រោងចក្រ

» ចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗបានចំនួន ២៥១ លើក។

១.២. ការងារបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម

ដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបង្កើនជីវភាពរស់នៅរបស់ប្រជាជន ការអភិវឌ្ឍវិស័យឧស្សាហកម្មជាអាទិភាពចម្បង។ ការអភិវឌ្ឍវិស័យឧស្សាហកម្ម ត្រូវធានាបានសុខដុមនីយកម្មសង្គម-សេដ្ឋកិច្ច ព្រមទាំងរក្សានូវសុខុមាលភាព និងបរិស្ថានសម្រាប់ប្រជាជន។ នាយកដ្ឋានបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ជាឫសគល់ដ៏សំខាន់ដែលតែងតែផ្តល់ជំនួយបច្ចេកទេស ចែករំលែកចំណេះដឹង និងបទពិសោធន៍ជាប្រចាំ ដល់ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។ ជាក់ស្តែងក្នុងឆ្នាំ២០២៤ លទ្ធផលការងារសម្រេចបានដូចខាងក្រោម៖

ក. ការងារកសាងលិខិតបទដ្ឋានគតិយុត្ត

ដើម្បីគាំទ្រដល់ការងារពង្រឹង និងលើកកម្ពស់សមត្ថភាពផ្នែកសុវត្ថិភាព និងបរិស្ថានការរៀបចំប្រកាស និងសេចក្តីណែនាំបច្ចេកទេស សម្រេចបានដូចខាងក្រោម៖

» ប្រកាស ស្ដីពីប្រព័ន្ធគ្រប់គ្រងការបំពុលក្នុងរោងចក្រ-សិប្បកម្ម សម្រេចបាន ៧០%
» សេចក្ដីណែនាំ ស្ដីពីការគ្រប់គ្រងសំណល់ឧស្សាហកម្ម សម្រេចបាន ៦០%
» សេចក្ដីណែនាំ ស្ដីពីការគ្រប់គ្រងហានិភ័យ និងការវាយតម្លៃហានិភ័យ សម្រេចបាន ៧០%
» សេចក្ដីណែនាំ ស្ដីពីការកសាងប្លង់បច្ចេកទេសឧស្សាហកម្ម សម្រេចបាន ៨០%
» នីតិវិធីត្រួតពិនិត្យ វាយតម្លៃ និងបញ្ជាក់ការគ្រប់គ្រងបរិស្ថានឧស្សាហកម្មក្នុងរោងចក្រ-សិប្បកម្ម សម្រេចបាន ៦០%
» ឯកសារបច្ចេកទេស ស្ដីពីការដាក់ស្លាកសញ្ញាសារធាតុគីមីតាមប្រព័ន្ធ GHS សម្រេចបាន ៦០%។

ខ. ការងារត្រួតពិនិត្យ វាយតម្លៃ ប្លង់បច្ចេកទេសឧស្សាហកម្ម

ដើម្បីគ្រប់គ្រង វាយតម្លៃហានិភ័យក្នុងទីតាំងមូលដ្ឋានផលិតកម្ម ឱ្យកាន់តែមានសុវត្ថិភាពប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងឆ្នាំ២០២៤ ការត្រួតពិនិត្យវាយតម្លៃប្លង់បច្ចេកទេសឧស្សាហកម្មជូនរោងចក្រ-សិប្បកម្ម សម្រេចបានចំនួន ៤៩១ មូលដ្ឋាន កើនឡើង ៤២,៣១% បើធៀបនឹងឆ្នាំ២០២៣។

គ. ការងារត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម

ដើម្បីពង្រឹងការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ក្នុងរោងចក្រ-សិប្បកម្មឱ្យបានត្រឹមត្រូវ សំដៅចូលរួមចំណែក និងធានាឱ្យបាននូវសុវត្ថិភាពបរិស្ថាន និងសុខុមាលភាពសង្គម, ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម បានផ្ដល់ការណែនាំទៅលើដំណើរការគ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលមានហានិភ័យ សម្រេចបានចំនួន ១.០១៤ មូលដ្ឋាន កើនឡើង ១៦,២២% បើធៀបនឹងឆ្នាំ២០២៣។

វឌ្ឍនភាពការងារត្រួតពិនិត្យ និងវាយតម្លៃលក្ខណបច្ចេកទេសសុវត្ថិភាព ឧស្សាហកម្ម និងប្លង់បច្ចេកទេសឧស្សាហកម្ម ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម



ឃ. ការងារផ្តល់ជំនួយបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម

ដើម្បីពង្រឹង និងលើកកម្ពស់សមត្ថភាពបច្ចេកទេសសុវត្ថិភាពប្រតិបត្តិការរបស់បុគ្គលិក-កម្មករ អ្នកបញ្ជាគ្រឿងចក្រ គ្រឿងម៉ាស៊ីន ក្នុងរោងចក្រ-សិប្បកម្ម ឱ្យមានកាន់តែប្រសើរឡើងក្នុងទីតាំងផលិតកម្ម ការរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម ជូនវិស័យឯកជន សម្រេចបានចំនួន ៨ លើក មានសិក្ខាកាមចូលរួមចំនួន ៣.៩១១ នាក់ មកពីរោងចក្រ-សិប្បកម្ម ចំនួន ៨០០ មូលដ្ឋាន កើនឡើង ៣៨,៤៤% បើធៀបនឹងឆ្នាំ២០២៣។ ក្នុងគោលបំណងចែករំលែកចំណេះដឹង បទពិសោធន៍ នៃការបញ្ជា ការថែទាំ ការទុកដាក់គ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យដល់បុគ្គលិក-កម្មករឱ្យយល់ពីការការពារសុវត្ថិភាព និងបរិស្ថាន ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលកើតមានឡើងជាយថាហេតុបាន។

វឌ្ឍនភាពសិក្ខាកាមចូលរួមបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពឧស្សាហកម្ម



ង. ការងារជំរុញការអភិវឌ្ឍឧស្សាហកម្មបៃតង

ការរៀបចំកម្មវិធី **«ពានរង្វាន់ឧស្សាហកម្មបៃតងកម្ពុជា»** មានសមាជិកចូលរួមសរុបចំនួន ១០៤ នាក់ មកពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរោងចក្រ ដោយបានផ្តល់ពានរង្វាន់ដល់រោងចក្រ-សិប្បកម្ម ចំនួន ១៧ មូលដ្ឋាន ក្នុងនោះរួមមាន ១) មាស ចំនួន ៤ ពាន, ២) ប្រាក់ ចំនួន ៩ ពាន និង ៣) សំរឹទ្ធិ ចំនួន ៤ ពាន ក្នុងគោលបំណងផ្តល់ការទទួលស្គាល់ ការលើកទឹកចិត្ត និងគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ដែលបញ្ចេញកាបូនតិច ដើម្បីបង្កើនផលិតភាព និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការផ្ទេរបច្ចេកវិទ្យាអំណោយផលល្អដល់បរិស្ថាន។

ពានរង្វាន់ឧស្សាហកម្មបៃតងដែលបានផ្តល់ជូនក្រុមហ៊ុនពីឆ្នាំ២០២១-២០២៤



១.៣. ការងារកម្មសិទ្ធិឧស្សាហកម្ម

» បានចេញប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សរុបចំនួន ១៩៨

» បានចុះបញ្ជីគំនូរឧស្សាហកម្ម សរុបចំនួន ៤៥៩

ក. ការងារចុះបញ្ជី

» ក្នុងឆ្នាំ២០២៤ ការទទួលសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មសរុបចំនួន ៩៤១ សំណុំលិខិត មានការថយចុះ ១៤% បើធៀបនឹងឆ្នាំ២០២៣ ដែលទទួលបាន ១.០៩៩ សំណុំលិខិត។ ការផ្តល់ប្រកាសនីយបត្រតក្កកម្មបានចំនួន ៨១ សំណុំលិខិត។

» ការទទួលពាក្យស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍សរុបចំនួន ១២ សំណុំលិខិត មានការកើនឡើង១០០% បើធៀបនឹងឆ្នាំ២០២៣ ដែលទទួលបានចំនួន ៦ សំណុំលិខិត។

» ការទទួលកម្រៃសេវាប្រកាសនីយបត្រតក្កកម្ម ក្នុងឆ្នាំ២០២៤ មានចំនួន ៩២៤ សេវា មានការកើនឡើង២៦% បើប្រៀបធៀបឆ្នាំ២០២៣ ដែលទទួលបាន ៧៣៤ សេវា

» ការទទួលសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មសរុបចំនួន ៩០ សំណុំលិខិត មានការកើនឡើង ១៥% បើប្រៀបធៀបឆ្នាំ២០២៣ ដែលទទួលបាន ៧៨ សំណុំលិខិត។ ការចុះបញ្ជីគំនូរឧស្សាហកម្មថ្មីសម្រេចបានចំនួន ៧២ សំណុំលិខិត និងការចុះបញ្ជីគំនូរឧស្សាហកម្មសារឡើងវិញសម្រេចបានចំនួន ៩៦ សំណុំលិខិត។

ពានរង្វាន់ឧស្សាហកម្មបៃតងដែលបានផ្តល់ជូនក្រុមហ៊ុនពីឆ្នាំ២០២១-២០២៤



	២០២៣	២០២៤	កើនឡើង/ថយចុះ %
បានទទួលសំណុំលិខិតប្រកាសនីយបត្រតក្កកម្ម	1,099	941	-14
បានចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម	118	81	-31
បានទទួលសំណុំលិខិតវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍	6	12	100
បានផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍	0	0	0
បានទទួលការបង់កម្រៃសេវាប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្ម	734	924	26
បានទទួលការបង់កម្រៃសេវាប្រចាំឆ្នាំសម្រាប់ម៉ូដែលមានអត្ថប្រយោជន៍	12	21	75
បានទទួលសំណុំលិខិតស្នើសុំគំនូរឧស្សាហកម្ម	78	90	15
បានចុះបញ្ជីគំនូរឧស្សាហកម្ម	77	72	-6
បានទទួលសំណុំលិខិតស្នើសុំគំនូរឧស្សាហកម្មសារឡើងវិញ	127	96	-24
បានចុះបញ្ជីនូវឧស្សាហកម្មសារឡើងវិញ	127	96	-24
បានទទួលសំណុំលិខិត Hague	68	73	7

ខ. កិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

- **កិច្ចសហប្រតិបត្តិការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ៖**
  - » បានជួបប្រជុំជាមួយអ្នកជំនាញ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤។ កិច្ចប្រជុំរវាងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ស្តីពី Cooperation Agreement between Ministry of Industry, Science, Technology & Innovation and World Intellectual Property Office for the Development of Intellectual Property Office Business Services និងពិភាក្សាទៅលើការប្រើប្រាស់ WIPO DAS Office Portal និងការរៀបចំអនុស្សរណៈនៃការយោគយល់។ ជាលទ្ធផលក្រសួងនឹងរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាង ក្រសួងឧ.វ.ប.ន. និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក អំពី IPAS-4 នាពេលខាងមុខ។
  - » ទទួលលិខិតពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ទទួលស្គាល់កម្ពុជា អំពីការចូល WIPO DAS (WIPO Digital Access Services) ដែលនឹងមានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៥ ខាងមុខ។
  - » បានចុះកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃព្រះរាជាណាចក្រកម្ពុជា និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក សម្រាប់ការអភិវឌ្ឍសេវាកម្មអាជីវកម្មកម្មសិទ្ធិបញ្ញា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ តាមរយៈអនឡាញ។
  - » បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវសេវាកម្មចុះបញ្ជីតាមអនឡាញ សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការកសាងសមត្ថភាពលើការប្រើប្រាស់សេវាអនឡាញ (The Launching of Patents and Industrial Design Online Filing Service and National Public Awareness / Capacity Building Workshop on Online Filing ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥ នៅសណ្ឋាគារសូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ។

- **កិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋប្រជាមានិតចិន CNIPA ៖**

អំពីកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញា ការចុះបញ្ជីទទួលស្គាល់សារឡើងវិញប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា និងផែនការសកម្មភាពឆ្នាំ២០២៤-២០២៥។ ក្រសួងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ជាមួយអង្គភាពកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋប្រជាមានិតចិន CNIPA បន្តសុពលភាពកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពី

កម្មសិទ្ធិបញ្ញា ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា និងផែនការសកម្មភាពឆ្នាំ២០២៤-២០២៥ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។

- **កិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី IPOS ៖** បានរៀបចំពិធីចុះហត្ថលេខាលើការបន្តសុពលភាពលើកទី២ នៃអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអំពីកម្មសិទ្ធិឧស្សាហកម្ម រវាងក្រសួងឧ.វ.ប.ន. និងអង្គការកម្មសិទ្ធិបញ្ញាសិង្ហបុរី (IPOS) តាមប្រព័ន្ធអនឡាញ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥។

- **កិច្ចសហការជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប EPO ៖**
    - » បានចុះហត្ថលេខាជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប EPO លើផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៤-២០២៥ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤
    - » បានរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយការយល់ដឹងដល់សាធារណជន អំពីនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងព័ត៌មានប្រកាសនីយបត្រតក្កកម្មតាមរយៈ ESPACENET កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤។

- **កិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ KIPO ៖**
    - » Korea International Cooperation Agency (KOICA) បានផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជា ចំនួន២០រូប ស្តីពី "Capacity Building for Intellectual Property and Patent Recognition Program System in Cambodia" កាលពីថ្ងៃទី៧-១៧ ខែតុលា ឆ្នាំ២០២៤ នៅសាធារណរដ្ឋកូរ៉េ
    - » កិច្ចប្រជុំជាមួយអង្គការកម្មសិទ្ធិបញ្ញាប្រទេសកូរ៉េ (KIPO) ពិភាក្សាអំពីការគ្រប់គ្រងស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញា ជាមួយ AI និងប្រធានបទផ្សេងៗ កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤។

- **កិច្ចសហប្រតិបត្តិការជាមួយអង្គការ UPOV (International Union for the Protection of New Varieties of Plants) ៖** ប្រជុំអនឡាញជាមួយអង្គការ UPOV ពិភាក្សាអំពីការកែសម្រួលសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលក្រសួងឧ.វ.ប.ន. បានកែសម្រួលជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឱ្យស្របតាម UPOV។ ជាលទ្ធផល សេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលកែសម្រួលរួចជាភាសាអង់គ្លេស បានទទួលការយល់ស្របពីអង្គការ UPOV រួចហើយ។

• **កិច្ចសហប្រតិបត្តិការជាមួយសមាគមកម្មសិទ្ធិបញ្ញាកម្ពុជា IPAC ៖** ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិឧស្សាហកម្ម រវាងក្រសួងឧ.វ.ប.ន. និងសមាគមកម្មសិទ្ធិបញ្ញាកម្ពុជា កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤។

១.៤. ការងារបង្កើនផលិតភាព

ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ២០២៤ កន្លងមក ក្រសួងឧ.វ.ប.ន. តាមរយៈមជ្ឈមណ្ឌលផលិតភាពជាតិ បានខិតខំជំរុញចលនាផលិតភាព ដើម្បីបង្កើនសមត្ថភាពសម្រាប់ការប្រកួតប្រជែងប្រកបដោយចីរភាព តាមរយៈការផ្សព្វផ្សាយ បណ្តុះបណ្តាល និងប្រឹក្សាយោបល់ដល់ឧស្សាហករ សិប្បករ និងស្ថាប័នពាក់ព័ន្ធ អំពីវិធីសាស្ត្រលើកកម្ពស់ផលិតភាពនានា សំដៅកាត់បន្ថយថ្លៃដើម បង្កើនគុណភាព ទិន្នផល ភាពប្រកួតប្រជែង និងការលើកទឹកចិត្តបុគ្គលិក-កម្មករ ក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។ ទិសដៅជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគ្រាស និងស្ថាប័នទាំងនោះ គឺតាមរយៈការផ្តល់ជំនាញដូចជា៖ វិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាព «ស៥» (សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដា ស្ថិតស្ថេរ) ខាយហ្សិន ប្រព័ន្ធថែទាំម៉ាស៊ីន ប្រព័ន្ធគ្រប់គ្រងគុណភាព ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ប្រព័ន្ធផលិតកម្ម LEAN ប្រព័ន្ធគ្រប់គ្រងពុទ្ធិ ប្រព័ន្ធគ្រប់គ្រងផលិតភាពបៃតង និងឧត្តមភាពធុរកិច្ច ជាដើម។ល។ ជាក់ស្តែង ក្រោមកិច្ចសហការជាមួយអង្គការផលិតភាពអាស៊ី (APO) បានបង្កើតនូវកម្មវិធីជាច្រើន រួមមានការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីនានាទាំងក្នុងប្រទេស និងពីពហុប្រទេស សរុបមានចំនួន ៨៥ គម្រោង មានអ្នកចូលរួម ១.៦១៩នាក់ បើប្រៀបធៀបឆ្នាំ២០២៣ មានចំនួន ៧៣ គម្រោង អ្នកចូលរួម ១.៥៦៥នាក់។ ទន្ទឹមនេះ មជ្ឈមណ្ឌលផលិតភាពជាតិបានបោះពុម្ពសៀវភៅលើកកម្ពស់ផលិតភាព ដើម្បីជាប្រយោជន៍ដល់សាធារណៈជនដែលមានបំណងចង់អភិវឌ្ឍផលិតភាព គុណភាព ភាពប្រកួតប្រជែង និងគំនិតផ្តួចផ្តើមថ្មីៗបន្ថែមទៀត ដើម្បីអភិវឌ្ឍអង្គភាពរបស់ខ្លួន ឱ្យកាន់តែមានការរីកចម្រើនឡើងមួយកម្រិតទៀត។

ក. ការងារអភិវឌ្ឍន៍ និងបណ្តុះបណ្តាលផលិតភាព

១. ការរៀបចំវគ្គបណ្តុះបណ្តាល នៅទីស្តីការក្រសួងឧ.វ.ប.ន. មាន៖

» វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាព «ស៥» ចំនួន ៥ វគ្គ សិក្ខាកាមចំនួន ១០៩ នាក់

» វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងពុទ្ធិ សិក្ខាកាមចំនួន ២២ នាក់

- វគ្គបណ្តុះបណ្តាល ស្តីពីផលិតកម្មស្អាត សិក្ខាកាមចំនួន ២៥ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធផលិតកម្ម LEAN សិក្ខាកាមចំនួន ២៥ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំប្រត្តិបត្តិសម្រាប់គ្រប់គ្រងអាជីវកម្ម សិក្ខាកាម ចំនួន ៣៣ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាព «ស៥» ចំនួន ២ វគ្គ សម្រាប់មន្ត្រីក្នុងក្រសួង និងក្រុមហ៊ុន រោងចក្រ សហគ្រាសដែលដាក់ពាក្យចូលរួមកម្មវិធីពានរង្វាន់សមិទ្ធផលផលិតភាព «ស៥» ប្រចាំឆ្នាំ២០២៤ សិក្ខាកាមសរុបចំនួន ៩១ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីផលិតភាព និងគុណភាពដើម្បីការអភិវឌ្ឍ SME នៅក្នុងបរិបទថ្មី សិក្ខាកាមចំនួន ៨៥នាក់ (ចូលរួមដោយផ្ទាល់ចំនួន៤០នាក់)។

២. ការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាតាមបណ្តាខេត្ត

- សិក្ខាសាលា ស្តីពីការលើកកម្ពស់ភាពប្រកួតប្រជែងតាមរយៈផលិតភាព និងនវានុវត្តន៍ នៅខេត្តរតនគិរី សិក្ខាកាមចំនួន ១០៨ នាក់
- សិក្ខាសាលា ស្តីពីការអនុវត្តល្អនៃប្រព័ន្ធ«ស៥» នៅខេត្តព្រះសីហនុ សិក្ខាកាមចំនួន ១០០ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធផលិតកម្ម LEAN និងការអនុវត្ត «ស៥» នៅខេត្តពោធិ៍សាត់ សិក្ខាកាមចំនួន ១០០ នាក់
- វគ្គបណ្តុះបណ្តាល ស្តីពីការច្នៃប្រឌិតថ្មី និងផលិតភាពក្នុងបរិបទថ្មី នៅខេត្តបាត់ដំបង សិក្ខាកាមចំនួន ៩៥នាក់
- សន្និសីទស្តីពីផលិតភាពប្រកបដោយបរិយាបន្ន សម្រាប់ធ្វើឱ្យប្រសើរឡើងនូវធុរកិច្ចនៅកម្ពុជា នៅខេត្តស្ទឹងត្រែង សិក្ខាកាមចូលរួមចំនួន ១០០នាក់។

៣. ការពង្រឹងសមត្ថភាពមន្ត្រីមជ្ឈមណ្ឌលផលិតភាព៖ រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ១០ វគ្គ និងចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលនានារបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

ខ. កម្មវិធីពានរង្វាន់សមិទ្ធផលផលិតភាព «ស៥» ៖

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីពានរង្វាន់សមិទ្ធផលផលិតភាព «ស៥» ប្រចាំឆ្នាំ ២០២៤ សិក្ខាកាមចំនួន ១១៧ នាក់
- រៀបចំកម្មវិធីប្រកាសពានរង្វាន់សមិទ្ធផលផលិតភាព «ស៥» ដល់ក្រុមហ៊ុន/សហគ្រាស /សិប្បកម្ម ចំនួន ១១ មានក្រុមហ៊ុន/សហគ្រាស/សិប្បកម្មចំនួន ៥ បានទទួលពានរង្វាន់សមិទ្ធផលផលិតភាព «ស៥» អមដោយវិញ្ញាបនបត្រអនុវត្ត «ស៥» ដោយជោគជ័យ។

ដោយទ្បែកក្រុមហ៊ុន/សហគ្រាស/សិប្បកម្មចំនួន ១ ទទួលវិញ្ញាបនបត្រអនុវត្ត «ស៥» ជោគជ័យ និងក្រុមហ៊ុន/សហគ្រាស/សិប្បកម្មចំនួន ៥ ទទួលបានវិញ្ញាបនបត្រចូលរួម កម្មវិធីពានរង្វាន់សមិទ្ធផលផលិតភាព «ស៥»។ កម្មវិធីនេះ មានវត្តមានអ្នកចូលរួម ចំនួន ១១០ នាក់។

គ. កិច្ចសហប្រតិបត្តិការជាមួយអង្គការផលិតភាពអាស៊ី (APO)

១. ការចូលរួមគម្រោងក្នុងប្រទេស

» បញ្ចប់កិច្ចសហការអនុវត្តគម្រោងស្ទង់មតិ ស្តីពីការឆ្លើយតបរបស់សហគ្រាសធុនតូច និងមធ្យមទៅនឹងការផ្ទុះនៃកូវីដ-១៩ ជុំទី៤ (គម្រោងរបស់ ADB)
» បោះពុម្ពសៀវភៅលើកកម្ពស់ផលិតភាព ខិត្តប័ណ្ណ ថង់យួរអេកូ និងផលិតវីដេអូ សកម្មភាពការងាររបស់ NPCC និងវិធីសាស្ត្រ Kaizen
» ធ្វើការផ្សព្វផ្សាយ APO Productivity Talk ចំនួន ៣០ គម្រោង
» រៀបចំវគ្គបណ្តុះបណ្តាលថ្នាក់អន្តរជាតិ ស្តីពីប្រព័ន្ធប្រាក់ឈ្នួលដែលផ្សារភ្ជាប់ផលិតភាព សិក្ខាកាម ចំនួន ២៨ នាក់
» រៀបចំវគ្គបណ្តុះបណ្តាលថ្នាក់អន្តរជាតិ ស្តីពីការប្រើប្រាស់បច្ចេកវិទ្យា Blockchains សម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក សិក្ខាកាមចំនួន ២៧នាក់
» រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាតិ ស្តីពីការធ្វើសវនកម្មប្រព័ន្ធគ្រប់គ្រង សិក្ខាកាមចំនួន ១៦២ នាក់
» រៀបចំសិក្ខាសាលាអន្តរជាតិ ស្តីពីសហគ្រិនភាពកសិ-ធុរកិច្ចសម្រាប់ជនមានពិការភាព តាមប្រព័ន្ធអនឡាញ ពីប្រទេសកម្ពុជា សិក្ខាកាមចំនួន ២១នាក់
» រៀបចំវគ្គបណ្តុះបណ្តាលជាតិ ស្តីពីការអភិវឌ្ឍអ្នកជំនាញផលិតភាពក្នុងវិស័យសាធារណៈ សិក្ខាកាមចំនួន ៣៥ នាក់
» រៀបចំវគ្គបណ្តុះបណ្តាលជាតិ ស្តីពីក្របខណ្ឌឧត្តមភាពធុរកិច្ច សិក្ខាកាមចំនួន ៣៥ នាក់។

២. ការចូលរួមគម្រោងពហុប្រទេស

» សម្របសម្រួលជ្រើសរើសបេក្ខជនចូលរួមគម្រោងរបស់អង្គការផលិតភាពអាស៊ី (APO) នៅក្រៅប្រទេស ចំនួន ៦០ គម្រោង សិក្ខាកាមចំនួន ១៨៤ នាក់
» ចូលរួមកិច្ចប្រជុំគណៈគ្រប់គ្រងអង្គការផលិតភាពអាស៊ី (APO) លើកទី៦៦ នៅប្រទេស ម៉ាឡេស៊ី
» ចូលរួមកិច្ចប្រជុំរបស់ប្រធានស្ថាប័នផលិតភាពជាតិលើកទី៦៥ នៅប្រទេសហ្វីជី។

សង្ខេបលទ្ធផលការងារ និង ការប្រៀបធៀប៖ ឆ្នាំ២០២៣ និង ឆ្នាំ២០២៤



ទីកន្លែង	ឆ្នាំ២០២៣						ឆ្នាំ២០២៤					
	ចំនួនគម្រោង	ចំនួនអ្នកចូលរួមតាមស្ថាប័ន				សរុប 1+2+3+4	ចំនួនគម្រោង	ចំនួនអ្នកចូលរួមតាមស្ថាប័ន				សរុប 1+2+3+4
		ក្រសួង ឧ.ស	ស្ថាប័ន ពាក់ព័ន្ធ	SME & Other	សមាជិក APO			ក្រសួង ឧ.ស	ស្ថាប័ន ពាក់ព័ន្ធ	SME & Other	សមាជិក APO	
		1	2	3	4			1	2	3	4	
ក្នុងប្រទេស	14	301	226	859	19	1,405	25	192	103	1,084	56	1435
ពហុប្រទេស	59	74	50	36		160	60	68	65	51		184
សរុប	73	375	276	895	19	1,565	85	260	168	1,135	56	1,619

១.៥. ការងារគម្រោង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូ

គម្រោងស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុល ជាកិច្ចសហការរវាង ក្រសួងឧ.វ.ប.ន. ជាមួយក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន (METI) និងសមាគមគ្រប់គ្រងបរិស្ថានជប៉ុនសម្រាប់ឧស្សាហកម្ម (JEMAI) ដែលគម្រោងនេះ ផ្តោតលើប្រព័ន្ធគ្រប់គ្រងការបំពុលក្នុងទីតាំងផលិតកម្ម ក្នុងគោលបំណងចែករំលែកចំណេះដឹង បទពិសោធន៍ របស់ប្រទេសជប៉ុន ក្នុងការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យការបំពុលក្នុងទីតាំងផលិតកម្មនៅកម្ពុជា គម្រោងនេះមានរយៈពេលអនុវត្តក្នុងឆ្នាំ២០២០-២០២៦។ ដោយឡែកក្នុងឆ្នាំ២០២៤ សមិទ្ធផលដែលក្រុមការងារគម្រោង សម្រេចបានរួមមាន៖

» រៀបចំសេចក្តីព្រាងប្រកាស ស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុលក្នុងរោងចក្រ-សិប្បកម្ម
» រៀបចំសិក្ខាសាលាពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុល នៅក្នុងរោងចក្រ-សិប្បកម្មចំនួន ២ លើក
» បានរៀបចំផែនការចុះស្រាវជ្រាវ ទិន្នន័យលើផលិតផលកសិ-ឧស្សាហកម្ម

២. វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

២.១. ការងារចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

នៅក្នុងឆ្នាំ២០២៤ ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មផ្នែកកម្មន្តសាលបានសរុបចំនួន ១.២៩២មូលដ្ឋាន (ចុះបញ្ជីថ្នាក់កណ្តាលបានចំនួន ១៧ មូលដ្ឋាន ចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានចំនួន ៣៣៨ មូលដ្ឋាន តាមបណ្តាមន្ទីររាជធានី-ខេត្តចំនួន ៨៣១មូលដ្ឋាន និងចុះបញ្ជីនៅតាមរាជធានី-ខេត្ត/ក្រុង ស្រុក/ខណ្ឌបានចំនួន ១០៦មូលដ្ឋាន), បានចេញវិញ្ញាបនបត្រដំណើរការចំនួន ១.០៥២មូលដ្ឋាន និងវិញ្ញាបនបត្របន្តចំនួន ១.៣៣៨មូលដ្ឋាន ដែលបង្កើតបានការងារថ្មីចំនួន ២៥.៨៣៣នាក់។ ទន្ទឹមនឹងនេះ ក៏មានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មបានបិទចំនួន ១.៩៥០ មូលដ្ឋានផងដែរ ដែលបានធ្វើឱ្យពលកម្មថយចុះចំនួន ១៣.៥៧៦នាក់។

គិតត្រឹមដំណាច់ឆ្នាំ២០២៤ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មបង្គរសរុបមានចំនួន ៤៣.៩៧០មូលដ្ឋាន (សហគ្រិនស្ត្រី ៨.៣២៥មូលដ្ឋាន) និងពលកម្មចំនួន ៤៧៦.២២៣នាក់ (ស្ត្រី ១៤៤.៥៥៩នាក់)។ ទិន្នន័យនេះនឹងត្រូវធ្វើបច្ចុប្បន្នភាព។

ឯកឧត្តម ហែម វណ្ណឌី ចុះទស្សនកិច្ចទីតាំងសិប្បកម្មផលិតចំណីអាហារ PPF Yummy Food នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤

ស្ថិតិសរុបរួមសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ប្រចាំឆ្នាំ២០២៤

ចំណាត់ថ្នាក់ឧសក ISIC Rev.4	ឆ្នាំ២០២៣		ខែធ្នូ ឆ្នាំ២០២៤					សរុបពីដើមខែមករា ដល់ចុះខែធ្នូ					មូលដ្ឋាន និង ពលកម្មសរុបរួម	
	ចំនួនមូលដ្ឋាន	ចំនួនពលកម្ម	ចំនួនមូលដ្ឋាន			ចំនួនពលកម្ម		ចំនួនមូលដ្ឋាន			ចំនួនពលកម្ម		ចំនួនមូលដ្ឋាន	ចំនួនពលកម្ម
			ថ្មី	បន្ត	បិទ	ថ្មី	ថយ	ថ្មី	បន្ត	បិទ	ថ្មី	ថយ		
១០-១២. ផ្នែកអាហារភេសជ្ជៈ បារី	28,966	169,148	30	71	808	209	1,487	533	798	1,515	4,484	4,261	27,984	69,371
១៣-១៥. ផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ ចាក់កាបូប និងស្បែកជើង	3,527	210,323	9	3	2	715	99	195	77	75	13,594	6,556	3,647	217,361
១៦. ផ្នែកឧស្សាហកម្មឈើ និងផលិតផលពីឈើ (លើកលែងគ្រឿងសង្ហារឹម)	309	2,296	-	-	1	-	5	22	8	5	289	123	326	2,462
១៧-១៨. ផ្នែកផលិតផលពីក្រដាស និងក្រដាស និងបោះពុម្ពផ្សេងៗលើកលែងសម្លៀកបំពាក់	214	4,677	4	1	1	154	18	46	13	8	779	206	252	5,250
១៩-២២. ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងផ្លាស្ទិក	1,532	14,226	8	7	3	100	34	163	147	44	2,382	338	1,651	16,270
២៣. ផ្នែកផលិតកម្មពីរ៉ែមិនមែនលោហៈ	2,187	30,287	6	5	7	77	158	57	102	85	675	956	2,159	30,006
២៤-៣០. ផ្នែកឧស្សាហកម្មកែច្នៃលោហៈ	5,493	22,101	12	17	2	851	9	128	161	89	2,032	637	5,532	23,496
៣១-ផ្នែកគ្រឿងសង្ហារឹម	772	4,346	1	2	-	12	-	24	20	24	324	213	772	4,457
៣២-ផ្នែកឧស្សាហកម្មផ្សេងៗ	1,628	6,562	85	3	1	478	4	124	12	105	1,274	286	1,647	7,550
សរុប	44,628	463,966	155	109	825	2,596	1,814	1,292	1,338	1,950	25,833	13,576	43,970	476,223

ស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅទីស្តីការក្រសួង មន្ទីររាជធានី ខេត្តនិងរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ ប្រចាំឆ្នាំ២០២៤

ល.រ	អង្គភាព	សរុបប្រចាំខែធ្នូ ឆ្នាំ២០២៤						សរុបប្រចាំខែធ្នូ ឆ្នាំ២០២៤					
		ប្រកាស/សេចក្តីសម្រេច	ការចេញវិញ្ញាបនបត្រ		ព្យួរ/បិទ	ចំនួនពលកម្ម		ប្រកាស/សេចក្តីសម្រេច	ការចេញវិញ្ញាបនបត្រ		ព្យួរ/បិទ	ចំនួនពលកម្ម	
			ថ្មី	បន្ត		កើន	ថយ		ថ្មី	បន្ត		កើន	ថយ
A1. ចុះបញ្ជីនៅថ្នាក់កណ្តាល													
1	នាយកដ្ឋាន SME	-	-	-	-	-	-	7	43	25	3	131	107
2	នាយកដ្ឋានកិច្ចការសិប្បកម្ម	-	-	-	-	-	-	10	27	21	-	230	-
	សរុប A1	-	-	-	-	-	-	17	70	46	3	361	107
A2. ចុះបញ្ជីតាមប្រព័ន្ធអនឡាញ													
1	សហគ្រាស	45	27	-	-	2,033	-	135	43	-	-	5,708	-
2	សិប្បកម្ម	58	14	-	-	-	-	203	14	-	-	2,343	-
	សរុប A2	103	41	-	-	2,033	-	338	57	-	-	8,051	-
B1. ចុះបញ្ជីនៅមន្ទីររាជធានី/ខេត្ត													
	សរុប B1	49	50	99	825	546	1,814	8311	822	1,254	1,924	16,264	13,362
B2. ចុះបញ្ជីនៅរាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ													
	សរុប B2	3	2	10	0	17	0	106	103	168	23	1,157	107
	សរុប A1+A2+B1+B2	155	93	109	825	2,596	1,184	1,292	1,052	1,338	1,950	25,833	13,576

ប្រៀបធៀបស្ថិតិសហគ្រាស និងសិប្បកម្មឆ្នាំ២០២០ ដល់ឆ្នាំ២០២៤



ចំនួនសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ក្នុងខែធ្នូ ឆ្នាំ២០២៤



ចំនួនមូលដ្ឋានបង្កើតថ្មី បន្ត និងចំនួនពលកម្ម ក្នុងខែធ្នូ ឆ្នាំ២០២៤



ចំនួនមូលដ្ឋានបិទ និងពលកម្មថយ ក្នុងឆ្នាំ២០២៤



ទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី១ ក្រោមប្រធានបទ
"ពង្រឹងប្រព័ន្ធអេកូឡូស៊ីសហគ្រាសធុនមីក្រូ តូច និងមធ្យមដើម្បីកំណើនកាន់តែប្រសើរ" នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និងធនាគារ SME Bank ក្នុងគោលដៅបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម និងធុរកិច្ចថ្មី

២.២. ការងារកសាងលិខិតបទដ្ឋានគតិយុត្ត និងផ្សព្វផ្សាយ

ដើម្បីលើកស្ទួយវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ឱ្យបានកាន់តែមានភាពប្រសើរឡើង ក្នុងការចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិ ក្រសួងសម្រេចបាននូវការរៀបចំលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដូចជា៖

- បានទទួលការអនុម័តលើអនុក្រឹត្យ ស្តីពីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយបានកំណត់យកថ្ងៃទី២៧ មិថុនា ជារៀងរាល់ឆ្នាំ ជាទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម
- បានទទួលការអនុម័តលើការស្នើសុំចុះបញ្ជីសហគ្រាសសិប្បកម្មគ្មានហានិភ័យ តាមប្រព័ន្ធផ្តល់សេវាសាធារណៈ ឌីជីថលរបស់ក្រសួងឧ.វ.ប.ន តាមរយៈសេចក្តីជូនដំណឹងលេខ ២០២៤ សជណ.ឧវ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានរៀបចំជាសេចក្តីព្រាងគោលនយោបាយ និងបានផ្ញើជូនស្នើសុំឱ្យមានការជួយពិនិត្យ និងបានផ្តល់អនុសាសន៍ ត្រឡប់ពីគណៈកម្មាធិការគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចហើយ បច្ចុប្បន្ននេះកំពុងរៀបចំបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីជួយផ្តល់ជាតុចូលបន្ថែម និងកែសម្រួលលើគោលនយោបាយនេះឱ្យកាន់តែសមស្របទៅតាមបរិបទ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល
- បានប្រជុំពិភាក្សាកែសម្រួលបញ្ចប់ប្រកាសស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មផ្នែកកម្មន្តសាល និងប្រកាសស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម និងត្រៀមឆ្លងភាគីពាក់ព័ន្ធ មុននឹងស្នើសុំសេចក្តីសម្រេចជាផ្លូវការពីថ្នាក់ដឹកនាំក្រសួង
- បានប្រជុំពិភាក្សា ដើម្បីរៀបចំធ្វើបច្ចុប្បន្នភាពសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម
- បានប្រជុំពិគ្រោះយោបល់លើការសិក្សាវាយតម្លៃ ការកំណត់និយមន័យថ្មីសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs)
- ចូលរួមកិច្ចប្រជុំពិភាក្សា តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ក្នុងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង។

ជាមួយគ្នានេះដែរ ក្រសួងក៏បានផ្សព្វផ្សាយការងារ KhmerSME តាមរយៈបណ្តាញព័ត៌មានសង្គម (Facebook, Telegram, Linkedin , Youtube និង website)។

២.៣. ការងារបណ្តុះបណ្តាលក្នុង/ក្រៅប្រទេស

ក្រសួងបាននិងកំពុងយកចិត្តទុកដាក់បន្ថែមទៀត លើការពង្រឹងសមត្ថភាពរបស់មន្ត្រីជំនាញ រួមទាំងម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលា។ ជាក់ស្តែងក្នុងឆ្នាំ២០២៤ កន្លងមក អនុវត្តបានចំនួន ៤៥ លើក ដែលមានអ្នកចូលរួមប្រមាណ ៥.០៨០នាក់។ ខ្លឹមសារសំខាន់បានផ្តោតលើការពង្រឹងគុណភាពសុវត្ថិភាពផលិតផលរបស់រោងចក្រ សហគ្រាស និងសិប្បកម្មផលិត និងកែច្នៃម្ហូបអាហារ និងភេសជ្ជៈ ការជំរុញតួនាទីស្ត្រីជាសហគ្រិន ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់សហគ្រាសធុនតូច និងមធ្យម ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា អត្ថប្រយោជន៍នៃការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ការចុះបញ្ជីរោងចក្រ សហគ្រាស និងសិប្បកម្មតាមប្រព័ន្ធអនឡាញ ការប្រើប្រាស់សេវាក្រោមដំបូលតែមួយ និងការតភ្ជាប់សហគ្រាសក្នុងស្រុកជាមួយក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស។

២.៤. ការងារសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

• ការងារសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

» ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា - ក្រុមការងារ "គ" និងស្ថាប័នឯកជនពាក់ព័ន្ធ

ក្នុងឆ្នាំ២០២៤ កន្លងមក ក្រសួងបានរៀបចំកិច្ចប្រជុំដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈម និងសំណូមពរនានារបស់វិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមការងារ "គ" ផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា សមាគមពាក់ព័ន្ធ តំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ សរុបចំនួន ២៥៥នាក់។ កិច្ចប្រជុំបានបង្ហាញពីគោលនយោបាយការគាំទ្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងផ្ទាល់របស់ក្រសួងឧ.វ.ប.ន. ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការចូលរួមលើកកម្ពស់ការអភិវឌ្ឍវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម និងរបាយការណ៍លទ្ធផលការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា ព្រមទាំងបានលើកយកបញ្ហាប្រឈមចំនួន២២ និងសំណូមពរចំនួន ៣៦ មកពិនិត្យ។ ជាលទ្ធផល វិស័យឯកជនបានឯកភាព និងទទួលយកដំណោះស្រាយដែលបានលើកឡើងក្នុងកិច្ចប្រជុំ និងពុំមានបញ្ហាប្រឈម និងសំណូមពរដែលនៅសេសសល់ សម្រាប់ដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនោះទេ។

» បានផ្សព្វផ្សាយ និងណែនាំផ្នែកឯកជន ឱ្យធ្វើការច្នៃប្រឌិត និងបង្កើតម៉ាស៊ីនខ្នាតតូចដើម្បីផលិតចំណិតដំឡូងមី ម៉ាស៊ីនសម្ងួតខ្នាតតូច នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង

បន្ទាយមានជ័យ កំពង់ចាម និងខេត្តត្បូងឃ្មុំ
- បានបណ្តុះបណ្តាលដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ទៅលើបច្ចេកទេសឡសម្ងួត និងឡចំហាយ និងការបង្កើនផលិតភាព សំដៅកាត់បន្ថយថ្លៃដើមផលិតកម្ម។
- បានចូលរួមអនុវត្ត និងត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិ ស្តីពី ស្វាយចន្ទី២០២២-២០២៧ ដោយបានធ្វើការសម្របសម្រួលដល់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តផែនការសកម្មភាពដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់ក្រសួង។ ក្នុងចំណោម ៤២ ផែនការសកម្មភាព ក្រសួងបានដឹកនាំ ៥សកម្មភាព និងចូលរួម ៤ សកម្មភាព។

• ការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

- ក្នុងឆ្នាំ២០២៤ ក្រសួងបានសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាង និងជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនទៀត ដូចជា៖ គម្រោងអភិវឌ្ឍន៍អាហារកម្ពុជារបស់រដ្ឋាភិបាលកូរ៉េ (FTC), GIZ, UNIDO, UN-ESCAP, CAPRED, Korea Development Institute, GGGI, ACCMSME & GIZ, ACCMSME, UNDESA, The ASIA Foundation, JICA and SWISS Contact ដើម្បីអនុវត្តការងារមួយចំនួន ពិសេសដូចជាការងារគ្រប់គ្រង និងជំរុញការងារអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដោយទទួលបានលទ្ធផលជាវិជ្ជមាន។
- បានសហការជាមួយដៃគូអភិវឌ្ឍន៍ លើការកំណត់ជំនាញ ឯកទេស និងសហការបណ្តុះបណ្តាល ស្តីពីការកែច្នៃផលិតផលម្ហូបអាហារ (ក្នុងនោះមានការកែច្នៃដំឡូងមីផងដែរ) បានចំនួន ២ខេត្តគោលដៅគឺខេត្តសៀមរាប និងខេត្តបាត់ដំបង។

២.៥. ការងារត្រួតពិនិត្យអនុលោមភាព និងពិគ្រោះយោបល់

ក) ការងារពិគ្រោះយោបល់

- បានពិគ្រោះយោបល់ជាមួយអតិថិជនលើការងារសហគ្រាសធុនតូច និងមធ្យម នៅច្រកចេញចូលតែមួយមានចំនួន ២៦នាក់ និងនៅតាមប្រព័ន្ធ CamDX មានចំនួន ៦២នាក់
- ពិគ្រោះយោបល់ដល់ម្ចាស់សហគ្រាស និងសិប្បកម្មចំនួន ១០២នាក់ (ដាក់ពាក្យផ្ទាល់ ៧៥នាក់ និង២៧នាក់ ដាក់ពាក្យតាមប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX និងប្រព័ន្ធផ្តល់សេវាសាធារណៈឌីជីថល តាមច្រកចេញចូលតែមួយរបស់ក្រសួង) លើការស្នើសុំប្រកាសបង្កើតសិប្បកម្ម វិញ្ញាបនបត្រអនុញ្ញាត ដំណើរការសិប្បកម្ម បន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្ម បន្ថែមមុខផលិតផល និងស្នើសុំផ្ទេរសិទ្ធគ្រប់គ្រងសិប្បកម្ម

សិក្ខាសាលាពិគ្រោះយោបល់ស្តីពីតម្រូវការជំនាញរបស់សហគ្រិនក្នុងបរិបទឧស្សាហកម្ម៤.០

» បានពិគ្រោះយោបល់ក្នុងការផ្តល់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពចំនួន ៦២មុខផលិតផល ជូនដល់ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម
» បានចេញវិញ្ញាបនបត្រ ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព ចំនួន ១២មុខផលិតផល។

ខ) ការងារត្រួតពិនិត្យអនុលោមភាព

» បានចុះពិនិត្យទីតាំងសហគ្រាស សិប្បកម្ម ដែលមានហានិភ័យខ្ពស់បានចំនួន ៦មូលដ្ឋាន នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម និងខេត្តកំពង់ធំ
» បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តមុខងារនៃការធ្វើប្រតិភូកម្មអំណាចចេញសេចក្តីសម្រេចបង្កើត និងវិញ្ញាបនបត្រដំណើរការសហគ្រាសរបស់មន្ទីរឧ.វ.ប.ន នៅខេត្តកំពង់ចាម តាកែវ កែប កំពត ព្រៃវែង ស្វាយរៀង សៀមរាប ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តរតនគិរី និងនៅថ្នាក់ក្រោមជាតិ សរុបបានចំនួន ១៥ រាជធានី-ខេត្ត
» ចូលរួមជាមួយក្រុមការងារអន្តរក្រសួង និងបានចុះធ្វើអធិការកិច្ចពិនិត្យរោងចក្របាន សរុបចំនួន ១៦៥ រោងចក្រ។

២.៦ ការងារស្រែអំបិល

» ក្នុងឆ្នាំ២០២៤ ទិន្នផលអំបិល សរុបមានចំនួន ១៦៨.៨៨២ តោន លើផ្ទៃដីស្រែអំបិល ចំនួន ៣.៩៨៧,៣៥ហិកតា (កំពត ៣.៤៨៩,៤៨ហិកតា កែប ៤៩៧,៨៧ហិកតា) និងមានក្រុមផលិតចំនួន ១៩១ក្រុម ក្នុងនោះ ខេត្តកំពតផលិតបាន ១២៨.៤៧៤តោន និងខេត្តកែបផលិតបាន ៤០.៤០៨តោន។ ការលក់ចេញបាន ៧៤.១៨៥តោន និងមានសិប្បកម្មចំនួន ៣២មូលដ្ឋាន ក្នុងចំណោម ៥៤មូលដ្ឋាន ដែលទទួលបានអាជ្ញាបណ្ណប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលអ៊ីយ៉ូដ។ ក្នុងឆ្នាំ២០២៤ កន្លងមកនេះ ពុំមានការនាំចូលអំបិលពីបរទេសទេ
» បានរៀបចំកិច្ចប្រជុំជាមួយផលិតករអំបិល និងសហគ្រាសមានសក្តានុពលនៅក្នុងខេត្តកំពត ខេត្តកែប ដើម្បីដោះស្រាយបញ្ហាប្រឈម និងការចុះពិនិត្យផ្ទៃដីស្រែអំបិល និងផលិតកម្មអំបិល
» បានរៀបចំលិខិតទៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសម្របសម្រួលក្នុងការធ្វើបច្ចុប្បន្នភាព និងកំណត់អត្តសញ្ញាណប្រភេទដីស្រែអំបិលនៅខេត្តកំពត និងខេត្តកែបឱ្យបានច្បាស់លាស់
» បានដាក់បញ្ចូលអាជ្ញាបណ្ណប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិល ដែលបានបញ្ចូលជាតិអ៊ីយ៉ូដ ទៅក្នុងកម្រងកម្រៃសេវាសាធារណៈរបស់ក្រសួង។

ផ្ទៃដីស្រែអំបិល (គិតជាហិកតា)

ល.រ	ខេត្ត/មណ្ឌល	ស្រែហាល	ស្រែបណ្ដុះ	អូទឹក	សរុប	សមត្ថភាព (តោន/ឆ្នាំ)	ចំនួនក្រុម
1	បឹងរូង១	604.79	88.80	75.99	769.58	15,391.60	32
2	បឹងរូង២	406.62	78.87	159.69	645.18	12,903.60	31
3	បឹងទូក	201.00	21.15	55.72	277.87	5,557.40	7
4	ត្រើយកោះ	532.79	90.63	384.53	1,007.95	20,159.00	77
5	សេះស	275.86	31.26	76.97	384.09	7,681.80	15
6	កំពង់ត្រាច	214.49	23.90	166.42	404.81	8,096.20	9
សរុបខេត្តកំពត		2,235.55	334.61	919.32	3,489.48	69,789.60	171
7	ខេត្តកែប				497.87	9,957.40	20
សរុបរួម		2,235.55	334.61	919.32	3,987.35	79,747.00	191

ទិន្នន័យនៃការផលិតអំបិលសម្រាប់ឆ្នាំ២០២៤ (គិតជាតោន) គិតត្រឹមឆ្នាំ២០២៤

ល.រ	ខេត្ត	ផ្ទៃដីផលិត (H)	ទិន្នផលផលិតប្រចាំខែ						សរុប	លក់ចេញ	សល់ (ស្តុក)
			មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា & កក្កដា			
1	កំពត	2,640.98	11,226.0	12,161.0	23,290.0	10,476.0	28,183.0	43,138.0	128,474.0	70,734.0	57,740.0
2	កែប	351.50	230.0	3,509.6	2,765.4	30,793.0	1,965.0	1,145.0	40,408.0	3,451.0	36,957.0
សរុប		2,992.48	11,456.0	15,670.6	26,055.4	41,269.0	30,148.0	44,283.0	168,882.0	74,185.0	94,697.0

ក្រាហ្វិកនៃការផលិតអំបិលប្រចាំឆ្នាំ២០២៤ (គិតជាតោន) គិតត្រឹមឆ្នាំ២០២៤



៣. ការងារស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម

ក្រសួងបានលើកកម្ពស់ការងារស្តង់ដា, បទប្បញ្ញត្តិបច្ចេកទេស និងការវាយតម្លៃភាពអនុលោម ដើម្បីចូលរួមគាំទ្រក្នុងការអភិវឌ្ឍវិស័យ ឧ.វ.ប.ន និងវិស័យពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព និងរីកចម្រើន ជាពិសេសគាំទ្រដល់ការជំរុញការធ្វើពាណិជ្ជកម្មកម្ពុជានៅក្នុងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ។ ក្នុងឆ្នាំ២០២៤ កន្លងមក ក្រសួងឧ.វ.ប.ន បានសម្រេចជាសកម្មភាព និងលទ្ធផលដូចខាងក្រោម៖

៣.១. ការងារព័ត៌មាន

ការរៀបចំបទប្បញ្ញត្តិបច្ចេកទេសត្រូវបានផ្តោតលើផលិតផលដែលមានហានិភ័យខ្ពស់ ដើម្បីការពារសុវត្ថិភាព និងសុខុមាលភាពអ្នកប្រើប្រាស់ សុខភាពអ្នកបរិភោគ បរិស្ថាន សន្តិសុខ និងសុវត្ថិភាពសង្គម និងបានធ្វើជាបន្តបន្ទាប់ ដែលក្នុងនោះរួមមាន៖ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក ចំនួន ១១៩ មុខទំនិញ, ផលិតផល និងគ្រឿងបន្លាស់យានយន្តចំនួន ២០ មុខទំនិញ, ផលិតផលម្ហូបអាហារចំនួន ៩ មុខទំនិញ, ផលិតផល និងសម្ភារសំណង់ចំនួន ១ មុខទំនិញ។

ក្នុងក្របខណ្ឌ របាំងបច្ចេកទេសពាណិជ្ជកម្ម ដែលជាកាតព្វកិច្ចរបស់ប្រទេសជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាបាន ផ្សព្វផ្សាយ, ជូនដំណឹង ឆ្លើយតបអំពីសកម្មភាពស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងវាយតម្លៃភាពអនុលោម ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ផ្សព្វផ្សាយសេចក្តីជូនដំណឹង (Notification) របស់ប្រទេសជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកចំនួន ៤.០៧៩ សេចក្តីជូនដំណឹងដែលគ្របដណ្តប់លើផលិតផលម្ហូបអាហារ អេឡិចត្រូនិក និងផលិតផលពាក់ព័ន្ធផ្សេងទៀត ទៅស្ថាប័នសាធារណៈ និងឯកជន ដើម្បីធ្វើការផ្តល់មតិយោបល់ និងត្រៀមរៀបចំខ្លួនក្នុងការអនុវត្ត
- ឆ្លើយតបទៅនឹងសំណួរ-ចម្ងល់របស់សាធារណជនទាំងក្នុង និងក្រៅប្រទេសអំពីព័ត៌មានទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម រួមមាន៖ ការរៀបចំស្តង់ដា, បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ដើម្បីបំភ្លឺអំពីគោលការណ៍ ឬលក្ខខណ្ឌនៃការរៀបចំកិច្ចការទាំងនេះ។

៣.២. ការងារអភិវឌ្ឍន៍ស្តង់ដា

ការងារអភិវឌ្ឍន៍ស្តង់ដា ជាកិច្ចការមួយដ៏សំខាន់សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើននូវប្រសិទ្ធភាពផលិតកម្ម គុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម និងប្រើប្រាស់ជាឧបករណ៍ស្នូលសម្រាប់សម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មទំនិញ និងផលិតផលទាំងនៅក្នុង និងក្រៅប្រទេស ជាពិសេសរួមចំណែកក្នុងការការពារសុខភាព សុវត្ថិភាពសាធារណៈ និងកាត់បន្ថយផលប៉ះពាល់ចំពោះបរិស្ថាន ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍឧស្សាហកម្ម ជំនាន់ថ្មី។ ក្នុងឆ្នាំ២០២៤ ដំណើរការរៀបចំ និងការអនុវត្តការងារស្តង់ដា សម្រេចបានលទ្ធផលដូចខាងក្រោម៖

» ចំនួនស្តង់ដាបង្កើតថ្មី និងកែសម្រួលស្តង់ដាចាស់ មានចំនួន ១.១៣២ ស្តង់ដា
» បានពង្រីកវិសាលភាពនៃការធ្វើតេស្តវិភាគចំនួន ៩.៦០៧ សំណាកផលិតផល
» បានបង្កើតឧបករណ៍ចំនួន ៤, បោះពុម្ពរបាយការណ៍ស្រាវជ្រាវបានចំនួន ៣ និងបោះពុម្ពកាលិកបត្របានចំនួន ៦
» បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់រៀបចំសេចក្តីព្រាងស្តង់ដាស្រា បំណិតអង្ករចំនួន ១លើក និង សម្រាប់រៀបចំកែសម្រួលស្តង់ដាទឹកត្រី និងទឹកស៊ីអ៊ីវចំនួន ២លើក
» បានរៀបចំកិច្ចប្រជុំគណៈកម្មការបច្ចេកទេសចំនួន ២០លើក ដើម្បីពិភាក្សាលើសេចក្តីព្រាងស្តង់ដាផ្នែកសារធាតុ និងផលិតផលគីមី ផ្នែកប្រព័ន្ធគ្រប់គ្រង ផ្នែកផលិតផលអគ្គីសនី និងអេឡិចត្រូនិក ផ្នែកផលិតផលកៅស៊ូ ផ្នែកផលិតផលយានយន្ត ផ្នែកផលិតផលគ្រឿងសម្អាង ផ្នែកផលិតផលពីឈើ ផ្នែកឱជីជីថល និងផ្នែកវាយនភ័ណ្ឌ
» បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដាជាតិចំនួន ៣លើក និងបានអនុម័តសេចក្តីព្រាងស្តង់ដាថ្មីចំនួន ៥៥ និងស្តង់ដាកែសម្រួលចំនួន ៣ ជាស្តង់ដាជាតិ ក្នុងនោះមានស្តង់ដាស្រាអង្ករ, ក្រមអនុវត្តល្អសម្រាប់ផលិតកម្មស្រាអង្ករ, ស្តង់ដាអន្តរជាតិ ISO ចំនួន ៣៩ និងស្តង់ដាកែសម្រួលចំនួន ១ ស្តង់ដាអន្តរជាតិ IEC ចំនួន ៤, ស្តង់ដាអន្តរជាតិ ISO/IEC ចំនួន៣, ស្តង់ដាអន្តរជាតិកូដិចចំនួន ២ ស្តង់ដា, ស្តង់ដា UNECE ចំនួន ៥ស្តង់ដា និងស្តង់ដាកែសម្រួលសម្រាប់ផលិតផលទឹកត្រី និងទឹកស៊ីអ៊ីវ។
» គិតត្រឹមដំណាច់ឆ្នាំ២០២៤ ស្តង់ដាកម្ពុជាមានសរុបចំនួន ១.១៣២ ស្តង់ដា។

លទ្ធផលនៃការអភិវឌ្ឍស្តង់ដាកម្ពុជាត្រឹមឆ្នាំ២០២៤

ល.រ	ស្តង់ដា	មុនឆ្នាំ ២០២០	២០២០	២០២១	២០២២	២០២៣	២០២៤	សរុប
		Std	Std	Std	Std	Std	Std	
1	ម្ហូបអាហារ	371	7	4	4	-	3	389
2	អគ្គិសនី និងអេឡិចត្រូនិក	193	5	8	7	8	4	225
3	វិធីសាស្ត្រធ្វើតេស្ត	172	-	-	-	-	-	172
4	សារធាតុគីមី	17	-	6	6	2	4	35
5	សំណង់	28	-	3	-	-	7	38
6	ផលិតផលយានយន្ត	21	-	2	14	8	10	55
7	ផលិតផលកៅស៊ូ	51	-	3	3	1	4	62
8	ផលិតផលពីឈើ	57	-	-	3	3	3	66
9	ក្រុមអនុវត្ត	8	-	-	-	-	1	9
10	ស្តង់ដាវាក្យស័ព្ទ	1	-	-	-	-	-	1
11	ប្រព័ន្ធគ្រប់គ្រង	7	11	6	6	4	10	44
12	ឌីជីថល	-	-	5	6	6	3	20
13	គ្រឿងសំអាង	-	-	2	4	2	4	12
14	វាយនភណ្ឌ	-	-	-	2	-	2	4
	សរុប	926	23	39	55	34	55	1132

*សម្គាល់៖ ក្នុងចំណោមស្តង់ដាកម្ពុជាសរុប ១.១៣២ ស្តង់ដា បានពិនិត្យឡើងវិញចំនួន ៨ ស្តង់ដា។

សសរក្រាហ្វិកចំនួនស្តង់ដាកម្ពុជាត្រឹមឆ្នាំ២០២៤



៣.៣. ការងារវិញ្ញាបនបត្រកម្ម

ការងារវិញ្ញាបនបត្រកម្ម បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីបញ្ជាក់ពីភាពអនុលោមរបស់ផលិតផលផលិតកម្ម និងសេវាកម្ម និងការសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្ម ការផ្តល់ភាពជឿជាក់ដល់អ្នកប្រើប្រាស់ទៅលើគុណភាព និងសុវត្ថិភាពរបស់ផលិតផលដែលត្រូវអនុវត្តក្រោមកិច្ចព្រមព្រៀងពាណិជកម្មសេរី ឬកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត តាមរយៈការចេញវិញ្ញាបនបត្រដើម្បីបញ្ជាក់ពីភាពអនុលោមរបស់ផលិតផល ប្រព័ន្ធគ្រប់គ្រងផលិតកម្ម និងប្រព័ន្ធគ្រប់គ្រងសេវាកម្ម ទៅនឹងការតម្រូវនៃស្តង់ដាកម្ពុជាដែលបានកំណត់ ដោយបានអនុវត្ត និងសម្រេចបានក្នុងឆ្នាំ២០២៤ កន្លងមក ដូចខាងក្រោម៖

ក. ការងារវិញ្ញាបនបត្រកម្មផលិតផល៖ (ចេញវិញ្ញាបនបត្រសរុប ២២៤ និងអាជ្ញាបណ្ណសរុប ១០៩)៖

- បានចេញវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ដោយសេរីលើផលិតផលម្ហូបអាហារ និងគ្រឿងសម្អាង (Certificate of Free Sale) ចំនួន ២២ វិញ្ញាបនបត្រ
- បានចុះត្រួតពិនិត្យខ្សែច្រវាក់ផលិតកម្មចំនួន១២៧ មូលដ្ឋាន និងចុះយកគំរូសំណាកផលិតផលតាមកិច្ចព្រមព្រៀងបានចំនួន ១៤៨ គំរូសំណាក
- បានចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល ចំនួន ៩៧ វិញ្ញាបនបត្រ (កម្រិតបឋម ៤៨ និងបញ្ជាក់ភាពអនុលោមផលិតផល ៤៩) សម្រាប់ផលិតផលម្ហូបអាហារ
- បានចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម (Certificate of Conformity-CoC) ចំនួន ១០៥ វិញ្ញាបនបត្រ សម្រាប់ផលិតផលអគ្គិសនី និងអេឡិចត្រូនិក, ផលិតផលយានយន្ត និងសម្ភារសំណង់
- បានចេញអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផល ចំនួន ១០៩ អាជ្ញាបណ្ណ។

ខ. ការងារវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ៖ (ចេញវិញ្ញាបនបត្រ សរុប ២៣)៖

- បានចុះធ្វើសវនកម្ម និងចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធចំនួន ១៦ វិញ្ញាបនបត្រ ដើម្បីបញ្ជាក់ប្រព័ន្ធផលិតកម្មអនុលោមទៅតាម ការតម្រូវនៃស្តង់ដាប្រព័ន្ធផ្នែកអនុវត្តផលិតកម្មល្អ (Good Manufacturing Practice-GMP) ចំនួន០៤, ស្តង់ដាប្រព័ន្ធផ្នែកវិភាគភាពគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យចាំបាច់ (Hazard Analysis and Critical Control Point- HACCP)ចំនួន០៤, ស្តង់ដាប្រព័ន្ធគ្រប់គ្រងគុណភាព(ISO 9001:2015) ចំនួន០៥, ស្តង់ដាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ(ISO 22000: 2018) ចំនួន០១ និងស្តង់ដាប្រព័ន្ធគ្រប់គ្រងអនាម័យ (GHP) ចំនួន ២

» បានចុះធ្វើសវនកម្មអង្កេតតាមដានក្រុមហ៊ុន រោងចក្រ ចំនួន ១២លើក ដើម្បីផ្ទៀងផ្ទាត់អំពីការបន្តការអនុវត្ត ស្តង់ដាប្រព័ន្ធផ្នែកអនុវត្តផលិតកម្មល្អ (GMP)ចំនួន ២ ស្តង់ដាប្រព័ន្ធផ្នែកវិភាគភាពគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យចាំបាច់ (HACCP), ស្តង់ដាប្រព័ន្ធគ្រប់គ្រងគុណភាព (ISO 9001:2015) ចំនួន ៣ និងវិញ្ញាបនបត្របញ្ជាក់អនាម័យចំនួន ៦

» បានចុះវាយតម្លៃផ្ទៀងផ្ទាត់ និងចេញវិញ្ញាបនបត្រអនាម័យចំនួន ០៧ វិញ្ញាបនបត្រជូនដល់ផលិតកម្មម្ហូបអាហារ ក្នុងនោះមានវិញ្ញាបនបត្រអនាម័យកម្រិតបឋមចំនួន ១ វិញ្ញាបនបត្រ។

៣.៤. ការងារបញ្ញត្តកម្ម

ការផ្តល់សេវាអាជ្ញាបណ្ណចុះបញ្ជីផលិតផល និងអាជ្ញាបណ្ណចុះបញ្ជីសុវត្ថិភាពផលិតផល និងអាជ្ញាបណ្ណបញ្ជាក់មុខសញ្ញា និងស្តង់ដាប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ត្រូវបានធ្វើទៅតាមនីតិវិធីច្បាស់លាស់ និងមានតម្លាភាពសម្រាប់ផលិតផលផលិតក្នុងស្រុកក៏ដូចជាផលិតផលនាំចូលពីក្រៅប្រទេសផងដែរ។ ក្នុងឆ្នាំ២០២៤ កន្លងមក ទទួលបានលទ្ធផលដូចខាងក្រោម៖

» ចេញអាជ្ញាបណ្ណសរុបចំនួន ៤.៣៣៧ អាជ្ញាបណ្ណ ក្នុងនោះមានអាជ្ញាបណ្ណបញ្ជាក់មុខសញ្ញា និងស្តង់ដាប្រើប្រាស់សារធាតុគីមីចំនួន ៧០៣, អាជ្ញាបណ្ណប្រើប្រាស់ និងចែកចាយសារធាតុគីមីជាប់បញ្ញត្តិចំនួន ៣១៩ អាជ្ញាបណ្ណ ចុះបញ្ជីផលិតផល (ចបផ) ចំនួន ២.០៥២ អាជ្ញាបណ្ណបញ្ជាក់សុវត្ថិភាពផលិតផលអគ្គិសនី និងអេឡិចត្រូនិកចំនួន ៩១៨ អាជ្ញាបណ្ណបញ្ជាក់សុវត្ថិភាពផលិតផលយានយន្តចំនួន ៦៤ និងអាជ្ញាបណ្ណបញ្ជាក់សុវត្ថិភាពទោចក្រ និងត្រីចក្រយានយន្ត(ម៉ូតូ)ចំនួន ៣

» ចេញលិខិតបញ្ជាក់ការផ្លាស់ប្តូរផ្នែកណាមួយ នៃផលិតផលយានយន្តចំនួន ៤៨លិខិត

» បានចេញលិខិតកែតម្រូវការផ្លាស់ប្តូរផ្នែកណាមួយ នៃផលិតផលអគ្គិសនី និងអេឡិច-ត្រូនិកចំនួន ២៥ លិខិត

» ចេញលិខិតចុះបញ្ជីកា និងទិដ្ឋាការសម្រាប់ទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធចំនួន ៥ ទិដ្ឋាការ

» ចុះអធិការកិច្ចលើក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម ដើម្បីជំរុញការអនុវត្តច្បាប់បទប្បញ្ញត្តិបច្ចេកទេស និងការអនុលោមស្តង់ដា បានចំនួន ៣៣៦ មូលដ្ឋាន។

» បានចុះត្រួតពិនិត្យសារធាតុគីមី ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកកម្ម ចំនួន ៦៥ មូលដ្ឋាន។

៣.៥. ការងារពង្រឹងសមត្ថភាព

ការពង្រឹងសមត្ថភាពធនធានមនុស្ស គឺជាកិច្ចការចាំបាច់មួយដែលក្រសួងត្រូវអនុវត្ត ឱ្យស្របទៅនឹងទិសដៅជាយុទ្ធសាស្ត្រនៃគោលយោបាយបញ្ចកោណរបស់រាជរដ្ឋាភិបាល ដោយក្នុងនោះបានចាត់មន្ត្រីបច្ចេកទេស និងជំនាញ ចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងធ្វើជាវាគ្មិន ទៅតាមបរិបទ ដូចខាងក្រោម៖

» បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេសជាសិក្ខាកាម និងជាវាគ្មិន ដែលបានរៀបចំឡើងដោយអង្គភាព និងស្ថាប័នរដ្ឋពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល បានចំនួន ៤៥ លើក (ដោយផ្ទាល់ចំនួន ២១ លើក និងតាមប្រព័ន្ធអនឡាញចំនួន ២៤លើក)ទៅលើប្រធានបទពាក់ព័ន្ធក្នុងវិស័យបច្ចេកវិទ្យាម្ហូបអាហារវិស័យ សំណង់ និងកិច្ចការស្តង់ដារូបនីយកម្ម ការអនុវត្តកម្មវិធីថវិការបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញ។ល។

» បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្រៅប្រទេសបានចំនួន ១០លើក លើការអនុវត្តស្តង់ដារូបនីយកម្មល្អ ការគ្រប់គ្រងគម្រោង និងការជំរុញភាគីពាក់ព័ន្ធ 2024 AKSCN WGs និងការអភិវឌ្ឍ ACCSQ Sectoral Plan 2026-2030។ល។

៣.៦. ការងារកិច្ចសហប្រតិបត្តិការ

នៅក្នុងទិសដៅចូលរួមគាំទ្រដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងទិសដៅពង្រីកការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន អាស៊ាន និងប្រទេសជាដៃគូអាស៊ាន និងការរៀបចំការធ្វើពាណិជ្ជកម្មទ្វេភាគី នៅក្នុងវិសាលភាពនៃការធ្វើសុខដុមនីយកម្មស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម និងកិច្ចព្រមព្រៀង និងកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទៅតាមផ្នែកអាទិភាព, ក្រសួងបានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយបានទទួលលទ្ធផលទៅតាមចំណុចនីមួយៗ ដូចខាងក្រោម៖

ក. ការងារកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន៖

នៅក្នុងសកម្មភាពការងារសម្របសម្រួលការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ក្នុងវិសាលភាពធ្វើសុខុដុមនីយកម្មស្តង់ដា, បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោមអាស៊ាន តាមរយៈការធ្វើជាប្រធានអង្គប្រជុំ និងចូលរួមជាសមាជិកអង្គប្រជុំ ដោយបានផ្តល់លទ្ធផលទៅតាមវិស័យនីមួយៗ ដូចខាងក្រោម៖

- បានអនុម័តស្តង់ដាសុខដុមនីយកម្មអាស៊ាន (ASEAN Harmonized Standards) ចំនួន ៥៣ ស្តង់ដា ក្នុងនោះមានស្តង់ដាផ្នែកទំនិញចំបង (Essential goods) ចំនួន ១ស្តង់ដា, ស្តង់ដាផ្នែកឧបករណ៍អគ្គិសនី និងអេឡិចត្រូនិកចំនួន ២០ស្តង់ដា, ស្តង់ដាផ្នែកបរិក្ខារពេទ្យចំនួន៣ស្តង់ដា, ស្តង់ដាផលិតផលកៅស៊ូចំនួន ៥ស្តង់ដា, ស្តង់ដាគ្រឿងសម្អាងចំនួន ៣ស្តង់ដា, ស្តង់ដាផលិតផលពីឈើចំនួន ៤១ស្តង់ដា, ស្តង់ដាផ្នែកសម្ភារសំណង់ និងការសាងសង់ចំនួន ១៧ស្តង់ដា, ស្តង់ដាផ្នែក CASCO ចំនួន ៣២ស្តង់ដា, ស្តង់ដាផ្នែក Green House Gas ចំនួន ៦ស្តង់ដា, ស្តង់ដាផ្នែកឌីជីថលចំនួន ១១ស្តង់ដា និងស្តង់ដា Smart manufacturing ចំនួន ៧ស្តង់ដា។
- បានរៀបចំកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក នៅក្នុងក្របខណ្ឌទីផ្សារអាស៊ាន ត្រូវបានពិនិត្យ និង ពិភាក្សាយ៉ាងល្អិតល្អន់ទៅតាមវិស័យអាទិភាព និងយកចិត្តទុកដាក់បំផុតដោយរក្សានូវគោលជំហរ ផ្តល់ផលប្រយោជន៍ទៅវិញទៅមក រវាងបណ្តាប្រទេសអាស៊ានជាសមាជិក ដែលរហូតមកដល់ពេលនេះ សម្រេចបាន៖
  - » កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក សម្រាប់ផលិតផលម្ហូបអាហារដែលបានវេចខ្ចប់ជាមុន
  - » កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក សម្រាប់ផលិតផលអគ្គិសនី និងអេឡិចត្រូនិក
  - » កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក សម្រាប់ផលិតផលយានយន្ត
  - » កិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក សម្រាប់ផលិតផលសំណង់ និងសម្ភារសាងសង់
  - » កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន
  - » កិច្ចព្រមព្រៀងដៃគូពាណិជ្ជកម្មអាស៊ាន។

ខ. ការងារកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និងប្រទេសដៃគូអាស៊ាន៖

- ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងកូរ៉េ ក្នុងជំពូកទី៦ ផ្នែកស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម៖ ភាគីទាំងពីរបានពិភាក្សាគ្នាអំពីវិស័យដែលត្រូវធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីជៀសវាងការជាន់គ្នាជាមួយក្រុមការងារ AKSCN ហើយក្រុមការងារ ROK បានស្នើសុំធ្វើចំណាត់ថ្នាក់វិស័យ ដែលក្រុមការងារ AKFTA WG-TBT មានចំណាប់អារម្មណ៍ និងស្នើសុំឱ្យរដ្ឋជាសមាជិកផ្តល់មតិយោបល់
- ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងចិន៖ ភាគីទាំងពីរបានបញ្ចប់កិច្ចព្រមព្រៀងជំឡើងកម្រិត ៣.0
- ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងឥណ្ឌា៖ ភាគីទាំងពីរបានព្រមព្រៀង

កែសម្រួលជំពូកទី៦ ផ្នែកស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ដោយក្នុងនោះភាគីទាំងពីរបានឯកភាពកែសម្រួលបានចំនួន៥ មាត្រានៅក្នុងចំណោម ១៤ មាត្រា

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងកាណាដា៖ ភាគីទាំងពីរបាននិងកំពុងពិភាក្សាផ្នែកស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម និងបានឯកភាពបានចំនួន២ មាត្រានៅក្នុងចំណោម ១៤ មាត្រា
- បានចូលរួមការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់អាស៊ានក្រោមបរិបទស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម បានពិភាក្សាយ៉ាងល្អិតល្អន់ដោយផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិជាគោល និងរក្សាគោលជំហរផលប្រយោជន៍ រួមរបស់អាស៊ាន និងកំពុងបន្តពិនិត្យទៅលើការអនុវត្ត រួមមាន៖

  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងចិន
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងហុងកុង
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងកូរ៉េ
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងជប៉ុន
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងអូស្ត្រាលី និងញ៉ូវហ្សេឡែន
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងកាណាដា
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន និងឥណ្ឌា។

គ. ការងារកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌកិច្ចព្រមព្រៀងទ្វេភាគី៖

- បានចុះហត្ថលេខាកិច្ចព្រមព្រៀងសំខាន់មួយស្តីពីកិច្ចសហប្រតិបត្តិការនៃភេសជ្ជៈមានជាតិអាល់កុលតាមបែបប្រពៃណី ស្តង់ដា និងបទប្បញ្ញត្តិបច្ចេកទេស ជាមួយស្ថាប័នសិក្សាស្រាវជ្រាវជាតិផ្នែកចំណីអាហារ និងឧស្សាហកម្ម(CNRIFFI)។
- បានរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជាក្រោមបរិបទស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម នាពេលកន្លងមក និងកំពុងបន្តពិភាក្សាទៅលើទិដ្ឋភាព និងដំណើរការនៃការអនុវត្តកិច្ចព្រមព្រៀងទាំងនេះ រួមមាន៖កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងចិន

  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងចិន
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងកូរ៉េ
  » កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងអេមេរ៉ាតអារ៉ាប់រួម។

ក្រាហ្វិកស្ដីពីលទ្ធផលការងារ ៥ឆ្នាំ (២០២០-២០២៤) របស់វិទ្យាស្ថានស្តង់ដារកម្ពុជា



	ស្តង់ដារកម្ពុជា	វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ	វិញ្ញាបនបត្រផលិតផល	អាជ្ញាបណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល	អាជ្ញាបណ្ណបញ្ជាក់មុខសញ្ញាសារធាតុគីមី	អាជ្ញាបណ្ណគីមីជាប់បញ្ញត្តិ	អាជ្ញាបណ្ណ ចផប	អាជ្ញាបណ្ណប្រើសញ្ញាសុវត្ថិភាព	ទិដ្ឋាការ
2020	23	6	96	95	598	132	1102	1029	11
2021	39	9	105	63	607	232	952	874	4
2022	55	17	115	60	557	360	1174	976	11
2023	34	11	156	85	623	312	1216	913	20
2024	36	23	224	109	703	319	2052	985	5

៤. ការងារមាត្រាសាស្ត្រ

វិស័យមាត្រាសាស្ត្របានដើរតួនាទីយ៉ាងសំខាន់ ក្នុងជីវភាពរស់នៅរបស់យើងជាអាទិ៍ ការជួយគាំទ្រសុខុមាលភាពរបស់សង្គម និងទំនើបកម្ម ដោយគាំទ្រលើផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម សុខភាព សុវត្ថិភាព បរិស្ថាន និងសេវាកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងបទបញ្ជាបច្ចេកទេស ដែលក្នុងនោះមាន៖

៤.១. ការផ្តល់សេវាសាធារណៈ

» បានធ្វើព្យាសកម្មឧបករណ៍មាត្រាសាស្ត្រសរុបចំនួន ១.០៩៧គ្រឿង រួមមាន៖ ១) ក្រុមហ៊ុន, រោងចក្រ, សហគ្រាស ចំនួន ៧៦៣គ្រឿង (១៧៤ ក្រុមហ៊ុន), ២) អង្គភាពចំណុះ ម.ម.ជ ចំនួន ១៥០គ្រឿង និង ៣) មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត ចំនួន ១៨៤គ្រឿង (១៤ខេត្ត)

» បានចេញវិញ្ញាបនបត្រព្យាសកម្មចំនួន ៧១០ច្បាប់

» បានចេញវិញ្ញាបនបត្រស្តង់ដាប្រតិបត្តិចំនួន ៦៣ច្បាប់

» បានផ្តល់វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រសរុបចំនួន ៦៥០មូលដ្ឋាន ក្នុងនោះ៖ ១)

វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រថ្មីចំនួន ២៧៦មូលដ្ឋាន និង២) វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្របន្តចំនួន ៣៧៤មូលដ្ឋាន និងបានផ្តល់អាជ្ញាបណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រសរុបចំនួន ៥មូលដ្ឋាន (អាជ្ញាបណ្ណថ្មី១ និងអាជ្ញាបណ្ណបន្ត៤) និងបានផ្តល់អាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាសរុបចំនួន ២មូលដ្ឋាន (អាជ្ញា ប័ណ្ណបន្ត) សរុបចំនួន ៦៥៧មូលដ្ឋាន

» បានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ និងទំនិញវេចខ្ចប់នាំចូលរួមមាន៖ ១) ស៊ីទែនរថយន្តចំនួន ២៩៤គ្រឿង, ២) ជញ្ជីងថ្លឹងរថយន្តចំនួន ៣៧០, ៣) ទំនិញវេចខ្ចប់នាំចូលបានចំនួន ២២មុខផលិតផល

» ការងារដែលក្រសួងបានប្រតិភូកម្មជូនមន្ទីររួមមាន៖ ១) ត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេង ចំនួន ៣៥.៨៣០ ដៃ ២) ត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងក្រោម ១.០០០ គីឡូក្រាម ចំនួន ២.២៦៨ជញ្ជីង ៣) ត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ចំនួន ១.០៤០ផលិតផល។

តារាង១៖ ការផ្តល់សេវាសាធារណៈព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ

ស្ថិតិធ្វើព្យាសកម្មឧបករណ៍មាត្រាសាស្ត្រតាមផ្នែក



ស្ថិតិជញ្ជីងក្រោមធ្វើព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ
ជូនមន្ទីរ ឧ.វ.ប.ន ខេត្ត និងអង្គភាពចំណុះ ម.ម.ជ ឆ្នាំ២០២៤



ការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងថ្លឹងរថយន្ត

ការត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេង និងជញ្ជីងក្រោម១០០គីឡូក្រាម



ការត្រួតពិនិត្យផ្ទៀងផ្ទាត់រថយន្តស៊ីទែន

កិច្ចប្រជុំត្រួតពិនិត្យការងារ

វគ្គបណ្តុះបណ្តាលត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់នាំចូល

ព្យាសកម្មកូនទម្ងន់

ព្យាសកម្មនាឡិកាសម្ពាធ

ទំនិញវេចខ្ចប់នាំចូល

ការផ្តល់សេវាសាធារណៈត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ



លទ្ធផលការងារដែលក្រសួងបាន ប្រតិភូកម្មជូនមន្ទីរ ២០២៤



ការផ្តល់សេវាសាធារណៈចុះបញ្ជីមាត្រាសាស្ត្រ

ទិន្នន័យចុះបញ្ជីមាត្រាសាស្ត្របែងចែកតាមប្រភេទ អាជីវកម្ម ប្រចាំឆ្នាំ២០២៤



ទិន្នន័យចុះបញ្ជីមាត្រាសាស្ត្របែងចែកតាម ប្រភេទអាជីវកម្ម រយៈពេល៤ឆ្នាំ ២០២២-នាំ២០២៤



ទិន្នន័យវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ តាមបណ្តារាជធានី-ខេត្ត ឆ្នាំ២០២៤



ទិន្នន័យការងារផ្តល់អាជ្ញាប័ណ្ណរយៈពេល៥ឆ្នាំ (២០២០-ឆ្នាំ២០២៤)



៤.២. ការងារផ្សព្វផ្សាយ និងកសាងលិខិតបទដ្ឋានគតិយុត្ត

» បានរៀបចំនីតិវិធីព្យាសកម្មឧបករណ៍អគ្គិសនី (Voltage Meter) និងនីតិវិធីព្យាសកម្មឧបករណ៍ផ្នែកពន្លឺ (Spectra Light)

» បានរៀបចំសេចក្តីណែនាំ ស្តីពីការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តអាជ្ញាបណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រលេខ ០០៣ ឧវបន.មមជ.សណន ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤។

៤.៣. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា

» បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ១៨លើក អ្នកចូលរួម ១.៤៨១ នាក់

» បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេសចំនួន ៣១លើក និងក្រៅប្រទេសចំនួន ១៤លើក ដែលមានអ្នកចូលរួមសរុប ១៥៧នាក់

» បានចូលរួមកិច្ចប្រជុំក្នុងប្រទេសចំនួន ១៣៥លើក ដែលមានអ្នកចូលរួមសរុប ៤៤០នាក់ និងបានទៅចូលរួមកិច្ចប្រជុំក្រៅប្រទេសចំនួន ៤លើកផងដែរ។

៤.៤. ការងារសហប្រតិបត្តិការ

» បានសហការជាមួយគម្រោង PTB អភិវឌ្ឍមន្ទីរពិសោធន៍ដើម្បីស្នើសុំវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍ ISO/ IEC17025:2017

» បានទទួលឧបករណ៍ស្តង់ដាមាត្រាសាស្ត្រ Infrared Thermometer Calibration Equipment ចំនួន ០៦ ប្រភេទ មានតម្លៃសរុប ២០៥.៧៦២ RMB ជាជំនួយឥតសំណងរបស់ NIM-China ប្រទេសចិន

» បានទទួលឧបករណ៍ស្តង់ដាមាត្រាសាស្ត្រ Testing Equipment for Electrical Vehicle Charging Station ចំនួន ០៦ ប្រភេទ មានតម្លៃសរុបចំនួន ២៩.៥៧៦ ដុល្លារអាមេរិក ជាជំនួយឥតសំណងរបស់ NIM-China ប្រទេសចិន

» បានរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីគម្រោងរៀបចំប្រព័ន្ធវង្វាស់វង្វាល់ថាមពលអគ្គិសនីយានយន្ត នៅកម្ពុជា «EV Charging Station in Cambodia » រវាងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិកម្ពុជា (NMC) និង វិទ្យាស្ថានមាត្រាសាស្ត្រជាតិប្រទេសចិន (NIM, China)

» បានលើកគម្រោង ស្តីពីការពង្រឹងសមត្ថភាពជំនាញមាត្រាសាស្ត្រ ផ្នែកម៉ាស និងសីតុណ្ហភាព ដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងតំបន់ឡានឆាង-មេគង្គ (Strengthening Metrology Capacity in Mass and Temperature to Facilitate Trade in the Lancang-Mekong Region) 2025»

- បានចុះអនុស្សរណៈយោគយល់រវាង NMC និងវិទ្យាស្ថានមាត្រាសាស្ត្រជាតិប្រទេសថៃ (NIMT) ស្តីពីកិច្ចសហប្រតិបត្តិការលើផ្នែកមាត្រាសាស្ត្រ នៅទីក្រុងបាងកក ប្រទេសថៃ
- បានលើកគម្រោងស្តីពី «Strengthening Metrology Infrastructure in Cambodia» បញ្ចូលទៅក្នុងគម្រោង អាទិភាព ដើម្បីដាក់បេក្ខភាពគម្រោងក្នុងក្របខណ្ឌឥណទានសម្បទានពី សាធារណរដ្ឋកូរ៉េ (EDCF Loan)
- បានរៀបចំពង្រាងគម្រោង "Concept Paper Enhancing Cambodia's Metrology Infrastructure for Trade Competitiveness and Economic Growth" ជាមួយភាគីហុងកុង
- បានរៀបចំគម្រោងទី១ ស្តីពីការគាំទ្របច្ចេកទេសរៀបចំប្រព័ន្ធថ្លឹងគ្រាប់ធញ្ញជាតិនៅប្រទេសកម្ពុជា និងគម្រោងទី២ ស្តីពីគាំទ្រវង្វាស់វង្វាល់ទឹកពិសាជប ដែលគម្រោងទាំងពីរនេះមានរយៈពេលអនុវត្ត ៣ឆ្នាំ (ឆ្នាំ២០២៥-២០២៧) ក្នុងទំហំទឹកប្រាក់ប្រមាណ ១,៨ លានដុល្លារអាមេរិក
- បានរៀបចំគម្រោងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិដំណាក់កាលទី៣ (Project of Strengthening Quality Infrastructure phase III)
- បានចូលរួមសហការជាមួយលោកស្រី Cora Roos ប្រធានគម្រោង PTB ទាក់ទងនឹងគម្រោង Phase III បញ្ហាស្នើសុំ ISO/IEC:17025-2017 និងលក្ខណៈបច្ចេកទេសមួយចំនួន។

៥. ការងារវាយតម្លៃទទួលស្គាល់នៃកម្ពុជា

ការវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោម គឺជាប្រព័ន្ធអន្តរជាតិមួយ ដែលបានរួមចំណែកដល់ការកាត់បន្ថយរបាំងបច្ចេកទេសនៃការធ្វើពាណិជ្ជកម្ម (TBT) និងរបាំងអនាម័យ និងភូតគាមអនាម័យ (SPS) ដែលនេះជាកត្តាសំខាន់បំផុតក្នុងការជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម, ចរាចរណ៍ទំនិញ និងសេវាកម្ម។ ក្នុងឆ្នាំ២០២៤ កន្លងមកក្រសួងបានអនុវត្តការងារវាយតម្លៃទទួលស្គាល់នៃកម្ពុជា និងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

៥.១. ការងារពង្រឹងស្ថាប័ន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- បានសហការជាមួយស្ថាប័ន PTB នៃប្រទេសអាល្លឺម៉ង់ ដើម្បីជួយពង្រឹងសមត្ថភាពមន្ត្រី អ្នកជំនាញ និងអ្នកវាយតម្លៃទទួលស្គាល់របស់អគ្គនាយកដ្ឋាន (Assessor and Expert Pools)

» បានសហការជាមួយ ACCSQ-WG-2 ក្នុងការផ្លាស់ប្តូរបទពិសោធន៍ការងារវាយតម្លៃទទួលស្គាល់, ការកសាងសមត្ថភាពមន្ត្រី និងអ្នកវាយតម្លៃទទួលស្គាល់
» បានសហការជាមួយអង្គភាពវាយតម្លៃទទួលស្គាល់បរទេស ដោយចូលរួមធ្វើជាអ្នកអង្កេតការណ៍លើការងារវាយតម្លៃទទួលស្គាល់របស់អង្គភាពវាយតម្លៃទទួលស្គាល់បរទេស ដែលបានធ្វើការងារវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោមក្នុងប្រទេសកម្ពុជា
» បានចូលជាសមាជិក Singatories MRA / MLA របស់ស្ថាប័ន APAC, IHAF និង ILAC ដើម្បីបញ្ជាក់ពីសមត្ថភាព និងទទួលបាននូវការទទួលស្គាល់ជាមួយស្ថាប័នក្នុងតំបន់ និងអន្តរជាតិ
» បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការវាយតម្លៃទទួលស្គាល់ជាតិនៃកម្ពុជា
» បានរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗ ដើម្បីបំពេញនូវតម្រូវការនៃកិច្ចដំណើរការផ្តល់សេវាកម្មវាយតម្លៃទទួលស្គាល់ ឱ្យឈានទៅបានការទទួលស្គាល់នៃវិសាលភាពតាមស្តង់ដាផ្សេងៗបន្ថែមទៀត
» បានសហការជាមួយ BoA, IAS, NATA, JAS-ZAN, SAC, ONSC, BLA-DSS, ACFS, BLQS-DMSc ដើម្បីរៀនសូត្រ និងដកស្រង់បទពិសោធន៍ ក្នុងការវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមក្នុងប្រទេស កម្ពុជា ឱ្យបានការទទួលស្គាល់ជាកម្រិតជាតិ និងអន្តរជាតិ។

៥.២. ការអភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ប្រកបដោយបរិយាបន្ន

ក្រសួង បានដាក់ដំណើរការប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ខ្លួនស្របតាមស្តង់ដាអន្តរជាតិ ISO/IEC 17011 និងដំណើការវាយតម្លៃទទួលស្គាល់ស្របតាមវិសាលភាពនៃប្រព័ន្ធនីតិវិធីវាយតម្លៃទទួលស្គាល់ អនុលោមតាមស្តង់ដាអន្តរជាតិ ដូចជា ISO/IEC 17025, ISO 15189, ISO/IEC 17020, ISO/IEC 17021, ISO/IEC 17065, ISO/IEC 17029 និងសេរីស្តង់ដា ISO 14065។ល។ ទន្ទឹមនេះ ដើម្បីពង្រឹងដល់ដំណើរការប្រព័ន្ធគ្រប់គ្រងគុណភាព ក្រសួងបានចូលជាសមាជិកក្រុមការងារទី២ នៃគណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីស្តង់ដា និងគុណភាពអាស៊ាន (ACCSQ-WG-2) និងស្ថាប័នវាយតម្លៃទទួលស្គាល់តំបន់ និងអន្តរជាតិ, APAC, IHAF, ILAC និងមានផែនការចូលជាសមាជិកនៃ IAF។ ដើម្បីធានាបំពេញលក្ខខណ្ឌជាអន្តរជាតិលើសេវាវាយតម្លៃទទួលស្គាល់ ក្រសួង បានប្រឹងប្រែងរៀបចំប្រព័ន្ធនីតិវិធីវាយតម្លៃទទួលស្គាល់ (schemes) ដោយអនុលោមស្តង់ដាអន្តរជាតិ

ដូចជា៖ ISO/IEC 17025 សម្រាប់មន្ទីរពិសោធន៍ ព្យាសកម្ម, ISO15189 សម្រាប់មន្ទីរពិសោធន៍ធ្វើតេស្តវេជ្ជសាស្ត្រ ISO/IEC 17020 សម្រាប់អង្គភាពអធិការកិច្ច ISO/IEC17021 សម្រាប់អង្គភាពវិញ្ញាបនបត្រកម្មស្តង់ដាប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17065 សម្រាប់អង្គភាពវិញ្ញាបនបត្រកម្មស្តង់ដាផលិតផល និងISO/IEC 17029 សេរីស្តង់ដា ISO 14065 សម្រាប់អង្គភាពធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់សុពលភាព។

៥.៣. ការងារវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោម (CABs)

ការងារវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោម បានចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាព និងការចុះបញ្ជីត្រូវបានផ្តល់ជូនអង្គភាពវាយតម្លៃភាពអនុលោម និងអ្នកស្នើសុំ មានដូចជា៖

» បានវាយតម្លៃទទួលស្គាល់លើសមត្ថភាព និងសមត្ថកិច្ចកម្រិតជាតិ ចំនួន១២ កម្រិតអន្តរជាតិ ចំនួន ១០

» បានចេញវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោមចំនួន ២០ និងលិខិតអនុញ្ញាតជូនអង្គភាពវាយតម្លៃទទួលស្គាល់ក្រៅប្រទេសចំនួន ១០

» បានចុះបញ្ជីបញ្ជាក់ការទទួលស្គាល់វិញ្ញាបនបត្រវាយតម្លៃភាពអនុលោមភ្ជាប់ទំនិញនាំចេញ-នាំចូល ចំនួន ២៦

» បាននិងកំពុងធ្វើការវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាព និងសមត្ថកិច្ច ដល់អង្គភាពវាយតម្លៃភាពអនុលោមដែលជាមន្ទីរពិសោធន៍ធ្វើតេស្តអនុលោមតាមស្តង់ដាអន្តរជាតិ ISO/IEC 17025: 2017 ជូនដល់មន្ទីរពិសោធន៍ចំនួន ០២ ដូចជា៖ Board of Engineers Cambodia Laboratory (CAST Laboratory Co. Ltd.) និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

» បានធ្វើការវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាព និងសមត្ថកិច្ច ដល់អង្គភាពវាយតម្លៃភាពអនុលោមដែលជាមន្ទីរពិសោធន៍ធ្វើតេស្តអនុលោមតាមស្តង់ដាអន្តរជាតិ ISO/IEC 17025: 2017 ចំនួន ០២ ដូចជា៖ SGS (Cambodia) Limited និង Phnom Penh Water Supply Authority (PPWSA) ដែលកំពុងស្ថិតក្នុងសុពលភាព

» បានទទួលពាក្យស្នើសុំវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាព និងសមត្ថកិច្ច ពីក្រុមហ៊ុន SGS (Cambodia) Limited - Sihanoukville branch ជាមន្ទីរពិសោធន៍ធ្វើតេស្តអនុលោមតាមស្តង់ដាអន្តរជាតិ ISO/IEC 17025: 2017

» បានចូលរួមជាអ្នកអង្កេតការណ៍ជាមួយក្រុមអ្នកវាយតម្លៃទទួលស្គាល់នៃអង្គភាពវាយតម្លៃទទួលស្គាល់ BoA ប្រទេសវៀតណាមដែលមកធ្វើការវាយតម្លៃទទួលស្គាល់

ដល់មន្ទីរពិសោធន៍នៃក្រុមហ៊ុន Bureau Veritas (Cambodia) Limited. និងជាមួយក្រុមអ្នកវាយតម្លៃទទួលស្គាល់នៃការិយាល័យមន្ទីរពិសោធន៍ស្តង់ដាគុណភាព (BLQS, DMSc) នៃប្រទេសថៃ ដែលចុះធ្វើការវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍ MORU-COMRU Unit នៃមន្ទីរពេទ្យកុមារអង្គរនៅខេត្តសៀមរាប និងជាមួយក្រុមអ្នកវាយតម្លៃទទួលស្គាល់ NATA ចុះវាយតម្លៃទទួលស្គាល់ដល់ STINL, MISTI

» បានផ្តល់វិញ្ញាបនបត្រនៃការចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម ដល់ក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃភាពអនុលោមចំនួន ២០

» បានផ្តល់លិខិតអនុញ្ញាតដល់អង្គភាពវាយតម្លៃទទួលស្គាល់ក្រៅប្រទេស មកធ្វើការវាយតម្លៃទទួលស្គាល់ដល់មន្ទីរពិសោធន៍ក្នុងប្រទេសកម្ពុជាចំនួន ១១

» បានរៀបចំកិច្ចពិភាក្សា និងចែករំលែកចំណេះដឹងជាមួយអ្នកជំនាញ មកពីស្ថាប័ន PTB Mr. Hanspeter Ischi ទៅលើឯកសារ IAF Mandatory Documentation Series ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតនីតិវិធីវាយតម្លៃទទួលស្គាល់ប្រព័ន្ធគ្រប់គ្រង Management System (ISO/IEC 17021-1)។

៥.៤. ការងារបណ្តុះបណ្តាល

ដើម្បីរួមចំណែកអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ក្រសួងបានផ្តល់ការងារបណ្តុះបណ្តាលដល់មន្ត្រី ជំនាញ និងភាគីពាក់ព័ន្ធ ក្នុងនោះមាន៖

» សហការរៀបចំបើកវគ្គបណ្តុះបណ្តាលទៅលើស្តង់ដា (ISO/IEC 17011:2017) ដល់មន្ត្រីនៃអគ្គនាយកដ្ឋាន និងអង្គភាពវាយតម្លៃភាពអនុលោម និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ស្តង់ដាវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រង (ISO/IEC 17021), ស្តង់ដា ISO 15189:2022 for Medical laboratories សម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ, Good Manufacturing Practice (GMP) and Hazard Analysis and Critical Control Point (HACCP), ការវាយតម្លៃទទួលស្គាល់លើស្តង់ដាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ (ISO 22000), ស្តង់ដាអន្តរជាតិ ISO/IEC 17025:2017 ដល់រដ្ឋាករទឹកស្វយ័តសៀមរាប, "Scheme of Testing Laboratory" សម្រាប់ការវាយតម្លៃទទួលស្គាល់ ដល់អង្គភាពពិសោធន៍, "ISO/IEC 17021-3:2017: Conformity assessment-Requirements for bodies providing audit and certification of management systems- Part 3: Competence requirements for auditing and certification of quality management systems" ដោយមានអ្នកជំនាញពីស្ថាប័ន PTB, " ISO 19001; Guidelines for quality and/or envi-

ronmental management systems auditing" ដោយមានអ្នកជំនាញពីស្ថាប័ន PTB ជាគ្រូបង្គោល

» រៀបចំកិច្ចពិភាក្សា ស្តីពីការណែនាំអំពីប្រព័ន្ធនីតិវិធីវាយតម្លៃទទួលស្គាល់ដល់អង្គភាពវិញ្ញាបនបត្រ (Accreditation Scheme) និងវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រង (ISO/IEC 17021)។

៥.៥. ការងារផ្សព្វផ្សាយ

ដើម្បីបញ្ជ្រាបអំពីការងារវាយតម្លៃទទួលស្គាល់ដល់សាធារណជន ក្រសួងបានរៀបចំសកម្មភាពមួយចំនួន មានដូចជា៖

» បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម និងការងារផ្សេងៗ

» រៀបចំវេទិកាផ្សព្វផ្សាយ ស្តីពីការងារវាយតម្លៃទទួលស្គាល់ ទៅដល់បណ្តាមន្ទីរ ឧ.វ.ប.ន. និងមន្ទីរពាក់ព័ន្ធ

» បានរៀបចំវេទិកាផ្សព្វផ្សាយ ស្តីពីការងារវាយតម្លៃទទួលស្គាល់ដល់ អង្គភាពវាយតម្លៃភាពអនុលោម

» បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី "ការងារវាយតម្លៃទទួលស្គាល់អង្គភាពវិញ្ញាបនបត្រកម្ម" ជាមួយអង្គភាពវាយតម្លៃភាពអនុលោម និងការងារផ្សេងៗពាក់ព័ន្ធនឹងអនុលោមភាព

» បានរៀបចំផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្ត និងសេវាកម្មវាយតម្លៃទទួលស្គាល់របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់អង្គភាពវិញ្ញាបនបត្រកម្ម ដល់អង្គភាពវាយតម្លៃភាពអនុលោម (CABs) និងបង្កើតទំនាក់ទំនង និងពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយអង្គភាពវាយតម្លៃភាពអនុលោម (CABs) ក្នុងការទទួលយកសេវាកម្មវាយតម្លៃទទួលស្គាល់ពីអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជា។

៦. ការងារមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

មន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ម.ជ.វ.ប.ន) បានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងដើម្បីក្លាយជាមន្ទីរពិសោធន៍ជាតិឈានមុខគេ ដែលបង្កើនអានុភាពដល់នវានុវត្តន៍ និងជានាគុណភាពតេស្តវិភាគប្រកបដោយសុក្រឹតភាព និងទំនុកចិត្ត រួមចំណែកជំរុញឧស្សាហកម្មខ្នាតតូច និងមធ្យម ក្នុងការប្រកួតប្រជែងថ្នាក់ជាតិ និងអន្តរជាតិ ក្នុងនោះមាន៖

ពិធីសម្ពោធមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤

- ម.ជ.វ.ប.ន បាននិងកំពុងផ្តល់សេវាធ្វើតេស្តវិភាគលើប៉ារ៉ាម៉ែត្រមួយចំនួនដូចជា៖ Total Plate Count, Coliform Count, Molds & Yeasts, pH, Fiber, CN-, SO2, Carbohydrate, Vitamin C, Ca, Mg, P, K, Na, Fe, ផេះ, សំណើម និងអាមីដុងជាដើម
- យកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមត្ថភាព ម.ជ.វ.ប.ន ក្នុងកម្រិតអន្តរជាតិ អនុលោមតាមស្តង់ដា ISO/IEC 17025:2017 ដើម្បីក្លាយជាមជ្ឈមណ្ឌលមួយដែលមានការទាក់ទាញ និងជឿទុកចិត្តពីសំណាក់ក្រុមហ៊ុន សហគ្រាស និងមូលដ្ឋានផលិតកម្ម អាជីវកម្ម ក៏ដូចជាសាធារណជន លើការបញ្ជាក់គុណភាពផលិតផល និងរួមចំណែកដល់ការពង្រឹងភាពប្រកួតប្រជែងលើទីផ្សារ ក្នុងស្រុក និងការនាំចេញ។ ជាលទ្ធផល មន្ទីរពិសោធន៍ជាតិបានផ្តល់សេវាវិភាគគុណភាពផលិតផលនូវសេវាធ្វើតេស្តវិភាគគុណភាពផលិតផលបានសរុបគំរូផលិតផលចំនួន ១១.០១៨ (គិតចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤) ដោយអនុលោមតាមស្តង់ដាចំនួន ៨.៣២៨ និងមិនអនុលោមតាមស្តង់ដាចំនួន ២.៦៩០។ ជាមួយគ្នានេះដែរ ដើម្បីបញ្ជាក់ពីសុក្រិតភាពនៃសេវាធ្វើតេស្តវិភាគគុណភាពផលិតផល ម.ជ.វ.ប.ន បានចូលរួមធ្វើវាយតម្លៃនៃការអនុលោមស្តង់ដា ISO/IEC 17025: 2017 ជាមួយអង្គភាពវាយតំលៃទទួលស្គាល់ SAC-SINGLAS ប្រទេសសិង្ហបុរី និង NATA ប្រទេសអូស្ត្រាលីផងដែរ។

៧. វិស័យទឹកស្អាត

រាជរដ្ឋាភិបាល អាណត្តិទី៧ បានគិតគូរដល់ការពង្រឹងសមត្ថភាពផលិត និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅគ្រប់តំបន់ទីប្រជុំជន រហូតដល់ទីជនបទដទៃទៀត សម្រាប់ការប្រើប្រាស់ទូទៅដល់សាធារណជន ដោយពង្រឹង និងធានាប្រសិទ្ធភាពនៃការផលិត ការចែកចាយ និងការធ្វើអាជីវកម្មប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជនទូទាំងប្រទេសមានប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលទទួលបានប្រកាសអនុញ្ញាតសរុបចំនួន ៤៥៤ ប្រកាស ដែលក្នុងនោះមានរដ្ឋាករទឹកសាធារណៈចំនួន ១១ (ស្មើនឹង ១៤ប្រកាស) រួមមាន៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្វយ័តសៀមរាប រដ្ឋាករទឹកស្ទឹងត្រែង រដ្ឋាករទឹកបាត់ដំបង រដ្ឋាករទឹកកំពង់ចាម រដ្ឋាករទឹកក្រុងស្ទឹងសែន រដ្ឋាករទឹកកំពត រដ្ឋាករទឹកមណ្ឌលគិរី រដ្ឋាករទឹកពោធិ៍សាត់ រដ្ឋាករទឹកស្វាយរៀង រដ្ឋាករទឹកស្ទោង-តាំងក្រសាំង និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនមានចំនួន សរុប ៤៤០ប្រកាស។

ទន្ទឹមនេះ ក្រសួងបានជំរុញអនុវត្តគោលនយោបាយទឹកស្អាត ដោយបានធ្វើការតភ្ជាប់បណ្ដាញជូនប្រជាពលរដ្ឋដែលមានប័ណ្ណសមធម៌ (ប្រភេទក្រ១ និងក្រ២) និងប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបសរុបចំនួន ២១១.១៣៦ តំណ និងបានភ្ជាប់បណ្ដាញជូនចំពោះអតិថិជនជាកម្មករ-កម្មការិនី និងសិស្ស-និស្សិត សរុបចំនួន ១១១.៥៣៧តំណ។

៧.១. ការងារទិន្នន័យទឹកស្អាតទូទាំងប្រទេស

សេវាទឹកស្អាតនៅតំបន់ទីប្រជុំជនត្រូវបានពង្រីក និងបង្កើនប្រសិទ្ធភាពតាមរយៈការពង្រឹង និងពង្រីកវិសាលភាព នៃការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ទីប្រជុំជន ក្នុងនោះរួមមាន៖

» បានចេញប្រកាសជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ២៣ មូលដ្ឋាន។ គិតមកដល់បច្ចុប្បន្ននេះ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៤៥៤ មូលដ្ឋាន ក្នុងនោះរដ្ឋាករទឹកសាធារណៈចំនួន ១១ ដែលមានអាជ្ញាបណ្ណសរុបចំនួន ១៤ និងប្រតិបត្តិករឯកជន មានអាជ្ញាបណ្ណសរុបចំនួន ៤៤០ ដែលបានផលិតបរិមាណទឹកស្អាតចំនួន ៥៣០ លានម៉ែត្រគូប

» បានភ្ជាប់តំណទឹកស្អាតជូនអតិថិជនសរុបចំនួន ១៣៣.១០៣ តំណ។ មកដល់បច្ចុប្បន្ននេះ បានភ្ជាប់តំណទឹកស្អាតជូនអតិថិជនសរុបចំនួន ១.៤៣៤.០៣៨ តំណ ស្មើនឹង ៤០,៤% ធៀបនឹងចំនួនគ្រួសារសរុបទូទាំងប្រទេស (ដោយសន្មត់ថាតំណទាំងអស់ ជាតំណភ្ជាប់ជូនផ្ទះប្រជាពលរដ្ឋ(Residential Connections) និង ១តំណស្មើនឹង ១គ្រួសារ)

» បានផ្ដល់អាជ្ញាបណ្ណជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៥០៦ ភូមិ នៅឆ្នាំ២០២៤។ មកដល់បច្ចុប្បន្ននេះ បានផ្ដល់អាជ្ញាបណ្ណជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ១០.៦៥៩ភូមិ ដែលស្មើនឹង ៤៩,៩% ធៀបនឹងចំនួនភូមិសរុបទូទាំងប្រទេស (ក្នុងនោះភូមិបានបណ្ដាញទឹកស្អាតមានចំនួន ៧.២៦៩ភូមិ ស្មើនឹង ៦៨,១% ធៀបនឹងចំនួនភូមិសរុបក្នុងតំបន់សេវាកម្ម)។

ក. បរិមាណទឹកស្អាតផលិត និងផ្គត់ផ្គង់

ក្នុងឆ្នាំ២០២៤ កន្លងមក ការផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបចំនួនប្រមាណ ៥៣០ លានម៉ែត្រគូប មានកំណើនប្រមាណ ៦៨ លានម៉ែត្រគូប ស្មើនឹង ១៤,៩% ធៀបនឹងឆ្នាំ២០២៣ មានចំនួនប្រមាណ ៤៦១ លានម៉ែត្រគូប ក្នុងនោះ៖

» រដ្ឋាករទឹកសាធារណៈបានផលិត និងផ្គត់ផ្គង់ទឹកស្អាតចំនួនប្រមាណ ៣៥៧ លានម៉ែត្រគូប មានកំណើនប្រមាណ ៥០ លានម៉ែត្រគូប ស្មើនឹង ១៦,៣% ធៀបនឹងឆ្នាំ២០២៣ ដែលមានបរិមាណទឹកផលិត និងផ្គត់ផ្គង់ចំនួន ៣០៧ លានម៉ែត្រគូប

» ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានផលិត និងផ្គត់ផ្គង់ទឹកស្អាតចំនួនប្រមាណ ១៧៣ លានម៉ែត្រគូប មានកំណើនប្រមាណ ១៨ លានម៉ែត្រគូប ត្រូវស្មើនឹង ១២,១% ធៀបនឹងឆ្នាំ២០២៣ បរិមាណទឹកដែលផលិតបានចំនួនប្រមាណ ១៥៤ លានម៉ែត្រគូប។

តារាងបង្ហាញអំពីបរិមាណផលិត និងផ្គត់ផ្គង់ទឹកស្អាតដោយរដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន

ល.រ	ប្រតិបត្តិករ	បរិមាណទឹកផលិតសរុបចុងគ្រា (ម៣)		
		ឆ្នាំ២០២៣	ឆ្នាំ២០២៤	អត្រាកំណើន
១	រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	២៦៤.៧៨២.៩៤៧	៣០៨.៩៣១.៥០៣	១៦,៧ %
២	រដ្ឋាករទឹកស្វយ័តសៀមរាប	៩.០៤៥.៩៩៥	១០.៨១២.៥៤០	១៩,៥ %
៣	រដ្ឋាករទឹកសាធារណៈ ៩ ផ្សេងទៀត	៣៣.៩៦០.៣៩១	៣៨.០៧៥.៣៧៥	១២,១ %
៤	ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន	១៥៣.៩៦៩.៧៩៧	១៧២.៥៤៤.៨១៥	១២,១ %
	សរុប	៤៦១.៧៨៩.១៣០	៥៣០.៣៦៤.២៣៣	១៤,៩ %

ក្រាហ្វិកបង្ហាញអំពីបរិមាណទឹកផលិតរយៈពេល ៥ឆ្នាំចុងក្រោយ (ម៣)



ខ. ចំនួនតំណភ្ជាប់ជូនអតិថិជន

ក្នុងឆ្នាំ២០២៤ កន្លងមក រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បានភ្ជាប់តំណជូនអតិថិជន សរុបចំនួន ១.៤៤០.៩១៣ តំណ មានកំណើនឡើង ១៣៣.១០៣ តំណ ស្មើនឹង ១០,២% ប្រៀបធៀបនឹងឆ្នាំ២០២៣ មានចំនួន ១.៣០៧.៨១០ តំណ ក្នុងនោះ៖

» រដ្ឋាករទឹកសាធារណៈបានភ្ជាប់តំណជូនអតិថិជនចំនួន ៦៤៦.៧១៧ តំណ បើប្រៀបធៀបទៅឆ្នាំ ២០២៣ បានភ្ជាប់តំណជូនអតិថិជនចំនួន ៦០៧.២៧៣ តំណ គឺមានការកើនឡើង ៣៩.៤៤៤ តំណ ដែលស្មើនឹង ៦,៥%។

» ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទឹកស្អាតឯកជនបានភ្ជាប់តំណជូនអតិថិជនចំនួន ៧៩៤.១៩៦ តំណ បើប្រៀបធៀបទៅ ឆ្នាំ២០២៣ បានភ្ជាប់តំណជូនអតិថិជនចំនួន ៧០០.៥៣៧ តំណ គឺមានការកើនឡើង ៩៣.៦៥៩ តំណ ដែលស្មើនឹង ១៣,៤%។

តារាងបង្ហាញអំពីចំនួនតំណភ្ជាប់បណ្តាញទឹកស្អាត

ល.រ	ប្រតិបត្តិករ	ចំនួនគ្រួសារក្នុងតំបន់សេវាកម្ម		ចំនួនតំណចុងគ្រា	
		ឆ្នាំ២០២៣	ឆ្នាំ២០២៤	ឆ្នាំ២០២៣	ឆ្នាំ២០២៤
១	រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	៥០៤.១៥១	៥២២.៥១៥	៤៧១.៧១៤	៤៩៩.១០២
២	រដ្ឋាករទឹកស្វយ័តសៀមរាប	៨២.៥៦០	៨២.៥៦០	២២.៩១៩	២៥.៥១០
៣	រដ្ឋាករទឹកសាធារណៈ ៩ ផ្សេងទៀត	១៩៧.២៦០	២១៧.៤៧២	១១២.៦៤០	១២២.១០៥
៤	ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន	១.៧៤៧.៧៩៤	២.១៦០.២៨៤	៧០០.៥៣៧	៧៩៤.១៩៦
	សរុប	**២.៥៣១.៧៦៦**	**២.៩៨២.៨៣១**	**១.៣០៧.៨១០**	**១.៤៤០.៩១៣**

ក្រាហ្វិកបង្ហាញអំពីចំនួនគ្រួសារក្នុងតំបន់សេវាកម្ម និងចំនួនតំណសរុប



ក្រាហ្វិកបង្ហាញអំពីចំនួនតំណភ្ជាប់ដោយរដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន



គ. ចំនួនភូមិក្នុងតំបន់សេវាកម្ម និងចំនួនភូមិដាក់បណ្តាញទឹកស្អាត

ក្នុងឆ្នាំ២០២៤ កន្លងមក ភូមិដាក់បណ្តាញទឹកស្អាតសរុបមានចំនួន ៧.៤២៤ ភូមិ នៃចំនួនភូមិសរុបដែលមានក្នុងតំបន់សេវាកម្មចំនួន ១០.៦៧៩ ភូមិ ក្នុងនោះ៖

» រដ្ឋាករទឹកសាធារណៈបានដាក់បណ្តាញក្នុងភូមិសរុបចំនួន ១.៤៧១ ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ១.៩៦០ ភូមិ

» ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានដាក់បណ្តាញក្នុងភូមិចំនួន ៥.៩៥៣ ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ៨.៧១៩ ភូមិ។

តារាងបង្ហាញអំពីចំនួនភូមិក្នុងតំបន់សេវាកម្ម និងចំនួនភូមិដាក់បណ្តាញទឹកស្អាត

ល.រ	ប្រតិបត្តិករ	ចំនួនភូមិតំបន់សេវាកម្ម		ចំនួនភូមិដាក់បណ្តាញ	
		ឆ្នាំ២០២៣	ឆ្នាំ២០២៤	ឆ្នាំ២០២៣	ឆ្នាំ២០២៤
១	រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	១.០៦៩	១.០៦៩	៨៦៥	៨៨០
២	រដ្ឋាករទឹកស្វយ័តសៀមរាប	១៨៦	១៨៦	១០៥	១១០
៣	រដ្ឋាករទឹកសាធាណៈ ៩ ផ្សេងទៀត	៦២៤	៧០៥	៤៦៥	៤៨១
៤	ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន	៨.២៩៤	៨.៧១៩	៥.០៨៤	៥.៩៥៣
	សរុប	១០.១៧៣	១០.៦៧៩	៦.៥១៩	៧.៤២៤

ក្រាហ្វិកបង្ហាញអំពីចំនួនភូមិដាក់បណ្តាញទឹកស្អាតធៀបនឹងចំនួនភូមិក្នុងតំបន់សេវាកម្ម



ឃ. ប្រវែងបណ្តាញ(គ.ម)

គិតត្រឹមឆ្នាំ២០២៤ បំពង់មេ និងបណ្តាញចែកចាយសរុបមានប្រវែង ៣៦.៤២៣ គ.ម បើប្រៀបធៀបទៅឆ្នាំ២០២៣ ដែលមានប្រវែងសរុប ៣០.៣៥១ គ.ម មានការកើនឡើង ៦.០៧២ គ.ម ដែលស្មើនឹង ២០% ក្នុងនោះ៖

- » រដ្ឋាករទឹកសាធារណៈបានដាក់បំពង់មេ និងបណ្តាញចែកចាយសរុបបានប្រវែង ៨.៧៨៥ គ.ម បើប្រៀបធៀបទៅឆ្នាំ២០២៣ ដែលមានប្រវែងសរុប ៧.៨៦៣ គ.ម គឺមានការកើនឡើង ៩២២ គ.ម ដែលស្មើនឹង ១១,៧%
- » ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានដាក់បំពង់មេ និងបណ្តាញចែកចាយសរុបបានប្រវែង ២៧.៦៣៩ គ.ម បើប្រៀបធៀបទៅឆ្នាំ២០២៣ ដែលមានប្រវែងសរុប ២២.៤៨៨ គ.ម មានការកើនឡើង ៥.១៥០ គ.ម ដែលស្មើនឹង ២២,៩%។

តារាងបង្ហាញអំពីប្រវែងបណ្តាញ

ល.រ	ប្រតិបត្តិករ	ប្រវែងបណ្តាញ (គ.ម)		
		ឆ្នាំ២០២៣	ឆ្នាំ២០២៤	អត្រាធៀប
១	រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	៤.៦៩១	៥.០១៩	៧,០%
២	រដ្ឋាករទឹកស្វយ័តសៀមរាប	៥២៣	៨៧០	៦៦,៣%
៣	រដ្ឋាករទឹកសាធារណៈ ៩ ផ្សេងទៀត	២.៦៤៩	២.៨៩៦	៩,៣%
៤	ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន	២២.៤៨៨	២៧.៦៣៩	២២,៩%
	សរុប	៣០.៣៥១	៣៦.៤២៣	២០%

បង្ហាញអំពីប្រវែងបណ្ដាញ (គ.ម)
របស់រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន



៧.២. ការងាររកសាងផែនការ

ក្រោមគម្រោងសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យទឹកស្អាត រវាងក្រសួងឧ.វ.ប.ន និងរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានរៀបចំកសាង «ផែនការអភិវឌ្ឍន៍វិស័យទឹកស្អាតទីប្រជុំជន (Project for Formulation of the Development Plan for Urban Water Supply)»។ ក្រៅពីនេះ យើងក៏មានដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដែលបានចូលរួមសហការរៀបចំកសាងផែនការសម្រាប់តំបន់គោលដៅមួយចំនួនផងដែរ។ ក្រសួងបាននិងកំពុងពិនិត្យមើលស្ថានភាពផ្គត់ផ្គង់ទឹកស្អាត ស្ថានភាពមន្ត្រីទទួលបន្ទុកទឹកស្អាតនៅតាមមន្ទីរ ឧ.វ.ប.ន រាជធានី-ខេត្ត បញ្ហាប្រឈមក្នុងពេលអនុវត្តតួនាទីរបស់មន្ទីរទាំងអស់លើការធ្វើបញ្ញត្តកម្មទឹកស្អាត តម្រូវការបណ្ដុះបណ្ដាល និងការពង្រឹងសមត្ថភាពដល់មន្ត្រីនៅតាមមន្ទីរ ឧ.វ.ប.ន រាជធានី-ខេត្ត។ ក្រសួងបាននិងកំពុងជួយលើកកម្ពស់សមត្ថភាពមន្ត្រីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងក្រោមជាតិ លើការងារអភិវឌ្ឍន៍ផែនការមេ ដើម្បីឈានទៅរៀបចំផែនការអភិវឌ្ឍន៍វិស័យទឹកស្អាត ឱ្យកាន់តែមានប្រសិទ្ធភាព។

រោងចក្រផលិតទឹកស្អាតបឹងធំ សមត្ថភាពផលិតទឹកស្អាត ៦.០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ត្រូវបានសម្ពោធ ដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

ឯកឧត្តម ហែម វណ្ណឌី ចុះទស្សនកិច្ចរោងចក្រផលិតទុយោរបស់ក្រុមហ៊ុន Lesso
នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល

វេទិកា សិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលនានា ក្នុងវិស័យទឹកស្អាត

៧.៣. ការងារបញ្ញត្តកម្មទឹកស្អាត

ក. ការផ្ដល់គោលការណ៍សិក្សា និងប្រកាសអនុញ្ញាតផ្សេងៗ

ក្នុងឆ្នាំ២០២៤ កន្លងមក ក្រសួងបានផ្ដល់គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព និងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជូនទីតាំងចំនួន ៣២ ដោយក្នុងនោះមានគោលការណ៍សិក្សាសមិទ្ធិលទ្ធភាពចំនួន ៩ទីតាំង, ប្រកាសអនុញ្ញាតផ្ទាល់ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតចំនួន ២២ទីតាំង, ប្រកាសអនុញ្ញាតជំនួសឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ទីតាំង និងប្រកាសកែសម្រួល(ផ្ទេរសិទ្ធិ/ពង្រីកតំបន់សេវា)ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន ៧ទីតាំង។

គិតត្រឹមចុងឆ្នាំ២០២៤ ក្រសួងបានផ្ដល់ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៤៥៤ ក្នុងនោះរដ្ឋាករទឹកសាធារណៈចំនួន១១ ដែលមានអាជ្ញាបណ្ណសរុបចំនួន ១៤ និងប្រតិបត្តិករឯកជន មានអាជ្ញាបណ្ណសរុបចំនួន ៤៤០។

ខ. ផែនទីធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស



៧.៤. ការងារគម្រោង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

គម្រោងសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យទឹកស្អាតដែលបាននិងកំពុងអនុវត្តមានសរុបចំនួន ២២គម្រោង ដែលរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត, គម្រោងកសាងផែនការ, ការកសាងសមត្ថភាព និងការបង្កើនប្រសិទ្ធភាពការគ្រប់គ្រងដំណើរការរដ្ឋាករទឹកតាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។

នៅក្នុងឆ្នាំ២០២៤ គម្រោងសហប្រតិបត្តិការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ ត្រូវបានបញ្ចប់ជាស្ថាពរ និងបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ ដែលក្នុងនោះគម្រោងហិរញ្ញប្បទានឥតសំណងពីប្រទេសជប៉ុនមានចំនួន ២គម្រោង ស្មើប្រមាណ ២,៥៨ លានដុល្លារអាមេរិក និងគម្រោងហិរញ្ញប្បទានសម្បទានពី AFD ចំនួន ១គម្រោង ស្មើប្រមាណ ១៤៨,២០ លានដុល្លារអាមេរិក។ តាមរយៈសមិទ្ធផលនៃគម្រោងទាំង៣នេះ បានបង្កើនសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតសម្រាប់រដ្ឋាករទឹកសាធារណៈចំនួន ២០១.០០០ ម³/ថ្ងៃ និងបង្កើនបណ្តាញផ្គត់ផ្គង់ទឹកស្អាតទាំងបណ្តាញមេ និងចែកចាយបានចំនួន ២៨២ គ.ម។

៧.៥. ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់

ក្រសួងបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តស្ថិតក្រោមច្បាប់ ស្តីពីការគ្រប់គ្រងទឹកស្អាតចំនួន១០៖

- សេចក្តីព្រាងអនុក្រឹត្យចំនួន៣ ៖១) អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្ម ផ្គត់ផ្គង់ទឹកស្អាត ២) អនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ច ៣)អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត
- សេចក្តីព្រាងប្រកាសអន្តរក្រសួងចំនួន៣៖ ១)ប្រកាសអន្តរក្រសួងស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ច, ប្រកាសអន្តរក្រសួងស្តីពីបែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ ៣)ប្រកាសអន្តរក្រសួង ស្តីពីការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស
- សេចក្តីព្រាងប្រកាសចំនួន ៤៖ ១) ប្រកាស ស្តីពីបែបបទ និងនីតិវិធីសម្រាប់ធ្វើអធិការកិច្ចក្នុងវិស័យទឹកស្អាត ២)ប្រកាស ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ៣)ប្រកាស ស្តីពីទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរ ការផ្គត់ផ្គង់ទឹកស្អាត

៤) ប្រកាស ស្តីពីនីតិវិធីសម្រាប់ការស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

- បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងទឹកស្អាតចំនួន២លើក នៅថ្នាក់ជាតិ ១លើក និងថ្នាក់ក្រោមជាតិ ១លើក។

៧.៦. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា

ក្នុងឆ្នាំ២០២៤ ក្រសួងបានរៀបចំសម្របសម្រួល ផ្តល់ការបណ្តុះបណ្តាល និងសិក្ខាសាលាដល់មន្ត្រីអគ្គនាយកដ្ឋានទឹកស្អាត មន្ត្រីមន្ទីរឧ.វ.ប.ន. បានចំនួន ២៧៥នាក់ និងសហការជាមួយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាត ផ្តល់ការបណ្តុះបណ្តាលដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតបានចំនួន ៧០នាក់ មានដូចជា៖

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងទឹកបាត់បង់ នៅថ្ងៃទី ១៦-១៧ & ២៣ ខែកក្កដា ឆ្នាំ២០២៤
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីលក្ខណៈបច្ចេកទេសអប្បរមាសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូចនៅកម្ពុជា និងនីតិវិធីការចុះអធិការកិច្ចលក្ខណៈបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅថ្ងៃទី១២-១៣ ខែសីហា ឆ្នាំ២០២៤
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត នៅថ្ងៃទី៤-៥ ខែកញ្ញា ឆ្នាំ២០២៤
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកាត់បន្ថយផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់សម្រាប់អាជីវកម្ម ផ្គត់ផ្គង់ទឹកស្អាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤
- បានសម្របសម្រួលផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅថ្ងៃទី១៤ និងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងទឹកស្អាត នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ សម្រាប់ ថ្នាក់ក្រោមជាតិ ដែលមានអ្នកចូលរួម ១៤០នាក់ និងបានចូលរួមសិក្ខាសាលាក្នុង និងក្រៅប្រទេសបានចំនួន ៨ លើកផងដែរ។

៨. ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

នេះជាបេសកកម្មក្នុងយុគថ្មីរបស់ក្រសួង ក្នុងការរៀបចំក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបម្រើទៅដល់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ជាក់ស្តែងក្នុងឆ្នាំ២០២៤ នេះ ក្រសួងឧ.វ.ប.ន. សម្រេចបានលទ្ធផលដូចខាងក្រោម៖

៨.១. ការងារគោលនយោបាយ

ក្រសួងបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យ វ.ប.ន. ដោយផ្តោតលើការរៀបចំផែនទីបង្ហាញផ្លូវ និងរបៀបវារៈស្រាវជ្រាវជាតិ ការសិក្សាអំពីប្រព័ន្ធអេកូឡូស៊ី និងឯកសារសំខាន់ៗផ្សេងទៀតដើម្បីគាំទ្រវិស័យ វ.ប.ន. ដូចជាគោលការណ៍ណែនាំស្តីពីការទាក់ទាញបុគ្គលមានទេពកោសល្យសម្រាប់កម្ពុជាជាដើម។ លើសពីនេះ ក៏បានរៀបចំសេចក្តីព្រាងក្របខណ្ឌថវិកាសម្រាប់ការអភិវឌ្ឍវិស័យ វ.ប.ន. ដែលត្រូវបានចាត់ទុកជាការងារអាទិភាព និងបានបញ្ចប់សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តដូចជា៖

» អនុក្រឹត្យ ស្តីពីការគ្រប់គ្រងការស្រាវជ្រាវ និងអភិវឌ្ឍន៍
» អនុក្រឹត្យ ស្តីពីការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវ
» សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវ និងអភិវឌ្ឍន៍

៨.២. ការងារផ្ទេរបច្ចេកវិទ្យា

» បានពិនិត្យឡើងវិញលើសេចក្តីព្រាងច្បាប់ ស្តីពី «ការផ្ទេរបច្ចេកវិទ្យា»
» បានរៀបចំវេទិកាប្រចាំឆ្នាំលើកទី៤ ស្តីពីការផ្ទេរបច្ចេកវិទ្យា ក្រោមប្រធានបទ **«ការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា ៖ ការភ្ជាប់នវានុវត្តន៍បច្ចេកវិទ្យា និងឱកាសទីផ្សារនៅកម្ពុជា»**
» បានរៀបចំវគ្គបណ្តុះបណ្តាល ដល់មន្ត្រីរបស់ក្រសួងឧ.វ.ប.ន. វិស័យឯកជន និងសាកលវិទ្យាល័យ ដើម្បីពង្រឹងសមត្ថភាពបច្ចេកវិទ្យា។
» បានផ្តួចផ្តើមគំនិតក្នុងការរៀបចំមជ្ឈមណ្ឌលជាតិផ្ទេរបច្ចេកវិទ្យាដើម្បីគាំទ្រ និងជំរុញការផ្ទេរបច្ចេកវិទ្យាផងដែរ។

៨.៣. ការងារគ្រប់គ្រងព័ត៌មាន

ក្រសួងបានសិក្សាស្រាវជ្រាវពីតម្រូវការវិនិយោគពីខាងក្រៅទៅសហគ្រាសធុនតូច និងមធ្យម និងជួយកំណត់តម្រូវការវិនិយោគសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម ដើម្បីទាក់ទាញការវិនិយោគបន្ថែមសម្រាប់កំណើនប្រកបដោយចីរភាព និងធ្វើបរិវត្តកម្មឌីជីថលដោយដាក់ឱ្យដំណើរការនូវប្រព័ន្ធដូចខាងក្រោម៖

- ប្រព័ន្ធថាសផ្ទុកឯកសាររបស់ក្រសួងឧ.វ.ប.ន. (MISTI-Drive)
- ប្រព័ន្ធគេហទំព័រផ្លូវការរបស់ក្រសួងឧ.វ.ប.ន. (www.misti.gov.kh)
- ប្រព័ន្ធផ្តល់សេវាសាធារណៈឌីជីថល (https://services.misti.gov.kh) រួមមាន៖
  » ប្រកាសបង្កើតសហគ្រាសធុនមីក្រូ តូច មធ្យម និងរោងចក្រ
  » វិញ្ញាបនប័ត្រដំណើរការសហគ្រាសធុនមីក្រូ តូច និងមធ្យម (ថ្មី ឬបន្ត)

» វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ (ថ្មី ឬបន្ត)
» អាជ្ញាបណ្ណចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដាកម្ពុជា (ច.ប.ផ., សុវត្ថិភាព) សម្រាប់ រថយន្ត ទោចក្រយានយន្ត និងត្រីចក្រយានយន្ត
» វិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម

- ប្រព័ន្ធបណ្តាញណិតវើកអ៊ីនធឺណិតល្បឿន ២០ ជីកាបីតក្នុងមួយវិនាទី (20Gbps) ដើម្បីធ្វើការតភ្ជាប់ទៅកាន់មជ្ឈមណ្ឌលទិន្នន័យ និងទីស្តីការក្រសួង រួមទាំងទីតាំងផ្សេងៗក្រោមឱវាទក្រសួងក្នុងរាជធានីភ្នំពេញ។

៨.៤. ការងារសហប្រតិបត្តិការ

ក្រសួងបានចុះអនុស្សរណៈយោគយល់ និងកិច្ចព្រមព្រៀង ចំនួន ៥ ក្នុងក្របខណ្ឌសហប្រតិបត្តិការវិស័យ វ.ប.ន. រួមមាន៖ ១) រវាងក្រសួងឧ.វ.ប.ន. និងក្រសួងឧត្តមសិក្សា វិទ្យាសាស្ត្រ ស្រាវជ្រាវ និងនវានុវត្តន៍នៃព្រះរាជាណាចក្រថៃ, ២) រវាងក្រសួងឧ.វ.ប.ន. និងសហគ្រាសចំនួន២០ ស្តីពីការអនុវត្តគម្រោង «កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (BEEP)» នៅតាមសហគ្រាសធុនតូច និងមធ្យម, ៣) រវាងអគ្គនាយកដ្ឋាន វ.ប.ន. នៃក្រសួងឧ.វ.ប.ន. និងស្ថាប័ននៃសាធារណរដ្ឋកូរ៉េ (The Korea Institute for Robot Industry Advancement), ៤) រវាងអគ្គនាយកដ្ឋាន វ.ប.ន. នៃក្រសួងឧ.វ.ប.ន. ជាមួយ ICP Hub of the Interlink FZE នៃប្រទេសសិង្ហបុរី និង៥)រវាងអគ្គនាយកដ្ឋាន វ.ប.ន. នៃក្រសួងឧ.វ.ប.ន. ជាមួយក្រុមហ៊ុន China-ASEAN Information Harbor Co., Ltd. នៃសាធារណរដ្ឋប្រជាមានិតចិន។

លើសពីនេះទៀត ក្រសួងក៏បាន៖ ១)រៀបចំទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើកទី២ អមជាមួយពិព័រណ៍បច្ចេកវិទ្យា និងគ្រឿងឧបករណ៍កម្មន្តសាល និងពិព័រណ៍វិទ្យាសាស្ត្រ, ២) រៀបចំសិក្ខាសាលាស្តីពី «ការអភិវឌ្ឍការភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាស ផ្តោតលើកាតាលីករនៅក្នុងគំរូត្រីវ័ណ្ណ សម្រាប់នវានុវត្តន៍ និងការអភិវឌ្ឍ», ៣) បានបិទបញ្ចប់គម្រោងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (BEEP) នៅខេត្តកំពង់ចាម, បាត់ដំបង និងខេត្តសៀមរាប និង៤) បានបិទបញ្ចប់គម្រោងស្តីពី «STI Coordination-Toyota Foundation» ក្រោមកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន-ថៃ។

ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២៤

កម្មវិធីអាស៊ានបូកបី វិថីអ្នកវិទ្យាសាស្ត្រវ័យក្មេងលើកទី១០ (APT JSO-10) ថ្ងៃទី២២-២៦ ខែកក្កដា

ក្រសួងឧស្សាហកម្ម និងក្រុមហ៊ុនរដ្ឋចិន CAIH ចុះអនុស្សរណៈដើម្បីជំរុញនវានុវត្តន៍បច្ចេកវិទ្យា

៨.៥. ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺជាដំណើរការមួយដែលមានគោលបំណងច្បាស់លាស់ សំដៅជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងផ្សេងៗឱ្យប្រសើរឡើង ដើម្បីធានាការសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុក តាមរយៈការគ្រប់គ្រងការតាមដានជាប្រចាំលើធាតុចូលសកម្មភាពដែលគាំទ្រធាតុចេញ ឬលទ្ធផលតាមឆ្នាំ និងវាយតម្លៃវឌ្ឍនភាពលទ្ធផលចុងក្រោយ និងផលជះនៃគោលនយោបាយនានា។ ដើម្បីធានាថាការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រព្រឹត្តទៅប្រកបដោយសុក្រឹតភាព និងតម្លាភាព ក្រសួងបានរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដូចខាងក្រោម ដែលក្នុងនោះរួមមាន៖

» របាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ ព្រមទាំងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០

» ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបៀបវារៈស្រាវជ្រាវជាតិ ២០២៥ ព្រមទាំងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបៀបវារៈស្រាវជ្រាវជាតិ

លើសពីនេះទៀត ក្រសួងបានផ្តួចផ្តើមលើការរៀបចំឯកសារទស្សនាទានស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីដឹកនាំការងារផ្តល់ទិន្នន័យអំពីប្រទេសកម្ពុជាសម្រាប់សន្ទស្សន៍នវានុវត្តន៍សកល, ឯកសារទស្សនទាន ស្តីពីការបង្កើតថ្នាលឌីជីថលសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, និងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីលក្ខណៈសម្បត្តិស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

៨.៦. ការងារគណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែក វ.ប.ន.

ក្រសួងបានរៀបចំកិច្ចប្រជុំស្តីពី «កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី២០ (AMMSTI-20), កិច្ចប្រជុំគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី៨៥ (COSTI-85) និងកិច្ចប្រជុំពាក់ព័ន្ធ» និងបានរៀបចំកម្មវិធីអាស៊ានបូកបី - វិថីនៃអ្នកវិទ្យាសាស្ត្រវ័យក្មេង (ASEAN Plus Three Junior Science Odyssey_AP JSO) ក្រោមមូលបទ «ជម្នះឧបសគ្គឆ្លើយតបនឹងបម្រាមរបស់អាកាសធាតុ (Racing Up Against Climate Change)» នៅខេត្តសៀមរាប។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី២០ (AMMSTI-20) ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ នៅក្រុងសៀមរាប

៨.៧. ការងារក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន.)

បានអនុម័ត និងដាក់ឱ្យដំណើរការជាផ្លូវការនូវឯកសារយុទ្ធសាស្ត្រសំខាន់ៗរួមមាន៖ ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបៀបវារៈស្រាវជ្រាវជាតិ និងគោលការណ៍ណែនាំស្តីពីសន្ទស្សន៍នវានុវត្តន៍សហគ្រាសកម្ពុជា ជាដើម។

ក.ជ.វ.ប.ន. ក្នុងសម័យប្រជុំថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ បានដាក់ចេញទិសដៅអាទិភាពចម្បងៗសម្រាប់វិស័យ វ.ប.ន. ស្របតាមផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ សំដៅជំរុញការអភិវឌ្ឍប្រទេសកម្ពុជា បង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិសំដៅការអភិវឌ្ឍប្រកបដោយចីរភាព និងការជំរុញកំណើនសេដ្ឋកិច្ចយ៉ាងគួរឱ្យទុកចិត្ត ដូចជា៖ ១) ពង្រឹងអភិបាលកិច្ចប្រព័ន្ធ វ.ប.ន., ២) កសាងមូលធនមនុស្សក្នុងវិស័យ វ.ប.ន., ៣) ពង្រឹងសមត្ថភាព និងគុណភាពស្រាវជ្រាវ និងអភិវឌ្ឍន៍, ៤) បង្កើនកិច្ចសហការ និងបណ្តាញរវាងតួអង្គពាក់ព័ន្ធ និង ៥) ជំរុញប្រព័ន្ធអេកូឡូស៊ីសម្រាប់ការទទួលយកបច្ចេកវិទ្យា។

៩. ការងារវិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ការងារវិទ្យាស្ថានជាតិជាមណ្ឌលនវានុវត្តន៍មានមុខងារផ្តល់ដំណោះស្រាយបច្ចេកទេស និងជួយដល់វិស័យឧស្សាហកម្ម សហគ្រាសធុនមីក្រូ តូច និងមធ្យម ឱ្យមានសមត្ថភាពប្រកួតប្រជែងទីផ្សារក្នុងតំបន់ និងអន្តរជាតិ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

ផ្អែកលើមូលដ្ឋាននេះ វិទ្យាស្ថានជាតិ បានកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍គឺ «សិក្សា ស្រាវជ្រាវ និងជំរុញលើកទឹកចិត្តឱ្យប្រើ

សកម្មភាពការងារ និងចែករំលែកចំណេះដឹង
របស់វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមន្ទីរពិសោធន៍ជាតិសំណង់

បច្ចេកវិទ្យា ឬបច្ចេកវិទ្យាឌីជីថល និងនវានុវត្តន៍ ក្នុងគោលដៅបម្រើឱ្យអន្តរវិស័យ ពិសេស វិស័យឧស្សាហកម្ម ៤.០ និងឧស្សាហកម្មជំនាន់ក្រោយបន្តបន្ទាប់ទៀត»។ ជាក់ស្តែង ក្នុងឆ្នាំ២០២៤ កន្លងមក បានទទួលលទ្ធផលដូចខាងក្រោម៖

៩.១. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍

- បានផលិតសម្ភារឧបទេសចំនួន ៤ មានដូចជា សម្ភារគំរូ «Sorting Fruits Prototype», សម្ភារគំរូ «Mini Wheel Robot», សម្ភារគំរូ «A 3D Educational Tool Prototype of Hand Crank Generator» និងឧបករណ៍គំរូ «liquid density experiment» ដើម្បីលើកកម្ពស់ការសិក្សាស្វែម
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវចំនួន ៣ មានដូចជា៖ ១) «TC Expert mission to conduct a scoping and need assessment for setting up food irradiation facility, EVT2400224» ២) «ការសិក្សាបឋមអំពីកត្តាប្រឈម និងតម្រូវការបច្ចេកវិទ្យា ក្នុងការកែច្នៃផលិតផលគ្រាប់ស្វាយចន្ទី ក្នុងសហគ្រាសធុនមីក្រូ តូច និងមធ្យម» និង ៣) «Characterization of Golden Sheet and Flora Foam Block»។

៩.២. ការងារបណ្តុះបណ្តាល ពិគ្រោះយោបល់ និងសិក្ខាសាលា

- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣ ដង៖ ១) ស្តីពីវិធីសាស្ត្រថែរក្សាគុណភាពអាហារ ដល់សហគ្រាសធុនតូច និងមធ្យម ២) ស្តីពីបច្ចេកទេសយកសំណាក និងវិភាគគុណភាពទឹក ដល់សហគ្រាសធុនតូច និងមធ្យម និងនិស្សិត និង៣) "ប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាពអាហារ" ដែលមានសិក្ខាកាមសរុប ចំនួន ១១៣ នាក់
- បានអង្កេតតម្រូវការ ការបណ្តុះបណ្តាល សហគ្រាសធុនតូច និងមធ្យមចំនួន ៨៣ សហគ្រាស នៅតាមបណ្តាខេត្ត និងរាជធានី
- បានរៀបចំវគ្គសិក្ខាសាលា ចំនួន ៨ ដងស្តីពី៖ ការផ្សព្វផ្សាយ និងជំរុញចំណាប់អារម្មណ៍សិស្សឱ្យចូលរួមផ្នែក វ.ប.ន. និងសុវត្ថិភាពអាហារ, Internet Computer Protocol (ICP) Blockchain, សារប្រយោជន៍នៃការចុះបញ្ជីវិស្វករនៅគណៈវិស្វករកម្ពុជា, មូលដ្ឋានគ្រឹះឧស្សាហកម្ម ៤.០, ការចែករំលែកចំណេះដឹង និងផ្តល់ការប្រឹក្សាអនុវត្តអនាម័យល្អ (GHP) និងផលិតកម្មល្អ (GMP) លើវិស័យម្ហូបអាហារសម្រាប់សហគ្រាធុនមីក្រូ តូច និងមធ្យម, ការចែករំលែកចំណេះដឹង និងការផ្តល់ប្រឹក្សាការអនុវត្តអនាម័យល្អ និងផលិតកម្មល្អ លើវិស័យម្ហូបអាហារសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម, ការបង្កើនការយល់ដឹងថ្នាក់ជាតិអំពីប្រព្រឹត្តកម្មវិទ្យុសកម្មពហុបំណងដោយបច្ចេកវិទ្យា E-Beam/X-ray, From Problematic Analysis to

Publication, From Problematic Analysis to Publication, ជំនាញអាហារូបត្ថម្ភសម្រាប់បុគ្គលិកអប់រំថ្នាក់ក្រោមជាតិ ដែលមានសិក្ខាកាមសរុប ចំនួន ១.០៦៧ នាក់។

៩.៣. កិច្ចសហប្រតិបត្តិការ

- បានសហការអនុវត្តគម្រោងចំនួន ៤ លើការគ្រប់គ្រងគុណភាព និងស្តង់ដាសុវត្ថិភាពអាហារសម្រាប់សហគ្រាសធុនតូច និងមធ្យម, ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ក្នុងប្រទេសកម្ពុជា ដែលមាន៖
  - » គម្រោងអភិវឌ្ឍន៍អាហារកម្ពុជាក្រោមកិច្ចសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ ២០២៣-២០២៧
  - » គម្រោង"Enhancing Nuclear Capacity for Cultural Heritage and Industrial Applications" ក្រោមកិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA) ២០២៤-២០២៥
  - » គម្រោង"Supporting the Adoption of E-Beam Technology and its Application in Areas of Food and Agriculture, Industry, Human Health and Environment Treatment", ក្រោមកិច្ចសហប្រតិបត្តិការ RCARO and NNSA/US-DoE ២០២៤-២០២៨
  - » គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផលដែលធន់នឹងច្រែះ និងសម្ភារដែលស្រាលហើយមានគុណភាពខ្ពស់ ២០២៤-២០២៥ (សហការជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)។
- បានបញ្ចប់គម្រោង Powering Southeast Asia's Future: Identifying and Overcoming Barriers to Implementation ក្រោមកិច្ចសហប្រតិបត្តិការ Japan-ASEAN Science, Technology and Innovation Platform (JASTIP) ២០២៣-២០២៤
- បានបញ្ចប់គម្រោង Establishment of Science, Technology and Innovation Club ក្រោមកិច្ចសហប្រតិបត្តិការ JASTIP, ២០២៣-២០២៤
- បានបញ្ចប់គម្រោង «ការអភិវឌ្ឍផលិតផលសាច់ក្រកត្រី » ក្រោមកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិ វ.ប.ន. សាកលវិទ្យាល័យស្វាយរៀង និងសិប្បកម្មកែច្នៃ សំណាង សុជា ក្រោមការឧបត្ថម្ភរបស់គម្រោង CAPFish, UNIDO
- បានបញ្ចប់គម្រោង «ការបង្កើនប្រសិទ្ធភាពការញែកត្រីដោយប្រើដញ្ជីងឌីជីថល» ក្រោមកិច្ចសហប្រតិបត្តិការ រវាងវិទ្យាស្ថានជាតិ វ.ប.ន. វិទ្យាស្ថានជាតិកសិកម្មព្រែកលាប និងសិប្បកម្មកែច្នៃ សំបុកត្រីធម្មជាតិ ក្រោមការឧបត្ថម្ភរបស់គម្រោង CAPFish, UNIDO

- បានចូលរួមប្រជុំជាមួយទីប្រឹក្សាបច្ចេកទេសគម្រោង និងក្រុមការងារ ក.ស.ន. លើការសិក្សាស្តីពី "Scoping and Need Assessment for Setting Up Food Irradiation Facility នៅតាមក្រសួងចំនួន៦ ក្រុមហ៊ុនឯកជនចំនួន ២ និងសាកលវិទ្យាល័យចំនួន ១
- បានរៀបចំជំនួបពិភាក្សាជាមួយក្រុមអ្នកជំនាញពីស្ថាប័ន Regional Cooperative Agreement Regional Office (RCARO)ជាមួយស្ថាប័នចំនួន ៤, ក្រុមហ៊ុនឯកជនចំនួន២ និងសាកលវិទ្យាល័យចំនួន ១។

៩.៤. ការងារជំរុញ និងផ្សព្វផ្សាយ

ការងារជំរុញការអភិវឌ្ឍ និងផ្សព្វផ្សាយការងារ វ.ប.ន. សម្រេចបានលទ្ធផល ដូចខាងក្រោម៖៖

» បានផលិតវីដេអូចំនួន ៨ អំពីសហគ្រាសអាហារដែលមានភាពជោគជ័យ តាមរយៈការគាំទ្រពីបច្ចេកវិទ្យា និងការចែករំលែកចំណេះដឹងអំពីការផលិតឧបករណ៍វិទ្យាសាស្ត្រ
» បានចងក្រងព្រឹត្តិបត្រព័ត៌មានប្រចាំខែរបស់វិទ្យាស្ថានជាតិ វ.ប.ន. ចំនួន ១២ លេខ
» បានរៀបចំទស្សនកិច្ចសិក្សា ស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅវិទ្យាស្ថានជាតិ វ.ប.ន. ចំនួន ៣ដង ដែលមានអ្នកចូលរួមសរុបចំនួន ៨៣នាក់
» បានផ្សព្វផ្សាយព័ត៌មានអំពី វ.ប.ន. ក្នុងបណ្តាញសង្គម Facebook និងTelegram
» បានសហការជាមួយសារមន្ទីរជាតិវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រថៃ សម្រាប់ការតាំងបង្ហាញពិព័រណ៍ឧបករណ៍ និងល្បែងកម្សាន្តបែបវិទ្យាសាស្ត្រ ក្នុងទិវាជាតិ វ.ប.ន. នៅមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមសរុបចំនួន ៣.០៩៨ នាក់
» បានចូលរួមតាំងបង្ហាញម៉ាស៊ីន 3D Printer និងសម្ភារឧបទេសផ្នែកស្នែមចំនួន ៤ ដង
» បានបោះពុម្ពកាលិកបត្រសរុបចំនួន ៧ ក្នុងស្រុកចំនួន ៤ និងអន្តរជាតិចំនួន ៣
» បានបោះពុម្ពទស្សនាវដ្តី វ.ប.ន. ចំនួន ២ លេខ។

១០. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ គឺជាកម្មវិធីទី៤ នៃកម្មវិធីគោលនយោបាយ អាទិភាពទាំង៦ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ យុទ្ធសាស្ត្រជាតិនេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ កន្លងទៅ។

ដើម្បីសម្រេចបានតាមផែនការយុទ្ធសាស្ត្រ គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (គ.ស.អ.ស.ក) បានសម្របសម្រួល ពង្រឹងការងារ និងបានរៀបចំកិច្ចសហការជាមួយក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត និងវិស័យឯកជន ជាពិសេសសមាគមដែលជាក្បាលម៉ាស៊ីនក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីចូលរួមការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងរៀបចំចុះឈ្មោះតាមថ្នាលឌីជីថល។ សមិទ្ធផលសម្រេចបាន ក្នុងឆ្នាំ២០២៤ មានដូចខាងក្រោម៖

១០.១. ក្របខណ្ឌគណៈកម្មាធិការសម្របសម្រួល

- បានចូលរួមពិនិត្យវិធានការគន្លឹះទី II.៩ ស្ថិតក្នុងឧបសម្ព័ន្ធទី៣ នៃយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដើម្បីរៀបចំបង្កើតបទដ្ឋានគតិយុត្ត ក្របខណ្ឌ និងយន្តការដែលផ្តល់ស្ថានភាពស្របច្បាប់ជាសហគ្រាសធុនមីក្រូ និងតូចដោយភ្ជាប់ជាមួយនឹងអត្ថប្រយោជន៍ផ្សេងៗ ដែលពាក់ព័ន្ធក្រសួង-ស្ថាប័នមួយចំនួនដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានពន្ធដារ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល
- បានជំរុញការអនុវត្តការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅថ្នាក់ក្រោមជាតិ និងពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់រដ្ឋបាលរាជធានី-ខេត្ត ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅតាមមូលដ្ឋានរបស់ខ្លួន
- បានសហការជាមួយក្រសួងព័ត៌មាន លើការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធសម្រាប់ក្រុមគោលដៅអ្នកសារព័ត៌មាន
- បានប្រជុំពិភាក្សាការងារជាមួយ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីបេឡាជាតិ សន្តិសុខសង្គម (ប.ស.ស.) ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកិច្ចសហការប្រទាក់ក្រឡារវាងអន្តរស្ថាប័ន
- បានពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សាពីវឌ្ឍនភាពការងារ និងកិច្ចសហការរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមានការចូលរួមពីតំណាង ក្រសួងឧ.វ.ប.ន. ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងធនាគារ SME និងលេខាធិការដ្ឋាន គ.ស.អ.ស.ក.
- បានរៀបចំអនុក្រឹត្យ ស្តីពីការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងត្រូវបានចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់ពី សម្តេចមហាបវរធិបតី នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤

- បានរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ដែលត្រូវបានសាធារណៈមតិជាតិ និងអន្តរជាតិគាំទ្រជាខ្លាំង។

១០.២. ក្របខណ្ឌក្រសួងឧ.វ.ប.ន. ក្នុងនាមជាសេនាធិការ

- បានចូលរួមរៀបចំថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល
- បានសហការជាមួយ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីរៀបចំផែនការ និងប្រភេទទិន្នន័យ Data Points សម្រាប់ដាក់បញ្ចូលទៅក្នុងថ្នាលឌីជីថល (Onboarding) សម្រាប់ចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បានសហការជាមួយវិស័យឯកជន ដែលរួមមាន៖ ក្រុមហ៊ុនសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធ PassApp, Grab, WeGo, LM Car, TADA, FoodPanda, WowNow, Nham24, Grabfood, E-gets និង BLOC, សមាគមរួមគ្នាដើម្បីអភិវឌ្ឍកម្ពុជា, សមាគមវិនិយោគិន នវានុវត្តន៍ និងអភិវឌ្ឍន៍, និងក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនសរុបចំនួន ៣០ក្រុមហ៊ុន ដើម្បីពិភាក្សាអំពីការជំរុញអ្នកដឹកជញ្ជូនក្រៅប្រព័ន្ធ ឱ្យចុះឈ្មោះជាសមាជិកនៃអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បានប្រជុំឆ្លងរបាយការណ៍វាយតម្លៃផលប៉ះពាល់ (RIA) លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការចុះឈ្មោះអ្នកសេដ្ឋកិច្ច ក្រៅប្រព័ន្ធជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ - ក្រុម២
- បានចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន១.១៨៥នាក់ ក្នុងនោះបានចុះឈ្មោះជាកម្មករនិយោជិត ចំនួន ១៦៨នាក់ សហគ្រាសធុនមីក្រូចំនួន ១៥៩នាក់ និងបុគ្គលស្វ័យនិយោជន៍ចំនួន ៨៥៨នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
- **ការសហការជាមួយដៃគូអភិវឌ្ឍន៍៖** បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ UNDP, ILO, CAPRED រៀបចំក្របខណ្ឌ និងប្រព័ន្ធ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨។

១១. ការងារកិច្ចការទូទៅ

១១.១. ការងាររដ្ឋបាល

ក្រសួងបានយកចិត្តទុកដាក់លើការកែទម្រង់ប្រព័ន្ធរដ្ឋបាលផ្ទៃក្នុងឱ្យកាន់តែមានរបៀបរៀបរយប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មន្ទីររាជធានី-ខេត្ត ដូចជា៖

» បានដាក់ឱ្យអនុវត្តប្រព័ន្ធទំនាក់ទំនងបែបឌីជីថល (E-Doc) ដោយកាត់បន្ថយការប្រើប្រាស់ឯកសារជាប្រភេទក្រដាសក្នុងការទំនាក់ទំនង និងការបញ្ជូនឯកសារ
» សម្របសម្រួលប្រមូលផ្តុំ ចងក្រង បូកសរុបរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ក្រសួង ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រីបានទៀងទាត់ និងទាន់កាលបរិច្ឆេទកំណត់របស់ទីស្តីការគណៈរដ្ឋមន្ត្រី
» បានចូលរួមសម្របសម្រួលសកម្មភាពការងារផ្នែករដ្ឋបាលជាមួយអង្គភាពចំណុះ មន្ទីរ ឧ.រ.ប.ន រាជធានី-ខេត្ត និងក្រសួង-ស្ថាប័ន ពាក់ព័ន្ធ
» បានសម្របសម្រួលលើលិខិតចូលចំនួន ៤.៧២៣ ច្បាប់ និងលិខិតចេញចំនួន ៨.៦៧៦ លេខ

១១.២. ការងារបុគ្គលិក

ការអភិវឌ្ឍធនធានមនុស្ស គឺជាផ្នែកមួយនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងជាអាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់ៗទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងនោះក្រសួងបានអនុវត្តការងារសម្រេចបានលទ្ធផលដូចខាងក្រោម៖

ល.រ	ប្រភេទការងារ	ចំនួន (នាក់)
១	តែងតាំង ផ្ទេរ សម្រួល និងប្រគល់ភារកិច្ច (ក្រសួង និងមន្ទីរ)	១០៦
២	ផ្ទេរក្របខណ្ឌចេញ	៣
៣	ទទួលស្គាល់ក្របខណ្ឌ	៥
៤	តាំងស៊ប់	៤៨
៥	**បានរៀបចំសំណើសុំគ្រឿងឥស្សរិយយស/មេដាយការងារ**	
	ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ	១៨៣
	និយោជិតរដ្ឋាករទឹកស្វយ័តទាំងអស់	២០៨

៦	**ការងារបណ្តុះបណ្តាល**	
	បណ្តុះបណ្តាលក្នុងប្រទេស	១៧៨
	បណ្តុះបណ្តាលក្រៅប្រទេស	៧៤
	ការចាត់មន្ត្រីចូលរួមក្នុងយន្តការក្នុងប្រទេស	៨២៣
	ការចាត់មន្ត្រីចូលរួមក្នុងយន្តការក្រៅប្រទេស	២៥៨
	ការចុះកម្មសិក្សារបស់សិស្ស និស្សិតតាមសាកលវិទ្យាល័យ	២
៧	**ការងារដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការ**	
	តាមវេន	
	អតីតភាពការងារ (២ឆ្នាំម្តង)	៦២២
	តាមកម្រិតសញ្ញាបត្រ	៥២
	ករណីពិសេសមុនពេលចូលនិវត្តន៍	១៨
៨	**មន្ត្រីចូលនិវត្តន៍**	
	តាមកាលកំណត់	១៨
	មុនកាលកំណត់	៧
៩	**លុបឈ្មោះចេញពីក្របខណ្ឌ**	
	លាឈប់ពីការងារសុំប្រាក់ឧបត្ថម្ភ	៤
	មរណភាព	២
១០	ទំនេរគ្មានបៀវត្ស	៤២
១១	អនុញ្ញាតិឱ្យចូលបម្រើការងារវិញ	៤
១២	ក្រៅក្របខណ្ឌដើម	៣

» បានពង្រឹងសមត្ថភាពជំនាញដល់មន្ត្រី ដើម្បីលើកកម្ពស់គុណភាពការងារ ដោយផ្តោតលើវិន័យ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងគោលដៅប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យអស់លទ្ធភាព

» បានធ្វើការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ពង្រឹងប្រព័ន្ធគ្រប់គ្រងវត្តមាន និងស្ថានភាពមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

» បានដាក់ចេញនូវប្រព័ន្ធលើកទឹកចិត្ត តាមរយៈការកំណត់សូចនាករសមិទ្ធកម្មរបស់មន្ត្រី (KPI) ដើម្បីធានាថាការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ

» បានពង្រឹងសមត្ថភាពជំនាញដល់មន្ត្រី ដើម្បីលើកកម្ពស់គុណភាពការងារ ដោយផ្តោតលើវិន័យ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងគោលដៅប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យអស់លទ្ធភាព។

១១.៣. ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- បានប្រតិភូកម្មសិទ្ធអំណាច និងមុខងារក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ដល់អង្គភាពក្រោមឱវាទ និងបានរៀបចំប្រែក្លាយអង្គភាពថវិកាចំនួន ៣៤ ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញតាមប្រកាសអន្តរក្រសួងលេខ ៣៤៩ សហវ.ប្រក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤
- បានបើកគណនីគោលជាប្រាក់រៀលនៅធនាគាររីង (ខេមបូឌា) និងធនាគារកាណាឌីយ៉ា ដើម្បីចូលរួមការអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធតាម (E-payment) និង KHQR Code ដោយមិនអនុញ្ញាតឱ្យមានការទូទាត់កម្រៃសេវាជាសាច់ប្រាក់
- បានប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការបើកប្រាក់បេសកកម្ម និងប្រាក់រង្វាន់ផ្សេងៗ
- បានកាត់បន្ថយគម្លាតរវាងផែនការចំណូល-ចំណាយប្រចាំត្រីមាសនីមួយៗ និងការអនុវត្តន៍ជាក់ស្តែងក្នុងរង្វង់ (+/-) ៥% យ៉ាងមានប្រសិទ្ធភាព
- បានអនុវត្តប្រព័ន្ធ NRMIS ប្រកបដោយភាពរលូនក្នុងការគ្រប់គ្រង និងការកត់ត្រាចំណូល
- បានអនុវត្តប្រព័ន្ធ SARMIS លើការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានស្នើសុំចុះបញ្ជីដី និងធ្វើវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋចំនួន ៣១ទីតាំង ក្នុងនោះទទួលបានប័ណ្ណកម្មសិទ្ធិចំនួន ១០ទីតាំង និងបានចុះកំណត់ព្រំដីចំនួន ៥ ទីតាំង
- បានអនុវត្តវិធានការកែលម្អប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តថវិកា រួមទាំងយន្តការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីតាមដានការប្រើប្រាស់ថវិកា និងរបាយការណ៍សមិទ្ធកម្ម
- បានកែសម្រួលកម្រងសេវាសាធារណៈ ក្នុងនោះមាន សម្រួលឈ្មោះសេវាចំនួន ៥០សេវា បញ្ចុះតម្លៃចំនួន ៦០សេវា បង្កើតសេវាថ្មីចំនួន ៣៦សេវា និងលុបចេញចំនួន ១៦សេវា
- បានបំពេញកាតព្វកិច្ចបង់វិភាគទានសមាជិកភាពជូនអង្គការអន្តរជាតិចំនួន ១២
- បានសម្រេចឱ្យរក្សាប្រាក់រង្វាន់ជាភាគលាភរបស់ក្រសួង សម្រាប់ដំណើរការអង្គភាពរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី-ខេត្ត ដើម្បីគាំទ្រការងាររ៉ែមជ្ឈការ និងវិសហមជ្ឈការ (លិខិតលេខ ២៦៦៥ ឧវបន.គហ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤)
- បានអនុវត្តថវិកាឆ្នាំ២០២៤ តាមគោលការណ៍ណែនាំ និងនីតិវិធីហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដោយបានអនុវត្តលើការងារចំណូលចំណាយដូចខាងក្រោម៖

ចំណូល និងចំណាយប្រចាំឆ្នាំ២០២៤			
ល.រ.	បរិយាយ		ទឹកប្រាក់ (រៀល)
	អំពីចំណូល		
១	ជំពូក៧៣ ផលទុនពីការលក់ជួលទ្រព្យសម្បត្តិ និងសេវា	ចំនួន	១៣.៩៣៣.៧៩៧.៥៤៩
២	ជំពូក៧៤ ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម	ចំនួន	១.២៦៧.០០០
៣	ជំពូក៧៧ ផលផ្សេងៗ និងផលពិសេស	ចំនួន	៣.៥៥៥.៧៥០
	ចំណូលថវិកាជាតិ	**សរុបរួម**	**១៣.៩៣៨.៦២០.២៩៩**
	អំពីចំណាយ		
១	ជំពូក៦០ ការទិញ	ចំនួន	៦.៧១៥.០១៩.២៦៤
២	ជំពូក៦១ សេវាកម្ម	ចំនួន	១១.៩៥៣.០៩៤.៣៣២
៣	ជំពូក៦៣ ពន្ធ និងអាករ	ចំនួន	១៥.៩៨០.០០០
៤	ជំពូក៦៤ បន្ទុកបុគ្គលិក	ចំនួន	២៥.០២១.០១៣.៤៤១
៥	ជំពូក៦៥ ឧបត្ថម្ភធន	ចំនួន	៣៩០.១៨៨.៤២៦
	ចំណាយ	**សរុបរួម**	**៤៤.០៩៥.២៩៥.៤៦៣**

១១.៤. ការងារនីតិកម្ម

- តាមដាន ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពកែតម្រូវលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទាំងឡាយណាដែលមិនឆ្លើយតបទៅនឹងការវិវត្តរបស់សង្គម
- ពិនិត្យ ពិភាក្សា កែសម្រួលផ្តល់ធាតុចូល និងធ្វើបច្ចុប្បន្នភាពជាមួយទីស្តីការគណៈរដ្ឋមន្ត្រី និងអន្តរក្រសួង លើសេចក្តីព្រាងច្បាប់ចំនួន៨, សេចក្តីព្រាងវិសោធនកម្មព្រះរាជក្រឹត្យចំនួន២, សេចក្តីព្រាងអនុក្រឹត្យចំនួន ១០, សេចក្តីព្រាងគោលការណ៍ការណែនាំចំនួន៣, សេចក្តីព្រាងប្រកាសចំនួន៤, សេចក្តីព្រាងសេចក្តីសម្រេចចំនួន១ និងសេចក្តីព្រាងសារាចរចំនួន១ ដែលមានលម្អិតដូចក្រោម៖
    - » សេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីច្បាប់គ្រប់គ្រងរោងចក្រ និងសិប្បកម្ម
    - » សេចក្តីព្រាងច្បាប់ ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
    - » សេចក្តីព្រាងច្បាប់ ស្តីពីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
    - » សេចក្តីព្រាងច្បាប់ ស្តីពីច្បាប់ភូមិបាល(ថ្មី)
    - » សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម
    - » សេចក្តីព្រាងច្បាប់ ស្តីពីផលផល

» សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
» សេចក្តីព្រាងច្បាប់ ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក
» សេចក្តីព្រាងវិសោធនកម្មព្រះរាជក្រឹត្យ ស្តីពី សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
» សេចក្តីព្រាងព្រះរាជក្រឹត្យកែសម្រួលព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រង ធនធានខ្សាច់
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតកំពង់ផែពហុបំណង កំពត
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការវិនិយោគសាធារណៈ (ថ្មី)
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងការស្រាវជ្រាវ និងអភិវឌ្ឍន៍
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតមូលនិធិស្រាវជ្រាវជាតិ ជាបរធនបាលកិច្ច
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ថ្មី)។
» សេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
» សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីសុវត្ថិភាពឧស្សាហកម្ម សម្រាប់តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម រោងចក្រសហគ្រាស
» សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
» សេចក្តីព្រាងគោលការណ៍ណែនាំអន្តរក្រសួង ស្តីពីការអនុវត្តការងារមាត្រាសាស្ត្រផ្នែកជញ្ជីងមិនស្វ័យប្រវត្តិដែលមានទម្ងន់ត្រឹម ១.០០០គីឡូក្រាមចុះក្រោម
» សេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌយោងការងាររបស់ក្រុមប្រឹក្សាស្តង់ដាជាតិ
» សេចក្តីព្រាងប្រកាស ស្តីពីស្តង់ដាកម្ពុជា CS 552:2024 សម្រាប់ស្រាអង្ករ
» សេចក្តីព្រាងប្រកាស ស្តីពីស្តង់ដាកម្ពុជា CS 553:2024 ក្រមអនុវត្តល្អសម្រាប់ស្រាអង្ករ
» សេចក្តីព្រាងប្រកាស ស្តីពីបទប្បញ្ញត្តិបច្ចេកទេស CTR 150:2024 សម្រាប់សារធាតុមេតាណុលក្នុងស្រាអង្ករ
» សេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការស្រាវជ្រាវ និងអភិវឌ្ឍន៍

» សេចក្ដីព្រាងសារាចរ ស្ដីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង-ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ។

១១.៥. ការងារផែនការ ស្ថិតិ សហប្រតិបត្តិការ និងអាស៊ាន

- បានពង្រឹងសមត្ថភាពរបស់អង្គភាពទទួលបន្ទុកការងារផែនការ ស្ថិតិ ដែលជំរុញដល់ការគ្រប់គ្រង និងប្រមូល ទិន្នន័យ ដើម្បីគាំទ្រដល់ការរៀបចំ និងអភិវឌ្ឍគោលនយោបាយផ្អែកលើភស្តុតាង និងសមិទ្ធផល
- បានសម្របសម្រួលជាមួយអាស៊ាន និងដៃគូអន្តរជាតិផ្សេងទៀត ក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាអនុលោមភាព និងប្រទាក់ក្រឡាគ្នា។
- បានសម្របសម្រួលរៀបចំយុទ្ធសាស្ត្រជាតិ ស្ដីពីការលើកកម្ពស់អាជីវកម្មបរិយាបន្ននៅកម្ពុជា (EBeeC) ឆ្នាំ២០២៤-២០២៥ ជាភាសាខ្មែរ និងភាសាអង់គ្លេស
- បានចូលរួមពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០
- បានធ្វើការពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យទឹកស្អាត និងវិស័យពាក់ព័ន្ធដទៃទៀត ដូចជា វិស័យសិប្បកម្ម វិស័យស្តង់ដា និងមាត្រាសាស្ត្រ
- សហការសម្របសម្រួល និងពិភាក្សាលើសេចក្តីព្រាងសូចនាករសមិទ្ធកម្មគន្លឹះតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១
- បានចូលរួមតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ របស់វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យទឹកស្អាត និងវិស័យពាក់ព័ន្ធដទៃទៀតដូចជាវិស័យសិប្បកម្ម វិស័យស្តង់ដា និងមាត្រាសាស្ត្រ ប្រចាំ ឆ្នាំ២០២៤
- បានពង្រឹងសមត្ថភាពរបស់អង្គភាពទទួលបន្ទុកការងារផែនការ ស្ថិតិ ដែលជំរុញដល់ការគ្រប់គ្រង និងប្រមូលទិន្នន័យ ដើម្បីគាំទ្រដល់ការរៀបចំ និងអភិវឌ្ឍគោលនយោបាយផ្អែកលើភស្តុតាង និងសមិទ្ធផល
- បានសម្របសម្រួលជាមួយអាស៊ាន និងដៃគូអន្តរជាតិផ្សេងទៀត ក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាអនុលោមភាព និងប្រទាក់ក្រឡាគ្នា
- បានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សរុបមានចំនួន ៤១ គម្រោង (គម្រោងកំពុងអនុវត្តន៍មានចំនួន ៣៦ គម្រោងផ្អាកសកម្មភាព និងបានបញ្ចប់មានចំនួន ៥ គម្រោង) និងសំណើគម្រោងថ្មីមានចំនួន ៣១ គម្រោង។

១២. ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០២៤ អគ្គាធិការដ្ឋានបានអនុវត្តការងារចរន្តជាប្រចាំ ចូលរួមក្នុងសកម្មភាពការងារផ្សេងៗ ដូចជា៖

- ការពិនិត្យកែសម្រួលបូកសរុបរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គាធិការដ្ឋាន សម្រាប់សន្និបាតបូកសរុបលទ្ធផល ការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ នាពេលខាងមុខ
- ការពិនិត្យកែសម្រួលតួនាទី និងភារកិច្ចរបស់អគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីកុំឱ្យមានការជាន់ភារកិច្ចគ្នា ក្នុងការចុះត្រួតពិនិត្យលើការងារដឹកនាំ គ្រប់គ្រងនៅតាមបណ្តាមន្ទីរឧ.វ.ប.ន
- ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញការងារអធិការកិច្ច និងក្របខណ្ឌសវនកម្មផ្ទៃក្នុង
- បានចុះធ្វើអធិការកិច្ចចម្រុះតាមបណ្តារោងចក្រ សហគ្រាស និងសិប្បកម្ម រាជធានីភ្នំពេញ
- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ពាក់ព័ន្ធសេចក្តីព្រាងអនុក្រឹត្យរវាងអគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានសវនកម្ម
- បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រង នៅតាមបណ្តាមន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត។

សកម្មភាពចុះអធិការកិច្ចតាមបណ្តាមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៣. ការងារយេនឌ័រ

ឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក៏ដូចជាថ្នាក់ដឹកនាំក្រសួង បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២៣-២០២៨ ដូចខាងក្រោម៖

- » បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីផែនការយុទ្ធសាស្ត្របញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្ន សង្គម ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ឆ្នាំ២០២៣-២០២៨
- » បានប្រជុំជាមួយតំណាងនារីនៅតាមនាយកដ្ឋាន/មជ្ឈមណ្ឌល ដើម្បីបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ របស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍
- » បានរៀបចំពិធីបោះឆ្នោតជ្រើសរើសប្រធានសាខាសមាគមនារីក្រសួងអាណត្តិថ្មីឆ្នាំ ២០២៤-២០២៨
- » បានរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៣ ទិវាអន្តរជាតិនារី៨ មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ **"ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល"**
- » បានសម្របសម្រួលក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង "ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ក្នុងឧស្សាហកម្មបៃតង"
- » បានចូលរួមអនុវត្តគម្រោង "ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីក្នុងឧស្សាហកម្មបៃតង" ដោយមានការសហការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយអង្គការ UNIDO និងក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់សហព័ន្ធអាល្លឺម៉ង់
- » បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយបញ្ហាយេនឌ័រ នៅសណ្ឋាគារហាយ៉ាត់រីជេនស៊ី ដែលមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានអ្នកចូលរួមពីក្រសួងឧ.វ.ប.ន. ប្រមាណ ៥០នាក់។
- » បានរៀបចំសិក្ខាសាលា ស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅសណ្ឋាគារហាយ៉ាត់រីជេនស៊ី ដែលមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានអ្នកចូលរួមពីក្រសួង ឧ.វ.ប.ន. ប្រមាណ ៥០នាក់ ។
- » បានជួបពិភាក្សាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្តីពីលទ្ធភាពនៃការលើកគម្រោងដើម្បីលើកស្ទួយស្ត្រីក្នុងវិស័យស្ទែម (Women in STEM)
- » បានរៀបចំសំណើសុំអនុវត្តគម្រោង និងបានធ្វើបទបង្ហាញ ស្តីពីការកសាងសមត្ថភាពស្ត្រីសម្រាប់ឧស្សាហកម្ម បៃតង ជូនភាគីអាល្លឺម៉ង់ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- » បានរៀបចំផែនការសកម្មភាពសម្រាប់ ១ឆ្នាំ, ៣ឆ្នាំ និង ៥ឆ្នាំ ទៅតាមគំរូ

ពិធីប្រគល់លិខិតសរសើរ
ជូនដល់មន្ត្រីសាធារណៈ និងសហគ្រិនស្ត្រីដែលបានចូលរួមអនុវត្តគម្រោង
លើកស្ទួយភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងឧស្សាហកម្មបៃតង
ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
FASMEC

PIB
Joint Quality Talk Workshop
The Importance of QI Services

សិក្ខាសាលាស្តីពី
ADB

CAMBODIA WOMEN ENTREPRENEURS DAY
WOMEN
EMPOWERMENT
IN GREEN ECONOMY
កិច្ចពិភាក្សា ប្រធានបទ៖ ជំហានដំបូងក្នុងការឈានជើងទៅកាន់សេដ្ឋកិច្ចបៃតង

» បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបសមភាពយេនឌ័រ ជនមានពិការភាព និងបរិយាបន្នសង្គម ២០២៣-២០២៨ ដែលមានអ្នកចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ និងវិស័យឯកជនប្រមាណ ១០០ នាក់

» បានរៀបចំការប្រកួតប្រជែងជ្រើសរើសស្ត្រីឆ្នើម ដែលបានចូលរួមក្នុងការអនុវត្តគម្រោងពង្រឹងភាពអង់អាចសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យឧស្សាហកម្មបៃតង និងបានផ្តល់ពានរង្វាន់ជ័យលាភីដល់ថ្នាក់ដឹកនាំជាស្ត្រី

» បានសហការជាមួយសមាគមសហគ្រិនស្ត្រីកម្ពុជា រៀបចំទិវាសហគ្រិនស្ត្រីកម្ពុជា មានប្រធានបទ«ការពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ចបៃតង »

» បានធ្វើការសិក្សាសមិទ្ធិលទ្ធភាពស្តីពីការបញ្ជ្រាបសមាសធាតុយេនឌ័រ និងសេដ្ឋកិច្ចបៃតងទៅគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

» បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការសិក្សាសមិទ្ធិលទ្ធភាពស្តីពីការបញ្ជ្រាបសមាសធាតុយេនឌ័រ និងសេដ្ឋកិច្ចបៃតងទៅគោលនយោបាយវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ដែលមានអ្នកចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ និងវិស័យឯកជន ប្រមាណ ៦៣ នាក់

» បានចុះអនុស្សារណៈនៃការយោគយល់ ជាមួយ CAPRED អំពីលទ្ធភាពនៃការអនុវត្តគម្រោងសាកល្បងស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ ជាមួយអគ្គនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងអគ្គនាយកដ្ឋានទឹកស្អាត

» បានចូលរួមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងការអនុវត្តឧស្សាហកម្មបៃតង ដែលឆ្លើយតបនឹងយេនឌ័រឱ្យកាន់តែប្រសើរឡើង ដែលរៀបចំឡើងដោយក្រសួងកិច្ចការនារីនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី

» បានចែករំលែកបទពិសោធនៃការវិភាគទិន្នន័យ និងការរៀបចំគោលនយោបាយ ដល់សមាជិកលេខាធិការដ្ឋាន និងមន្ត្រីស្ម័គ្រចិត្ត

» បានចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលា ពាក់ព័ន្ធទៅនឹងការបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃ។

ទន្ទឹមនេះដែរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបន្តយកចិត្តទុកដាក់ដល់ការផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប ស្ត្រីមេម៉ាយ ជនចាស់ជរា ជនមានពិការភាព ដោយផ្តល់លទ្ធភាពបង់រំលោះ និងប្រាក់ឧបត្ថម្ភធន (៣០%, ៥០%, ៧០% និង ១០០%) មានចំនួន ២២.៩៣៣ បណ្តាញ ក្នុងនោះអតិថិជនដែលមានចំណូលទាបបានឧបត្ថម្ភធន៣០% មានចំនួន ២០១បណ្តាញ, ឧបត្ថម្ភធន៥០% មានចំនួន ៨៧៤បណ្តាញ,

ឧបត្ថម្ភធន៧០% មានចំនួន ៤៦៤បណ្តាញ, ឧបត្ថម្ភធន១០០% មានចំនួន៣៥៤បណ្តាញ និងឧបត្ថម្ភដល់ស្ត្រីមេម៉ាយមានចំនួ១៩បណ្តាញ។ សម្រាប់កម្មករ កម្មការិនី និស្សិតស្នាក់នៅតាមបន្ទប់ជួល បានចំនួន ១០៨.៩៩០បណ្តាញ និងធ្វើកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួលបានចំនួន ៤.៧៣០បណ្តាញ ដើម្បីជួយបន្ធូរបន្ថយថ្លៃទឹករបស់ពួកគាត់។

១៤. ការងារមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី-ខេត្ត

១៤.១. ការងារឧស្សាហកម្ម និងសិប្បកម្ម

» បានសហការជាមួយអាជ្ញាធរមូលដ្ឋានផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនរោងចក្រ សហគ្រាស និងសិប្បកម្ម និងនីតិវិធីនៃការស្នើសុំចុះបញ្ជីរោងចក្រ សហគ្រាស និងសិប្បកម្ម
» បានផ្សព្វផ្សាយ និងពន្យល់ណែនាំអំពីវិធីសាស្ត្រ ស៥(5S), ខាយហ្សិន ជូនដល់សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម
» បានសហការជាមួយអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យការងារប្រតិភូកម្មការចុះបញ្ជីសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ជូនអង្គភាពច្រកចេញចូលតែមួយ និងមន្ត្រីភ្នាក់ងារទទួលបន្ទុកការងារឧស្សាហកម្ម និងសិប្បកម្ម
» បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការសហគ្រាសធុនតូច និងសិប្បកម្ម
» បានចុះត្រួតពិនិត្យខ្សែច្រវាក់ផលិតកម្មតាមទីតាំងសិប្បកម្មដែលមានហានិភ័យ ក្នុងគោលបំណងពង្រឹងគុណភាព និងបរិមាណ
» បានចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងឧស្សាហកម្ម និងសិប្បកម្ម ជាមួយអគ្គនាយកដ្ឋានជំនាញ

ដោយឡែក មន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មរួមមាន៖

» រោងចក្រធុនធំមានចំនួន ២.៣៨៤ រោងចក្រ
» សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មមានចំនួន ៣.១១៨ មូលដ្ឋាន
» សិប្បកម្មមានចំនួន ៣២.៧៤៣ មូលដ្ឋាន
» ទីតាំងផលិតអំបិល មានចំនួន ៥០ទីតាំង និងអាចផលិតអំបិលក្នុងឆ្នាំ២០២៤ កន្លងមកសរុបបានចំនួន ១៣៦.៧១០ តោន។

១៤.២. ការងារទឹកស្អាត

» បានផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងទឹកស្អាត
» បានចុះត្រួតពិនិត្យ វាយតម្លៃ និងអធិការកិច្ចលើការស្នើសុំវិញ្ញាបនបត្រដំណើរការអាជីវកម្មទឹកស្អាត
» បានចុះពិនិត្យទីតាំងសម្រាប់ដាក់វ៉ានបង្គោលអគ្គីភ័យជាមួយក្រុមហ៊ុនទឹកស្អាតនៅតាមបណ្តាខេត្ត
» បានជួបប្រជុំពិភាក្សាជាមួយម្ចាស់អាជីវកម្មទឹកស្អាត ដើម្បីត្រៀមបម្រុងប្រភពទឹកសម្រាប់រដូវប្រាំង
» បានចូលរួមជាមួយអគ្គនាយកដ្ឋានទឹកស្អាត និងសមាគមទឹកស្អាតនៅកម្ពុជា ហ្វឹកហ្វឺនលើបច្ចេកទេសនៃការផលិតទឹកស្អាត

ដោយឡែក មន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពរដ្ឋាករទឹកសាធារណៈ និងអាជីវកម្មទឹកឯកជន សរុបចំនួន ៤៧៩ ទីតាំង។

១៤.៣. ការងារស្តង់ដា និងមាត្រាសាស្ត្រ

- បានផ្សព្វផ្សាយច្បាប់មាត្រាសាស្ត្រ និងស្តង់ដាកម្ពុជា នៅតាមរោងចក្រ សហគ្រាស និងសិប្បកម្មក្នុងរាជធានី-ខេត្ត
- បានចុះត្រួតពិនិត្យគុណភាពផលិតផល ផ្ទៀងផ្ទាត់ទំនិញវេចខ្ចប់ និងទំនិញផលិត នៅតាមរោងចក្រ សហគ្រាស និងសិប្បកម្ម
- បានចុះត្រួតពិនិត្យដៃបាញ់ប្រេងនៅតាមស្ថានីយ៍ប្រេងឥន្ធនៈនៅទូទាំងរាជធានីខេត្ត
- បានចុះត្រួតពិនិត្យជញ្ជីងថ្លឹងរថយន្ត និងដោះស្រាយបញ្ហាប្រឈម ដែលបានលើកឡើងក្នុងវេទិកាសាធារណៈពាក់ព័ន្ធនឹងការចុះត្រួតពិនិត្យជញ្ជីងថ្លឹងរថយន្ត ដោយសហការជាមួយមន្ត្រីជំនាញរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានចុះត្រួតពិនិត្យ និងតំឡើងជញ្ជីងគំរូនៅតាមបណ្តាផ្សារនានាក្នុងរាជធានី-ខេត្ត
- បានចុះត្រួតពិនិត្យ និងវាយតម្លៃទីតាំងសហគ្រាស សិប្បកម្មស្នើសុំសញ្ញាស្តង់ដា(CS)កម្រិតបឋម
- បានចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីរបស់រោងចក្រ និងសហគ្រាសក្នុងមូលដ្ឋានខេត្ត។

ដោយឡែក មន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពការងារមាត្រាសាស្ត្រ រួមមាន៖
» ដៃបាញ់ប្រេងមានចំនួន ៣៦.២៥៦ ដៃ
» ដៃរវៃបូមប្រេងមានចំនួន ៤៤០ ដៃ

» ជញ្ជីងតោនមានចំនួន ១.០៨៩ ជញ្ជីង
» ជញ្ជីងថ្លឹងវត្ថុមានតម្លៃមានចំនួន ១.៩៣៤ គ្រឿង
» ជញ្ជីងធម្មតាមានចំនួន ២១.៩០៧ គ្រឿង
» ទំនិញផលិត និងទំនិញវេចខ្ចប់មានចំនួន ២.៤៨៧ មូលដ្ឋាន។

១៤.៤. ការងារវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះយកគំរូសំណាកផលិតផល ចំណីអាហារ ភេសជ្ជៈ ទឹក ទៅវិភាគនៅមន្ទីរពិសោធន៍ជាតិ វ.ប.ន.
- បានសហការជាមួយអគ្គនាយកដ្ឋានវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ រៀបចំសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ និងដាក់ឱ្យដំណើរការសាកល្បង «ប្រព័ន្ធឆ្លាតវៃ» នៃគម្រោង «ការចាប់បច្ចេកវិទ្យារបស់សហគ្រាសធុនតូច និងមធ្យម ដើម្បីមានភាពធន និងទីផ្សារប្រកួតប្រជែង»
- បានបំពាក់នូវឧបករណ៍ពិសោធន៍ចំនួន ២៤ នៅខេត្តមណ្ឌលគិរី
- មន្ទីរ ឧ.វ.ប.ន. ខេត្តមណ្ឌលគិរី មានសមត្ថភាពធ្វើតេស្តបានចំនួន ២០ប៉ារ៉ាម៉ែត្រ ដោយផ្តោតសំខាន់លើ ប្រភពទឹកស្អាតដែលឆ្លងកាត់ប្រព្រឹត្តកម្ម និងផលិតផលចំណីអាហារដែលកំពុងផលិតក្នុងខេត្ត។

ដោយឡែក មន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពចុះយកសំណាកដើម្បីបញ្ជូនទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ជាតិ វ.ប.ន. មាន៖

» សំណាកជបចំនួន ១.៤១៦ សំណាក
» សំណាកទឹកស្អាតចំនួន ១.០៧៨ សំណាក
» សំណាក់ទឹកកកចំនួន ៥៤៨ សំណាក
» សំណាកចំណីអាហារចំនួន ១.៦៥៨ សំណាក
» សំណាកផលិតផលចំនួន ២០៧ សំណាក។

១៥. សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

បន្ទាប់ពីបានរៀបចំឡើងវិញរួចរាល់នូវមន្ត្រីចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី-ខេត្ត តាមការកំណត់របស់រាជរដ្ឋាភិបាល ដោយចាប់ពីដើមឆ្នាំ២០២៤មក ថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលសំខាន់ៗរបស់ក្រសួង បានចូលរួម និងចុះបំពេញការងារក្នុងក្រុមការងាររាជរដ្ឋាភិបាលនៅតាមមូលដ្ឋានតាមមុខសញ្ញារៀងៗខ្លួន។ ជាក់ស្តែងនៅគ្រប់រាជធានី-ខេត្ត សុទ្ធតែមានមន្ត្រីតំណាងក្រសួង ចាប់ពីថ្នាក់រដ្ឋមន្ត្រី ដល់ថ្នាក់

អគ្គនាយករង និងទីប្រឹក្សា ចូលរួមក្នុងសមាសភាពក្រុមការងារមានចំនួនសរុប ៩៦នាក់ ដែលក្នុងនោះគិតតែក្នុងខេត្តបាត់ដំបងមួយ បានចូលរួមចំនួន ៤៨ នាក់។ រីឯនៅក្នុងឆ្នាំ២០២៤ ក៏មានការចាត់តាំងបំពេញបន្ថែមមន្ត្រីក្រសួងចំនួន ១៤៣នាក់ទៀត (យោងតាមសេចក្តីសម្រេចរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបាត់ដំបង លេខ០១៤/២៤ ករ.បប ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកសង្កែ និងឃុំនានា ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង និងសេចក្តីសម្រេចរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបាត់ដំបង លេខ០១៥/២៤ ករ.បប ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុករតនមណ្ឌល និងឃុំនានា នៃស្រុករតនមណ្ឌល ខេត្តបាត់ដំបង) ដោយបានបញ្ចូលក្នុងក្រុមការងារស្រុកសង្កែ ចំនួន ៨៣នាក់ និងបញ្ចូលទៅក្នុងក្រុមការងារស្រុករតនមណ្ឌលមានចំនួន ៦០នាក់ ធ្វើឱ្យចំនួនមន្ត្រីក្រសួង ដែលចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបាត់ដំបង សរុបកើនឡើងចំនួន ១៩១នាក់។

មន្ត្រីទាំងអស់បានចូលរួមធ្វើវេទិកាសាធារណៈនៅតាមមូលដ្ឋានឃុំ សង្កាត់ ទៅតាមកម្មវិធីការងារដែលបានកំណត់ ដើម្បីៈ (១)ពាំនាំ ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីគោលនយោបាយ គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាផ្សព្វផ្សាយអំពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល, សភាពការណ៍វិវត្តន៍របស់ប្រទេសជាតិ និងស្ថានភាពសេដ្ឋកិច្ចសង្គមទូទៅ ជូនដល់ប្រជាពលរដ្ឋ, (២)ត្រួតពិនិត្យ និងជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ជាពិសេស ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទជូនដល់ប្រជាពលរដ្ឋ និងការចូលរួមជំរុញ, គាំទ្រការអភិវឌ្ឍមូលដ្ឋាន, ការពង្រឹងស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋាន និង(៣)ក្តាប់សំណូមពរ, បញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និងទទួលយកមកពិនិត្យដោះស្រាយនៅនឹងកន្លែងតែម្តង តាមរយៈវេទិកាសាធារណៈ និងបន្តជួយពិនិត្យដោះស្រាយនៅកម្រិតរដ្ឋបាលស្រុក ក្រុង ខណ្ឌ រាជធានី-ខេត្ត, ក្នុងករណីចាំបាច់ លើកសំណូមពរទៅថ្នាក់ជាតិ ដើម្បីជួយគាំទ្រ និងពិនិត្យដោះស្រាយបន្ត ពិសេស សំណូមពរធំៗដូចជា ការស្ថាបនាផ្លូវ, ការស្នើអគារសិក្សាជាដើម។ ការចូលរួមចុះធ្វើវេទិកាសាធារណៈ និងការក្តាប់បញ្ហាប្រឈម សំណើសំណូមពររបស់ប្រជាពលរដ្ឋ បានដំណើរទៅដោយផ្អែកលើសេចក្តីណែនាំលេខ០២ សរណន. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងលិខិតណែនាំលេខ៤៦៩ សជណ. ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រៅពីនេះ ក្រុមការងារនៅបានចូលរួមឧបត្ថម្ភ គាំទ្រមូលដ្ឋានជាថវិកា សម្ភារផ្សេងៗ

សម្រាប់ដំណើរការធ្វើវេទិការបស់ឃុំ-សង្កាត់ ការចូលរួមអភិវឌ្ឍមូលដ្ឋាន ការជួយប្រជាពលរដ្ឋដែលមានធុរៈគ្រោះថ្នាក់ផ្សេងៗដោយថាហេតុ, មានជំងឺធ្ងន់ធ្ងរ ឬទទួលមរណភាពជាដើម, តិចច្រើនទៅតាមលទ្ធភាពរៀងៗខ្លួន ប៉ុន្តែគឺជាសមានចិត្តឈឺឆ្អាលចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ដោយឡែក ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅខេត្តបាត់ដំបង ដែលដឹកនាំផ្ទាល់ដោយ ឯកឧត្តមរដ្ឋមន្ត្រី និងទទួលផ្ទាល់នៅស្រុកសង្កែ និងស្រុករតនមណ្ឌល បាននិងកំពុងយកអស់កម្លាំងកាយចិត្ត ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញ ចុះផ្ទាល់ដល់ភូមិ ឃុំ-សង្កាត់ និងតាមខ្នងផ្ទះប្រជាពលរដ្ឋមួយចំនួន ដើម្បីធ្វើវេទិកាសាធារណៈ និងចុះស្វែងយល់ដោយផ្ទាល់បញ្ហាប្រឈម កង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋ ដែលបាន៖

- ស្រុកសង្កែ៖
  - » មានកម្លាំងសរុប ២.៦៨៩នាក់(ស្រី៨០៤នាក់)
  - » តាមក្រុមនីមួយៗបានដឹកនាំការប្រជុំ ការធ្វើវេទិកាសាធារណៈ ការចុះធ្វើសកម្មភាពនានា សរុប ៤៣៥លើក
- ស្រុករតនមណ្ឌល៖
  - » មានកម្លាំងសរុប ១.៤៨៩នាក់ (ស្រី៣៧៤នាក់)
  - » តាមក្រុមនីមួយៗបានដឹកនាំការប្រជុំ សរុប ៥៣លើក

ជាលទ្ធផលនៃការចុះធ្វើសកម្មភាព ទទួលបានដូចខាងក្រោម៖

- » ជួយគាំទ្រលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការអភិឌ្ឍមូលដ្ឋាន (ដូចជា អគារសាលាស្រុក អគារសិក្សា មណ្ឌលសុខភាព វត្តអារាម ផ្លូវថ្នល់ ទំនប់ទឹក ប្រឡាយទឹក...)
- » ចូលរួមសកម្មភាពសង្គមដូចជា៖ ទិវាបុណ្យជាតិ និងអន្តរជាតិ ពិធីសម្ពោធសមិទ្ធផល ពិធីបុណ្យសាសនា ការប្រកួតកីឡា ការដាំដើមឈើ ការដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តជួយព្យាបាលជំងឺជូនប្រជាពលរដ្ឋ ការជួយគាំទ្រដល់មជ្ឈមណ្ឌលបន្សាបព្យាបាល និងស្តារនីតិសម្បទា រួមទាំងសកម្មភាពមនុស្សធម៌ (ការជួយប្រជាពលរដ្ឋជួបរងគ្រោះដោយគ្រោះថ្នាក់ចរាចរ អគ្គីភ័យ) និងបានចូលរួមក្នុងពិធីនានាជាច្រើនទៀត។ល។
- » ជួយឧបត្ថម្ភជាថវិកាតាមរយៈកម្លាំងមហាសាមគ្គីរបស់ក្រុមការងារគ្រប់លំដាប់ថ្នាក់ទទួលបានចំណូលពីការផ្តួចផ្តើមរៀបចំបុណ្យកឋិនទាន ដើម្បីជួយកសាង និងអភិវឌ្ឍមូលដ្ឋានក្នុងស្រុកសង្កែ និងស្រុករតនមណ្ឌល ក្នុងខេត្តបាត់ដំបង ទាំងក្នុងផ្លូវអាណាចក្រ និងពុទ្ធចក្រ មានថវិកាឧបត្ថម្ភសរុបចំនួនប្រមាណ ៩២៩ លានរៀល

បូកជាមួយនឹងទេយ្យទាន សម្ភារ និងម៉ូតូ សម្រាប់សិស្សពូកែនិទ្ទេស A ផងដែរ ដែលក្នុងនោះមាន៖ ១) ស្រុកសង្កែ ជួយឧបត្ថម្ភថវិកាសរុបចំនួនប្រមាណ ៦២៧ លានរៀល គួបផ្សំនឹងទេយ្យទាន, សម្ភារ និងម៉ូតូចំនួន ៣ គ្រឿង និង២) ស្រុករតនមណ្ឌល ជួយឧបត្ថម្ភថវិកាសរុបចំនួនប្រមាណ ៣០២ លានរៀល គួបផ្សំនឹងបន្ទះសូឡាចំនួន ៥០ ឈុត និងម៉ូតូចំនួន ៣ គ្រឿង។ ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលសំខាន់ៗរបស់ក្រសួង ក៏បានចូលរួម និងចុះបំពេញការងារក្នុងក្រុមការងាររាជរដ្ឋាភិបាលនៅតាមមូលដ្ឋានតាមមុខសញ្ញាផ្សេងៗ និងបានចូលរួមជួយឧបត្ថម្ភជាថវិកា ទេយ្យទាន និងសម្ភារផ្សេងៗទៀតផងដែរ។





IV

•

បញ្ហាប្រឈម

IV- បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងរយៈពេលជាង ១ឆ្នាំកន្លងមកនេះ ក្រសួងបានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- » ចំនួនមន្ត្រីបម្រើការងារតាមអង្គភាពមួយចំនួនមិនទាន់ឆ្លើយតបទៅនឹងទំហំការងារ និងតាមមុខជំនាញបច្ចេកទេសនៅឡើយ ជាពិសេសសមត្ថភាពក្នុងការអនុវត្តការងារនៅមានកម្រិតទាំងសមត្ថភាព ចំណេះដឹង ជំនាញ និងការគ្រប់គ្រង
- » ថវិកា និងការផ្គត់ផ្គង់សម្ភារបរិក្ខារ ឧបករណ៍សុវត្ថិភាព និងបច្ចេកទេស នៅមានកម្រិតសម្រាប់ការគាំទ្រដល់ដំណើរការអនុវត្តការងារ
- » ការចូលរួមសហការគាំទ្រពីស្ថាប័នពាក់ព័ន្ធនៅមានកម្រិត
- » ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងនានា ជាពិសេសគម្រោងស្ពាន និងអភិវឌ្ឍផ្លូវថ្នល់បានធ្វើឱ្យខូចខាត និងប៉ះពាល់បណ្ដាញទឹកស្អាត ប៉ុន្តែមិនមានសំណង ឬសំណងមិនសមរម្យ គឺជាបន្ទុកធ្ងន់ធ្ងរចំពោះប្រតិបត្តិករ ទឹកស្អាតទាំងផ្នែកបច្ចេកទេស សេដ្ឋកិច្ច និងនិរន្តរភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
- » វិស័យទឹកស្អាត ជាពិសេសប្រតិបត្តិករឯកជន នៅមានបញ្ហាប្រឈមច្រើន។ ការវិនិយោគដើម្បីជានាតួនាទីជាយុទ្ធសាស្ត្ររបស់រដ្ឋ និងការធានាឱ្យសម្រេចបានគោលដៅ២០៣០ ត្រូវការទុនវិនិយោគបន្ថែមច្រើនទៀត
- » បម្រែបម្រួលអាកាសធាតុធ្វើឱ្យមានការខ្វះប្រភពទឹកនៅតំបន់មួយចំនួន ជាពិសេសនៅរដូវប្រាំង
- » ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវការទុនវិនិយោគច្រើន ជាពិសេសតំបន់ដែលនៅទំនេរ
- » សមត្ថភាពរបស់ប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត ដែលមិនទាន់ឆ្លើយតបបានទាំងស្រុងតាមលក្ខខណ្ឌអាជ្ញាបណ្ណ
- » វិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម មានដូចជា៖ ផលពិបាកក្នុងការទទួលបានហិរញ្ញប្បទានពីធនាគារ SME, ការកើនឡើងដោយផ្ទាល់ពីបញ្ហាប្រភពថាមពលសម្រាប់សហគ្រាសផលិតកម្ម, កង្វះការគាំទ្រការប្រើប្រាស់ផលិតផលក្នុងស្រុក ក្នុងស្ថាប័នសាធារណៈ, ការក្លែងបន្លំប្រភពដើមនៃផលិតផលដើម្បីនាំចេញ, ការចុះបញ្ជីផលិតផល, ការស្នើសុំសាងសង់រោងចក្រចំណាយពេលវេលាយូរ, ការសុំឱ្យកម្ពុជាចូលជាសមាជិក ISO Member Bodies, ការប្រកួតប្រជែងមិនច្បាស់លាស់, ការដាក់លក់ផលិតផលចូលក្នុងទីផ្សារធំៗត្រូវចំណាយខ្ពស់, ការធ្វើបច្ចុប្បន្នភាពកំណត់អត្តសញ្ញាណជីស្រែអំបិលពុំទាន់បានបញ្ចប់នៅឡើយ និងកំពុងមានការប្រើប្រាស់ខុសគោលដៅ។

V

ទិសដៅការងារអនុវត្ត ឆ្នាំ២០២៥

V-ទិសដៅការងារអនុវត្តឆ្នាំ២០២៥

ដើម្បីជានាអនុវត្តរាល់បេសកកម្មរបស់ក្រសួង ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រក្រសួងឧ.វ.ប.ន ២០២៥-២០២៨ ឱ្យសម្រេចជោគជ័យ រួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា ក្រសួងបានដាក់នូវទិសដៅការងារអនុវត្តសម្រាប់ឆ្នាំ២០២៥ ដូចខាងក្រោម៖

១. វិស័យឧស្សាហកម្ម

» បន្តរៀបចំ និងធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្តឧស្សាហកម្មទៅតាមតម្រូវការ និងឆ្លើយតបតាមការរីកចម្រើននៃវិស័យឧស្សាហកម្ម ក៏ដូចជាជំរុញចលនាផលិតភាពជាតិ និងសិក្សាអំពីច្បាប់អន្តរជាតិ សម្រាប់ការចូលជាសមាជិកសន្ធិសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងឧស្សាហកម្ម

» បន្តអនុវត្ត និងពង្រីកគម្រោង ក្នុងការពង្រឹងការគ្រប់គ្រងឧស្សាហកម្ម កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម បច្ចេកទេស សុវត្ថិភាពឧស្សាហកម្ម និងជំរុញចលនាផលិតភាព ព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ប្រកបដោយនិរន្តរភាព ធានាបានសុខដុមនីយកម្មសង្គម និងបរិស្ថាន

» បន្តការធ្វើពិពិធកម្មវិស័យឧស្សាហកម្ម ក្នុងទិសដៅទាក់ទាញការវិនិយោគ កម្មន្តសាលកែច្នៃ កសិ-ឧស្សាហកម្ម សម្រាប់កសិផលមានសក្តានុពលក្នុងការនាំចេញ

» បន្តរៀបចំផែនការយុទ្ធសាស្ត្រក្នុងការជំរុញ និងទាក់ទាញការវិនិយោគលើកម្មន្តសាលផ្គុំ និងដំឡើងយានយន្ត និងអេឡិចត្រូនិកផ្អែកលើផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា

» បន្តបណ្តុះបណ្តាលជំនាញឧស្សាហកម្ម ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ដល់មន្ត្រីជំនាញ ផ្នែកឯកជនពាក់ព័ន្ធ និងបន្តផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹង ក្នុងការអភិវឌ្ឍធនធានមនុស្ស

» បន្តជំរុញការចុះបញ្ជីរោងចក្រតាមប្រព័ន្ធអនឡាញ និងបន្សីជាមួយប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) និងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា(Cambodia Data eXchange/CamDX)

» បន្តជំរុញការលើកកម្ពស់ផលិតភាពនៅតាមរោងចក្រ សហគ្រាស ដែលមានទីតាំងនៅរាជធានី និងតាមបណ្តារាជធានី-ខេត្ត
» បន្តពង្រឹងការគ្រប់គ្រងឧស្សាហកម្មតាមប្រព័ន្ធឌីជីថល
» បន្តពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីគ្រប់គ្រងរោងចក្រ
» បន្តរៀបចំទិន្នន័យទីតាំងរោងចក្រតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)
» បន្តពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
» បន្តសិក្សាស្រាវជ្រាវអំពីធនធានមានសក្តានុពល(កៅស៊ូ ស្វាយ ដំឡូងមី) សម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម និងសិក្សាអំពីតម្រូវការវត្ថុធាតុដើមក្នុងស្រុក
» រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្មដល់វិស័យឯកជន តាមប្រព័ន្ធអនឡាញ
» បន្តរៀបចំកម្មវិធីបានពានរង្វាន់ឧស្សាហកម្មបៃតងកម្ពុជា
» បន្តរៀបចំស្ថិតិអាងប្រព្រឹត្តកម្មសំណល់រាវ
» បន្តសុពលភាពលើកទីពីរនៃអនុស្សារណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអំពីកម្មសិទ្ធិឧស្សាហកម្ម រវាងក្រសួងឧ.វ.ប.ន. និងអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី IPOS តាមប្រព័ន្ធអនឡាញ
» រៀបចំបទដ្ឋានគតិយុត្តិ និងធ្វើវិសោធនកម្ម ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
» សិក្សា អំពីផលប្រយោជន៍ និងនីតិវិធីនានា ដើម្បីចូលជាសមាជិកអង្គការ UPOV
» លើកកម្ពស់ចំណេះដឹងផ្នែកកម្មសិទ្ធិឧស្សាហកម្មដល់សាធារណៈជន និងការបង្កើតថ្មីនៅកម្ពុជា តាមរយៈការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយអំពីការចុះបញ្ជីអនឡាញ នីតិវិធីចុះបញ្ជី កម្មសិទ្ធិឧស្សាហកម្ម ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា វិធានការបច្ចេកវិទ្យា និងការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា នានាពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម
» រៀបចំខិតប័ណ្ណផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម
» បន្តកិច្ចសហប្រតិបត្តិការផ្នែកកម្មសិទ្ធិឧស្សាហកម្ម ជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) និងដៃគូសហប្រតិបត្តិការនានា ក្នុងការពន្លឿនផ្តល់សិទ្ធិចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មនៅកម្ពុជា
» សហការជាមួយសមាគមកម្មសិទ្ធិបញ្ញាកម្ពុជា (Intellectual Property Association of Cambodia = IPAC) អនុវត្តផែនការបណ្តុះបណ្តាលវិស័យកម្មសិទ្ធិឧស្សាហកម្ម
» បន្តបញ្ជូនមន្ត្រីដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសដើម្បី

ទទួលបានចំណេះដឹង និងបទពិសោធន៍ឱ្យទូលំទូលាយផ្នែកកម្មសិទ្ធិបញ្ញា

» ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល(បង់សេវា)ស្តីពី វិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាពទៅវិស័យរដ្ឋ និងឯកជន
» ត្រៀមផ្តល់សេវាប្រឹក្សាយោបល់ដើម្បីអភិវឌ្ឍផលិតភាពនៅក្នុងក្រុមហ៊ុន-សហគ្រាស
» ត្រៀមរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាពនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត
» ត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីពានរង្វាន់សមិទ្ធផលផលិតភាព «ស៥»ប្រចាំឆ្នាំ២០២៥
» ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំវគ្គបណ្តុះបណ្តាលស្តីពី AI and Data Analystics for Productivity Enhacement
» ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាស្តីពី Boosting Workplace Productivity through Effective Practices
» ត្រៀមរៀបចំដំណើរការនីតិវិធីសម្រាប់ប្រែក្លាយមជ្ឈមណ្ឌលផលិតភាពជាតិ ទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ
» ត្រៀមរៀបចំផែនការរៀបចំដំណើរការសាកល្បងនៃកម្មវិធីឧត្តមភាពធុរកិច្ចនៅក្នុងប្រទេសកម្ពុជា
» ត្រៀមរៀបចំវេទិកាចលនាផលិតភាព ដើម្បីលើកកម្ពស់ផលិតភាពនៅក្នុងប្រទេសកម្ពុជា
» តៀមសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលឯកជនពាក់ព័ន្ធដើម្បីពង្រីកសេវាបណ្តុះបណ្តាល និងប្រឹក្សារបស់មជ្ឈមណ្ឌលផលិតភាពជាតិ
» បន្តផ្សព្វផ្សាយសម្របសម្រួលជ្រើសរើសបេក្ខជន ដើម្បីចូលរួមគម្រោងរបស់អង្គការ APO នៅក្រៅប្រទេស។

២. វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

» បញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម (SMEs Cluster) និងសេចក្តីព្រាងគោលនយោបាយ ស្តីពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
» ជំរុញការបង្កើតតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម(SMEs Cluster) ដើម្បីទាក់ទាញវិនិយោគិនថ្មីៗ ពិសេសក្នុងវិស័យបច្ចេកវិទ្យា និងបង្កើតប្រព័ន្ធប្រទាក់ក្រឡាគ្នា និងទ្រទ្រង់គ្នាទៅវិញទៅមករវាងសហគ្រាស ធុនតូច និងមធ្យម (SMEs) និងការវិនិយោគផ្ទាល់ពីបរទេស (FDI)

» បន្តចូលរួមអនុវត្តន៍គំនិតផ្តួចផ្តើមនៃការបង្កើត «មជ្ឈមណ្ឌលគាំទ្រធុរកិច្ច និង SMEs ក្នុងការចាប់យកឌីជីថល» (SMEs Go Digital Supporting Hubs) សំដៅចូលរួមបណ្តុះផ្នត់គំនិតសហគ្រិនភាព និងលើកកម្ពស់ការប្រើប្រាស់ និងការចាប់យកបច្ចេក-វិទ្យាឌីជីថលក្នុងអាជីវកម្ម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការធុរកិច្ច និងពង្រីកទីផ្សារ

» បន្តពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមលើការងារគុណភាព សុវត្ថិភាព ការធ្វើទំនើបកម្ម និងពិពិធកម្ម ផលិតផល ដោយមានការសហការបន្ថែមជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការអភិវឌ្ឍវិស័យសហគ្រាស ធុនតូច និងមធ្យម

» បន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអំបិលកម្ពុជាឆ្នាំ២០២២-២០២៦

» បន្តពង្រឹងការគ្រប់គ្រង និងអភិរក្សដីស្រែអំបិល (ខេត្តកំពត-កែប) និងជំរុញការផលិតអំបិល ដែលជាទំនិញយុទ្ធសាស្ត្រឱ្យដើរព្រមគ្នានឹងវិធានការដោះស្រាយបញ្ហាដីស្រែអំបិលដែលមិនមានសក្តានុពល

» បន្តធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ដើម្បីធានាបាននូវភាពងាយស្រួល តម្លាភាព និងភាពឆាប់រហ័សក្នុងការអនុវត្ត គ្រប់គ្រង និងតាមដាន

» បន្តជំរុញកសាងសមត្ថភាពផ្ទាល់របស់មន្ត្រីគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យមានលទ្ធភាពរួមចំណែកបំពេញការងារសម្រាប់វិស័យដែលកំពុងទទួលបន្ទុកឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់

» បន្តអភិវឌ្ឍសិប្បកម្មកែច្នៃវត្ថុធាតុដើមក្នុងស្រុក

» បន្តកសាង និងកែសម្រួលរាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

» បន្តជំរុញការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ពិសេសលើកទឹកចិត្តការចុះបញ្ជីតាមប្រព័ន្ធអនឡាញ

» បន្តពង្រឹងការគ្រប់គ្រងការអនុវត្តប្រតិភូកម្មអំណាចលើការចុះបញ្ជី ឬបង្កើត និងវិញ្ញាបនបត្រអនុញ្ញាត ដំណើរការសហគ្រាសធុនតូច និងមធ្យមរបស់មន្ទីររាជធានី-ខេត្ត ទាំង២៥

» បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងតំបន់ និងពិភពលោក ដើម្បីជំរុញការអភិវឌ្ឍ SMEs

» បន្តលើកកម្ពស់សមត្ថភាពម្ចាស់សហគ្រាសកែច្នៃផលិតផលក្នុងស្រុក និងបន្តជំរុញអភិវឌ្ឍសិប្បកម្មកែច្នៃវត្ថុធាតុដើមក្នុងស្រុក និងកសិ-ឧស្សាហកម្ម

» ជំរុញការបង់កម្រៃសេវាដោយប្រើប្រាស់ KHQR (លែងទទួលកម្រៃជាសាច់ប្រាក់)

» បន្តពង្រឹងសមត្ថភាពទាំងមន្ត្រីមានសមត្ថកិច្ច ផ្នែកឯកជន រួមទាំង MSMEs ដើម្បី

អាចប្រែក្លាយផលិតកម្ម អាជីវកម្ម និងសេវារបស់ខ្លួនបានជោគជ័យ ជាពិសេសនៅពេលមានលំហូរផលិតផលដោយសេរីនៅក្នុងតំបន់អាស៊ាន និងត្រៀមខ្លួន នៅពេលដែលកម្ពុជាចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ និងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០

- ជំរុញវិស័យ MSMEs អនុវត្តស្តង់ដា ការផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ ការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក រួមទាំងការអនុវត្តឧស្សាហកម្មបៃតង (Green Industry)។
- ជំរុញសហគ្រាសធុនមធ្យម និងធំ ងាកមកជួយសហគ្រាសមីក្រូ និងតូច (Backward Linkage) ដោយចាប់អារម្មណ៍លើមុខផលិតផលក្នុងស្រុកដែលមានស្រាប់ ហើយដែលអាចជួយគាំទ្រដល់មុខផលិតផលសម្រេច។
- បន្តរៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីគុណភាព និងសុវត្ថិភាពម្ហូបអាហារ។

៣. ការងារស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងការវាយតម្លៃភាពអនុលោម

- បន្តអភិវឌ្ឍស្តង់ដាជាតិសម្រាប់ផលិតផលថ្មីៗក្នុងស្រុកដែលជាប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច
- បន្តរៀបចំសុខដុមនីយកម្មអាស៊ាន និងកិច្ចសម្រុះសម្រួលទទួលស្គាល់គ្នាទៅវិញទៅមកសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងក្របខណ្ឌទីផ្សារអាស៊ាន
- តម្លើងកម្រិតសមាជិកភាពរបស់កម្ពុជាទៅក្នុងអង្គការស្តង់ដាអន្តរជាតិ
- បន្តរៀបចំគោលនយោបាយជាតិសម្រាប់គ្រប់គ្រងការងារស្តង់ដារូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធី វាយតម្លៃភាពអនុលោមរបស់កម្ពុជា
- បន្តរៀបចំគោលនយោបាយជាតិ សម្រាប់ពង្រឹងគុណភាព និងប្រសិទ្ធិភាពការងាររបស់ហេដ្ឋារចនាសម្ព័ន្ធគុណភាព
- រៀបចំផែនទីបង្ហាញផ្លូវ (Roadmap) សម្រាប់ជំរុញ និងអនុវត្តសកម្មភាពស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងអាសិប (RCEP)
- រៀបចំប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ផលិតផលប្រព័ន្ធ ចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធអធិការកិច្ចការអនុវត្តស្តង់ដាឱ្យទទួលស្គាល់ជាលក្ខណៈអន្តរជាតិ
- រៀបចំ Peer Assessment ទៅលើបណ្តាអង្គភាពវិញ្ញាបនបត្រ និងអធិការកិច្ចរបស់

បណ្ដាប្រទេសដែលចូលរួមអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយកម្ពុជា

» ធ្វើវិសោធនកម្មច្បាប់ស្ដីពីស្ដង់ដាកម្ពុជាឱ្យស្របទៅនឹងនិន្នាការនៃទីផ្សារសកល និង តំបន់ និងក្របខណ្ឌ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ពហុភាគី កិច្ចព្រមព្រៀង អាស៊ាន អាស៊ាន និងប្រទេសដៃគូពាណិជ្ជកម្ម

» រៀបចំបង្កើតអនុក្រឹត្យស្ដីពីការគ្រប់គ្រងអង្គភាពវាយតម្លៃភាពអនុលោម (អង្គភាព វិញ្ញាបនបត្រ អង្គភាពធ្វើតេស្ត និងអធិការកិច្ច) ដើម្បីចូលរួមអនុវត្តកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីទ្វេភាគី ពហុភាគី កិច្ចព្រមព្រៀងអាស៊ាន អាស៊ាន និងប្រទេសដៃគូ ពាណិជ្ជកម្ម

» បន្តរៀបចំ និងកែលម្អយន្តការផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការបណ្ដុះបណ្ដាល និងសិក្ខាសាលាដល់ក្រុមហ៊ុន សហគ្រាសផលិតកម្ម និងអាជីវកម្ម ពាក់ព័ន្ធនឹង ការអនុវត្តស្ដង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធី វាយតម្លៃភាពអនុលោម កិច្ច ព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអាស៊ិប (RCEP)។

៤. ការងារមាត្រាសាស្ត្រជាតិ

» រៀបចំមន្ទីរពិសោធន៍ផ្នែកអាភាមាត្រាសាស្ត្រ និងដាក់ដំណើរការមន្ទីរពិសោធន៍ផ្នែកអគ្គិ សនី

» ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ម៉ាស ចំណុះ សម្ពាធ សីតុណ្ហភាព និងទំហំ ដើម្បី ទទួលបាន ISO/IEC 17025:2017

» បង្កើន និងពង្រីកប្រសិទ្ធភាពលើការព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ និងត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញ វេចខ្ចប់នាំចូល ការចេញលិខិតអនុញ្ញាតប្រើប្រាស់សមមូលនៃប្រព័ន្ធឯកតាទម្ងន់ ផ្នែក លោហធាតុមានតម្លៃ តាមបណ្ដា ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្ម

» បន្តជំរុញ ពិនិត្យតាមដាន វាយតម្លៃ និងផ្ដល់យោបល់ការងារបានប្រតិភូកម្មទៅ មន្ទីរ រាជធានី-ខេត្ត

» បន្តត្រួតពិនិត្យបទល្មើស និងអនុវត្តការពិន័យអន្តរការណ៍ជាប្រាក់នៅតាមបណ្ដាមូល ដ្ឋានអាជីវកម្មពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ

» បន្តសហការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធរបស់មន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត

» បន្តសិក្សាស្រាវជ្រាវ ចងក្រង អភិវឌ្ឍឧបករណ៍ស្ដង់ដាមាត្រាសាស្ត្រ

» រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសនានាដើម្បីគាំទ្រអភិវឌ្ឍការ ងារមាត្រាសាស្ត្រ

» សិក្សារៀបចំអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាមាត្រាសាស្ត្រជាតិ និងប្រកាសស្តីពីក្លឹបមាត្រាសាស្ត្រ
» កំណែទម្រង់រដ្ឋបាលសាធារណៈលើការងារមាត្រាសាស្ត្រ
» គ្រោងពង្រីកកិច្ចសហប្រតិបត្តិការមាត្រាសាស្ត្រ ក្របខណ្ឌមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិជាមួយនឹង វិទ្យាស្ថានមាត្រាសាស្ត្រជាតិវៀតណាម (Vietnam Metrology Institute)
» សហប្រតិបត្តិការសម្របសម្រួល និងទំនាក់ទំនងជា មួយអង្គការក្នុងតំបន់ និងសកល (BIPM,OIML, APMP, APLMF, EGM-GROUP, ACCSQ និងវិទ្យាស្ថានមាត្រាសាស្ត្រជាតិនានា)
» បន្តពង្រឹង និងអនុវត្តកិច្ចសហប្រតិបត្តិការមាត្រាសាស្ត្រជាមួយសាធារណរដ្ឋប្រជាមានិតចិន លើកគម្រោង ផែនការសកម្មភាពសម្រាប់បង្កើនការរីកចម្រើនវិស័យមាត្រាសាស្ត្រ និងការទទួលស្គាល់គ្នាទៅវិញទៅមកជាមួយប្រទេសក្នុងគម្រោងមេគង្គ-ឡាងឆាង (២០២៣-២០២៨)
» រៀបចំបង្កើតក្រុមការងារចុះអង្កេតទីផ្សារ (Market Surveillance) ការលក់ ការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាព ពាណិជ្ជកម្ម និង ស្ថានីយ៍ អនុស្ថានីយ (ដេប៉ូ) ប្រេងឥន្ធនៈ រាជធានី-ខេត្ត
» បន្តចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រតាមបណ្តាអង្គភាពសេដ្ឋកិច្ច និងតាមបណ្តារាជធានី-ខេត្ត ដែលត្រូវបានដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងបន្តចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងថ្លឹងរថយន្តនៅតាមខេត្តដោយផ្ទាល់
» បន្តរៀបចំផែនការបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រទំនិញផលិត និងទំនិញវេចខ្ចប់តាមបណ្តាមន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត និងនៅទីតាំងរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដោយផ្ទាល់
» បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់រថយន្តស៊ីទែន ជញ្ជីងថ្លឹងរថយន្ត ការបញ្ជាក់ លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល និងការងារប្រព័ន្ធឯកតា
» ទាក់ទង ផ្សព្វផ្សាយ និងចុះដល់ទីតាំងក្រុមហ៊ុន ឬអ្នកនាំចូលទំនិញវេចខ្ចប់ ដើម្បីជំរុញក្នុងការដាក់ពាក្យស្នើសុំបញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល និងការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញវេចខ្ចប់នាំចូល
» បន្តជំរុញជាមួយតំណាងផ្សារនានា ក្នុងការផ្សព្វផ្សាយដល់អាជីវករផ្សារ ឱ្យយល់ដឹងកាន់តែច្បាស់ពីប្រព័ន្ធឯកតា ផ្នែកលោហធាតុមានតម្លៃ
» បន្តសិក្សាស្រាវជ្រាវពីបច្ចេកទេសថ្មីៗដើម្បីគ្រប់គ្រងការងារមាត្រាសាស្ត្រ
» បន្តស្វែងរកដៃគូជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍវិស័យមាត្រាសាស្ត្រ

» បន្តរៀបចំកែសម្រួលប្រកាសស្តីពីនីតិវិធីការចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រ ដោយរួមបញ្ចូលនីតិវិធីតាមប្រព័ន្ធអនឡាញ
» បន្តរៀបចំកែសម្រួលប្រកាសស្តីពីអាជ្ញាបណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ ដោយរួមបញ្ចូលនីតិវិធីតាមប្រព័ន្ធអនឡាញ
» រៀបចំសេចក្តីព្រាងប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍មាត្រាសាស្ត្រដាក់លាក់ដែលបានបញ្ញត្ត
» សិក្សាចងក្រងប្រកាសអន្តរក្រសួង ស្តីពីទម្រង់ឯកសារសម្រាប់មន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រើប្រាស់ក្នុងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ
» ពង្រឹងមុខងារ និងភារកិច្ចមន្ត្រីទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ នៅមន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត។

៥. ការខារវាយតម្លៃទទួលស្គាល់នៃកម្ពុជា

» បន្តស្វែងរកកិច្ចសហការពីដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពល ដើម្បីគាំទ្រដល់ការអភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ តាមរយៈសិក្ខាសាលា កិច្ចប្រជុំផ្សេងៗ ជូនដល់បញ្ញត្តិករជ្ញ អ្នកពាក់ព័ន្ធ សាធារណជន ដោយមានការបើកវគ្គបណ្តុះបណ្តាលទៅតាមស្តង់ដាជាអាទិភាពស្របតាមស្ថានភាពនៃការងារសេវាកម្មវាយតម្លៃទទួលស្គាល់ និងបន្តបណ្តុះបណ្តាលដល់អ្នកជំនាញឱ្យក្លាយជាអ្នកវាយតម្លៃទទួលស្គាល់ផ្លូវការ
» បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗបន្ថែមទៀត ផ្សព្វផ្សាយ និងជំរុញឱ្យអង្គភាពវាយតម្លៃភាពអនុលោម មកចុះបញ្ជី និងស្នើសុំសេវាវាយតម្លៃទទួលស្គាល់
» បន្តរៀបចំផ្សព្វផ្សាយដល់អ្នកនាំចេញនាំចូល ឱ្យមកចុះបញ្ជីវិញ្ញាបនបត្រវាយតម្លៃភាពអនុលោមភ្ជាប់ជាមួយ ទំនិញនាំចេញ-នាំចូល ដើម្បីជួយការពារអ្នកប្រើប្រាស់ក្នុងគោលបំណងធ្វើឱ្យទំនិញឈានទៅអនុលោមតាមស្តង់ដាពិតប្រាកដ
» បន្តអភិវឌ្ឍរបបការងារ (Schemes) ជាអាទិភាពអនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិ
» បន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងគុណភាព QMS-GDAC
» បន្តរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តទាក់ទិនការងារវាយតម្លៃទទួលស្គាល់
» រៀបចំអភិវឌ្ឍប្រព័ន្ធនីតិវិធី (Schemes) សម្រាប់វាយតម្លៃទទួលស្គាល់ និងបណ្តុះបណ្តាលធនធានមនុស្សទៅតាមស្តង់ដាជាតម្រូវការតាមអាទិភាព
» សហការជាមួយអង្គភាពបញ្ញត្តកម្មសាធារណៈ ដើម្បីគាំទ្រដល់គោលនយោបាយ

សាធារណៈ
» ខិតខំពង្រឹងគុណភាពទំនិញផលិតក្នុងស្រុក និងទំនិញនាំចូល ដោយប្រើប្រាស់យន្តការចុះបញ្ជីលើវិញ្ញាបនបត្រ វាយតម្លៃភាពអនុលោមដែលភ្ជាប់ជាមួយទំនិញនាំចេញនាំចូល ដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ គាំទ្រដល់សេដ្ឋកិច្ចជាតិ និងបរិស្ថានសង្គម។

៦. ការងារមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

» កែលម្អពង្រឹង និងពង្រីកអាជីវកម្ម
» រៀបចំប្រព័ន្ធគ្រប់គ្រងតាមបែបឌីជីថល
» បង្កើនសមត្ថភាព និងប្រសិទ្ធភាពនៃការធ្វើតេស្តវិភាគ
» លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងសមិទ្ធកម្មការងារ
» រក្សាភាពអនុលោម និងការទទួលបានភាពអនុលោមស្តង់ដាជាតិ និងអន្តរជាតិបន្ថែមទៀត
» អភិវឌ្ឍមន្ទីរពិសោធន៍ផ្នែកមេកានិក អគ្គីសនី និងអេឡិចត្រូនិក។

៧. វិស័យទឹកស្អាត

» ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងបទដ្ឋានគតិយុត្តនានា ព្រមទាំងបន្តរៀបចំសេចក្តីព្រាងបទដ្ឋានគតិយុត្តទាំងអស់ដែលស្ថិតក្រោមច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតចូលជាធរមាន
» បញ្ចប់ការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
» បង្កើតមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត
» ពង្រឹងការគ្រប់គ្រងទិន្នន័យ រួមទាំងប្រព័ន្ធដែលកំពុងប្រើប្រាស់ ដោយយកចិត្តទុកដាក់ខ្ពស់លើការប្រើប្រាស់ បច្ចេកវិទ្យាក្នុងប្រព័ន្ធគ្រប់គ្រង
» សិក្សាបង្កើតនិយ័តករទឹកស្អាតកម្ពុជា ព្រមទាំងពង្រឹងការងារនិយ័តកម្ម
» បន្តពង្រីកវិសាលភាពការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
» បន្តជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងពន្លឿនការរៀបចំលិខិតបទដ្ឋានគិតយុត្តដែលស្ថិតក្រោមច្បាប់
» បន្តចុះត្រួតពិនិត្យ និងពង្រឹងការអនុវត្តលក្ខខណ្ឌអាជ្ញាបណ្ណ របស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងប្រទេស
» សិក្សាលើការបញ្ចូលគ្នារវាងប្រតិបត្តិករខ្នាតតូច និងប្រតិបត្តិករដែលមិនមានសមត្ថភាពបន្តអាជីវកម្មពន្លឿនការរៀបចំបង្កើតនិយ័តករទឹកស្អាតកម្ពុជា

» សិក្សាសមិទ្ធិលទ្ធភាពបង្កើតរដ្ឋាករទឹកកម្ពុជា
» ពន្លឿនការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
» បន្តបញ្ជ្រាបការយល់ដឹង អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតទៅកាន់ប្រជាជនគ្រប់ស្រទាប់
» បន្តសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិដើម្បីរៀបចំផែនការអភិវឌ្ឍន៍វិស័យទឹកស្អាតទីប្រជុំជន
» បន្តរក្សាកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិដើម្បីអភិវឌ្ឍ និងដោះស្រាយបញ្ហាប្រឈមនឹងវិស័យទឹកស្អាត។

៨. ការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

» រៀបចំគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្សសម្រាប់វិស័យ វ.ប.ន. និងបន្តរៀបចំគោលយុទ្ធសាស្ត្រជាតិ ស្តីពីបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត
» រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំ និងបង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាស
» បន្តធ្វើបរិវត្តកម្មឌីជីថលលើការងារ និងការគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ព្រមទាំងសេវាសាធារណៈក្រោមសមត្ថកិច្ចរបស់ក្រសួង
» សិក្សា និងអភិវឌ្ឍប្រព័ន្ធទិន្នន័យសម្រាប់ក្រសួង និងរៀបចំគោលការណ៍ណែនាំអំពីនីតិវិធីប្រតិបត្តិការស្តង់ដាសុវត្ថិភាពទិន្នន័យ
» បញ្ចប់ការរៀបចំបទដ្ឋានគតិយុត្តគាំទ្រ ការគ្រប់គ្រងការស្រាវជ្រាវ និងអភិវឌ្ឍន៍
» បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពី «ការផ្ទេរបច្ចេកវិទ្យា» និងសិក្សារៀបចំមជ្ឈមណ្ឌលជាតិផ្ទេរបច្ចេកវិទ្យា
» រៀបចំវេទិកាប្រចាំឆ្នាំលើកទី៥ ស្តីពី «ការផ្ទេរបច្ចេកវិទ្យា»
» រៀបចំទិវាជាតិ វ.ប.ន. លើកទី៣, រៀបចំកិច្ចប្រជុំ ក.ជ.វ.ប.ន. លើកទី៥ និងទី៦
» ចូលរួមកិច្ចប្រជុំលើកទី២១ រដ្ឋមន្ត្រីអាស៊ានផ្នែក វ.ប.ន. (AMMSTI-21) កិច្ចប្រជុំគណៈកម្មាធិការអាស៊ាន សម្រាប់កិច្ចសហប្រតិបត្តិការផ្នែក វ.ប.ន. លើកទី៨៦ និងទី៨៧ (COSTI-86 & 87) និងកិច្ចប្រជុំពាក់ព័ន្ធ
» រៀបចំកម្មវិធីអាស៊ានណិក (ASEAN-NEXT) និងសន្និបាតស្ត្រីអ្នកវិទ្យាសាស្ត្រអាស៊ានឥណ្ឌា ក្រោមក្របខណ្ឌគណៈកម្មាធិការអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការផ្នែក វ.ប.ន.
» បង្កើនដៃគូសហការជាតិ អន្តរជាតិ និងវិស័យឯកជនក្នុងវិស័យ វ.ប.ន.
» រៀបចំព្រឹត្តិការណ៍ និងកម្មវិធីក្នុងន័យលើកកម្ពស់នវានុវត្តន៍ និងសហគ្រិនភាព

- រៀបចំផែនការវិនិយោគលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ការផ្ទេរបច្ចេកវិទ្យា និងអនុក្រឹត្យការរៀបចំមូលនិធិស្រាវជ្រាវជាតិ ការគ្រប់គ្រង ការស្រាវជ្រាវជ្រាវ និងអភិវឌ្ឍន៍
- បន្តពង្រីកមជ្ឈមណ្ឌលទិន្នន័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅស្រុក និងជំរុញការផ្សារភ្ជាប់រវាងសាកលវិទ្យាល័យ និងសហគ្រាសតាមម៉ូឌែលត្រីវណ្ណ
- ត្រៀមបង្កើតថ្នាលឌីជីថលសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងធ្វើការសាក ល្បងលើផែនទីបង្ហាញផ្លូវ វ.ប.ន.កម្ពុជា ២០៣០
- បន្តសម្របសម្រួល និងប្រមូលទិន្នន័យសន្ទស្សន៍នវានុវត្តន៍សកលរបស់កម្ពុជា ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៩. ការងារវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បន្តពង្រឹង និងបង្កើនសមត្ថភាពមន្ត្រី និងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ផលិតផលលើវិស័យកសិឧស្សាហកម្ម អាហារ វិស័យវិទ្យាសាស្ត្ររូបធាតុ ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម
- អនុវត្តកម្មវិធី អ្នកវិទ្យាសាស្ត្រវ័យក្មេង (Young Scientist Program) ដើម្បីបង្កើនសម្ព័ន្ធភាពជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សានានា និងចំពោះមុខបំពេញកង្វះខាតមន្ត្រីជំនាញ នៅក្នុងវិទ្យាស្ថានជាតិ វ.ប.ន.
- បន្ត និងបញ្ចប់ការបំពាក់ និងតម្លើងឧបករណ៍ និងគ្រឿងម៉ាស៊ីន សម្រាប់ផ្នែកវិភាគគុណភាព និងផលិតកម្មខ្នាតតូចនៃគម្រោងអភិវឌ្ឍន៍អាហារកម្ពុជា
- ផ្តល់ការគាំទ្រ ប្រឹក្សាលើបច្ចេកវិទ្យាអាហារដល់សហគ្រាសធុនមីក្រូ តូច និងមធ្យមតាមរយៈគម្រោងអភិវឌ្ឍន៍អាហារកម្ពុជា
- សាកល្បងប្រើប្រាស់សម្ភារដែលធន់នឹងច្រែះដែលក្រុមការងារវិទ្យាស្ថានជាតិ វ.ប.ន. ផលិតបាន នៅក្នុងទីតាំងវិទ្យាស្ថាន វ.ប.ន. ហើយនឹងរៀបចំជាវីដេអូ និងសិក្ខាសាលាដើម្បីបង្ហាញពីលទ្ធផលនៃការផលិតសាកល្បងនេះ
- បញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍បច្ចេកវិទ្យាប្រព្រឹត្តកម្មវិទ្យុសកម្មលើពហុវិស័យ
- បន្តបង្កើតមាតិកា និងផ្សព្វផ្សាយអំពី វ.ប.ន. ដល់សាធារណជន ជាពិសេសបង្កើនការផ្សព្វផ្សាយអំពីការងារ និងសក្តានុពលរបស់វិទ្យាស្ថានជាតិ វ.ប.ន. ដល់វិស័យឯកជន (សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅវិទ្យាស្ថានជាតិ វ.ប.ន.)

» រៀបចំវេទិកាអន្តរជាតិស្ដីពីការអភិវឌ្ឍផលិតផលធម្មជាតិ

» រៀបចំវេយន្តមត្ថុទ្ទេសក៍វិទ្យាសាស្ត្រដើម្បីគាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការអភិវឌ្ឍផលិតផល និងធនធានមនុស្ស

» បន្តរៀបចំវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាអាហារដល់សហគ្រាសធុនមីក្រូ តូច និង មធ្យម

» រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្វែងយល់ពីតម្រូវការបណ្តុះបណ្តាលសម្រាប់ សហគ្រាសធុន មីក្រូ តូច និងមធ្យម ផ្នែកអាហារ និងវិទ្យាសាស្ត្ររូបធាតុ ដើម្បីរៀបចំ ជាមេរៀន និងឯកសារណែនាំ (training materials, guidelines & manuals)

» បន្ត និងបញ្ចប់ការរៀបចំផែនទីបង្ហាញផ្លូវរបស់វិទ្យាស្ថានជាតិ វ.ប.ន. (roadmap) ក្នុងគោលបំណងបង្ហាញអំពីទស្សនវិស័យ ចក្ខុវិស័យ និងយុទ្ធសាស្ត្រនាពេលអនាគត របស់វិទ្យាស្ថានជាតិ វ.ប.ន.

» បន្តពង្រឹង និងពង្រីកសមត្ថភាពមន្ត្រី និងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ផលិតផល ដែលគាំទ្រវិស័យអាទិភាព របស់រាជរដ្ឋាភិបាល និងបន្តបង្កើតមាតិកា និងផ្សព្វផ្សាយ អំពី វ.ប.ន. ដល់សាធារណជន

» បន្តសហការ គាំទ្រ និងពង្រឹងការស្រាវជ្រាវ ដើម្បីបម្រើដល់វិស័យពាក់ព័ន្ធ វ.ប.ន.

» បន្តអភិវឌ្ឍកម្មវិធី និងរៀបចំវគ្គបណ្តុះបណ្តាល ដល់សហគ្រាសធុនតូច និងមធ្យម ជាពិសេស គឺការរៀបចំវគ្គបណ្តុះបណ្តាលរបៀបយកសំណាកមកធ្វើតេស្តវិភាគ ប៉ុន្តែ មិនទទួលបានភាពអនុលោម នៅមន្ទីរពិសោធន៍ជាតិ វ.ប.ន.។

១០. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ

» បន្តជំរុញក្រសួង-ស្ថាប័ន ឱ្យពន្លឿន និងបញ្ចប់ការអនុវត្តវិធានការគន្លឹះនៃយុទ្ធសាស្ត្រ

» រៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍ សេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យបានគត់មត់

» បន្តសហការជាមួយដៃគូអភិវឌ្ឍរួមមាន៖ UNDP, ILO & CAPRED ពិនិត្យរៀបចំ ឯកសារទស្សនទាន ស្តីពីការបង្កើតក្របខណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃ (M&E Framework) នៃយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ២០២៣-២០២៨

» លើកកម្ពស់ការយកចិត្តទុកដាក់បន្ថែមក្នុងការសម្របសម្រួល ការដោះស្រាយបញ្ហា កង្វល់ និងយន្តការឆ្លើយតបជាមួយបងប្អូនអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលនឹងចុះឈ្មោះ ក្នុងថ្នាលឌីជីថល

» បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ ធុរកិច្ច និងសេដ្ឋកិច្ចឌីជីថល ដើម្បីពង្រឹងធានាសន្តិសុខ សុវត្ថិភាពថ្នាលឌីជីថល និង

ទិន្នន័យឯកជនភាពផ្សេងៗរបស់អ្នកចុះឈ្មោះសេដ្ឋកិច្ចក្រៅប្រព័ន្ធ

- បន្តរៀបយុទ្ធនាការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីសារៈសំខាន់នៃការចុះឈ្មោះ និងរបៀបចុះឈ្មោះជូនដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បន្តសម្របសម្រួល ដោះស្រាយបញ្ហាប្រឈមនានាដែលនាំឱ្យមានការរាំងស្ទះក្នុងការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បន្តសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់កញ្ចប់អត្ថប្រយោជន៍ និងបង្កលទ្ធភាពអភិវឌ្ឍបន្ទាប់ពីបានចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ពិនិត្យលទ្ធភាពនៃប្រភេទមុខរបរ តម្រូវការ ស្ថានភាពអាជីវកម្មដែលអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចទទួលយកបានដើម្បីអភិវឌ្ឍខ្លួនតាមដែនដីរដ្ឋបាលនីមួយៗព្រមទាំងកំណត់អាទិភាពនៃប្រភេទមុខរបរអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- សិក្សា សម្របសម្រួល ជាមួយក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា ដើម្បីពិនិត្យដោះស្រាយបញ្ហាប្រឈម និងជំរុញអភិវឌ្ឍអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំងលើផ្នែកផលិតភាព បច្ចេកទេស ការគ្រប់គ្រងមុខរបរ លទ្ធភាពហិរញ្ញវត្ថុ និងទីផ្សារ ជាដើម
- បន្តសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងបង្កលទ្ធភាពក្នុងការអភិវឌ្ឍអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។

១១. ការងារកិច្ចការទូទៅ

- បន្តបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដើម្បីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដោយសហការជាមួយបណ្តាស្ថាប័នជាតិ អន្តរជាតិ និងស្ថានទូតនានា និងពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីរាជការ
- បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកាលកំណត់ និងតាមសញ្ញាបត្រ និងការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការដែលមានគុណសម្បត្តិ និងមានស្នាដៃល្អក្នុងការបំពេញការងារឱ្យបានទាន់ពេល និងទៀងទាត់
- បន្តធ្វើផែនការក្របខណ្ឌ និងការវិភាគមុខងារ និងមុខតំណែង និងរៀបចំយន្តការលើកទឹកចិត្តមន្ត្រីរាជការដែលបានបំពេញតួនាទីបានល្អ និងមានស្នាដៃ
- បន្តយកចិត្តទុកដាក់ដល់ការងារសមាគមបុគ្គលិកក្រសួង និវត្តន៍ជន សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
- បន្តយកចិត្តទុកដាក់ក្រុមការងារថ្នាក់ជាតិរបស់ក្រសួង ចុះមូលដ្ឋានរាជធានី-ខេត្ត
- បន្តតាមដានរាល់សកម្មភាពកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ក្នុង និងក្រៅតំបន់ ដែលពាក់ព័ន្ធវិស័យឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងបូកសរុប

ការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ប្រចាំឆ្នាំ

» បន្តសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងពិភាក្សាជាមួយប្រទេសដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្ម និងសិប្បកម្ម ដើម្បីគៀរគរធនធាន និងលើកគម្រោងស្នើសុំ (Build Project Proposal)
» បន្តផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ ក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង
» បន្តរៀបចំសិក្ខាសាលា និងបណ្តុះបណ្តាល ស្តីពីសេចក្តីណែនាំបច្ចេកទេស ស្តីពីបែបបទនីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងការដឹកនាំ ការសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចុះត្រួតពិនិត្យ តាមដាន និងគាំទ្របច្ចេកទេស លើការអនុវត្តកិច្ចដំណើរការផ្ទេរមុខងារជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
» បន្តអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម និងបន្តអនុវត្តការត្រួតពិនិត្យឡើងវិញ ការវិភាគមុខងារ និងការប្រើប្រាស់ធនធានមនុស្ស
» បន្តអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្របតាមផែនការសកម្មភាពរួមរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
» បន្តប្រតិភូកម្មសិទ្ធអំណាច និងធនធានដល់ភាពអង្គភាពចំណុះក្រសួង
» បន្តកិច្ចសហការជាមួយធនាគារដៃគូដើម្បីពង្រឹង និងពង្រីកការទូទាត់សេវាសាធារណៈឱ្យកាន់តែភាពងាយស្រួល
» បន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងអង្គភាពថវិកាទាំង ៣៤ ដែលបានក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
» បន្តពិនិត្យឡើងវិញកម្រងសេវាសាធារណៈរបស់ក្រសួង និងរបស់មន្ទីរពិសោធន៍
» បន្តការចុះធ្វើសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងទូទាំងប្រទេស។

១២. ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

» បន្តចុះធ្វើអធិការកិច្ច និងសវនកម្មនៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង
» បន្តចូលរួមជាមួយក្រុមអធិការកិច្ចអន្តរស្ថាប័ន និងក្រុមជនបង្គោលសម្របសម្រួលការងារអធិការកិច្ចអន្តរស្ថាប័ន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង

សវនកម្មបីឆ្នាំរំកិល ២០២៥-២០២៧

» បន្តពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងសវនកម្មផ្ទៃក្នុង តាមរយៈការសិក្សាស្រាវជ្រាវចងក្រងបន្ថែមទៀតនូវបណ្តាលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងវិធីសាស្រ្តអនុវត្តនានា ក៏ដូចជាកិច្ចសហការអន្តរស្ថាប័ននានា ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីជាជំនួយដល់ការអនុវត្តភារកិច្ចឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់

» បន្តជំរុញដល់មន្ត្រីសវនករក្នុងនាយកដ្ឋាន ក្នុងការលើកកម្ពស់សមត្ថភាពតាមរយៈការសិក្សាស្រាវជ្រាវបន្ថែមទៀតនូវបណ្តាលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីជាជំនួយដល់ការអនុវត្តភារកិច្ចឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

១៣. ការងារយេនឌ័រ

» បន្តអនុវត្តតាមផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រឆ្នាំ២០២៣-២០២៨ ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ និងបន្តចូលរួមអនុវត្តន៍អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ១២ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញក្នុងកិច្ចប្រជុំបូកសរុបការងារឆ្នាំ២០២៣ និងផែនការសកម្មភាពការងារឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាជាតិកម្ពុជា កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ដើម្បីសម្រេចបាននូវផែនការសកម្មភាពបញ្ជ្រាបយេនឌ័រវិស័យឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍។

១៤. ការងារមន្ទីរ ឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត

» បន្តជំរុញ និងអភិវឌ្ឍការងារឧស្សាហកម្ម និងសិប្បកម្ម

» បន្តជំរុញ និងអភិវឌ្ឍ ការងារទឹកស្អាត

» បន្តជំរុញ និងអភិវឌ្ឍ ការងារស្តង់ដា និងមាត្រាសាស្រ្ត

» បន្តជំរុញ និងអភិវឌ្ឍ ការងារវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍

» បន្តអនុវត្តប្រកបដោយការទទួលខុសត្រូវ លើមុខងារដែលក្រសួងបានប្រតិភូកម្មជូន។

១៥. សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

» បន្តចូលរួម និងចុះបំពេញការងារនៅតាមមូលដ្ឋានតាមមុខសញ្ញារៀងៗខ្លួន

» បន្តចូលរួមធ្វើវេទិកាសាធារណៈនៅតាមមូលដ្ឋានឃុំ សង្កាត់ ទៅតាមកម្មវិធីការងារដែលបានកំណត់ ដោយបន្តក្តាប់បញ្ហាប្រឈម សំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងទទួលយកមកពិនិត្យដោះស្រាយនៅនឹងកន្លែងតែម្តង

» បន្តត្រួតពិនិត្យ និងជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល

» បន្តជួយពិនិត្យ និងរកដំណោះស្រាយនៅកម្រិតរដ្ឋបាលស្រុក ក្រុង ខណ្ឌ រាជធានី-ខេត្ត

» បន្តចូលរួមឧបត្ថម្ភ គាំទ្រមូលដ្ឋាន ជាថវិកា សម្ភារផ្សេងៗ សម្រាប់ដំណើរការធ្វើវេទិកាសាធារណៈរបស់ឃុំ សង្កាត់

» បន្តជួយគាំទ្រលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍមូលដ្ឋាន និងការចូលរួមសកម្មភាពសង្គម។

VI.

សេចក្តី សន្និដ្ឋាន

VI- សេចក្តីសន្និដ្ឋាន

ជារួម ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ក្រសួងឧ.វ.ប.ន បានខិតខំអនុវត្ត គោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រេចបានសមិទ្ធផលវិជ្ជមានជាច្រើនប្រកបដោយផ្លែផ្កា និងជាទីគួរមោទនៈ។ សមិទ្ធផលទាំងអស់នេះ ពិតជាបានចូលរួមចំណែកដល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យបាននូវការបង្កើតការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបន្តរួមចំណែកដើម្បីសម្រេចបាននូវចក្ខុវិស័យរយៈពេលមធ្យម និងរយៈពេលវែង របស់កម្ពុជា ពិសេសគោលនយោបាយស្តារ និងអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។

លទ្ធផលសំខាន់ៗតាមបណ្តាវិស័យជំនាញដូចបានគូសបញ្ជាក់ខាងលើ ពិតជាបង្ហាញឱ្យឃើញថា វិស័យ ឧ.វ.ប.ន កំពុងមានការអភិវឌ្ឍឈានទៅមុខប្រកបដោយនិរន្តរភាព មានលក្ខណៈចម្រុះសម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែច្នៃ កម្មន្តសាល ជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែច្រវាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ដើម្បីជំរុញ និងលើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសេវាកម្ម ក្រសួងឧ.វ.ប.ន បាននិងកំពុងយកចិត្តទុកដាក់អភិវឌ្ឍឧស្សាហកម្ម ៤.០ ស្របតាមនិន្នាការថ្មីនៃពិភពលោក ក្នុងការត្រៀមរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ដើម្បីចាប់យកឱកាសជំរុញការរីកចម្រើននៃទីផ្សារធុរកិច្ចបច្ចេកវិទ្យា ជំរុញ និងលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ក៏ដូចជាការគ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុដោយបច្ចេកវិទ្យា។ ក្រសួងបានកំពុងយកចិត្តទុកដាក់លើកកម្ពស់សហគ្រិនភាព និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងការបង្កើតការងារសមរម្យថ្មី និងតម្រង់ទិសថ្មី រួមជាមួយការបង្កើត និងកែសម្រួលក្របខណ្ឌគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រពាក់ព័ន្ធនានា ដើម្បីរួមចំណែកត្រៀមកម្ពុជាក្នុងដំណើរចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ ដោយជោគជ័យ។

តាមរយៈការបន្តគាំទ្រ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយ

គតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងឧ.វ.ប.ន នឹងបន្តខិតខំអនុវត្តការងារប្រកបដោយសុឆន្ទៈ និងទទួលខុសត្រូវ ស្របតាមទិសដៅការងារឆ្នាំ២០២៥ និងចក្ខុវិស័យ ដូចមានចែងផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៥-២០២៨ របស់ក្រសួងឧ.វ.ប.ន ឱ្យសម្រេចដោយជោគជ័យ។ ការងារអាទិភាព ទាំងនោះរួមមានៈ (១). ការជំរុញអនុវត្តការងារ ដើម្បីឱ្យសម្រេចជោគជ័យគោលដៅផ្គត់ផ្គង់ ទឹកស្អាត នៅឆ្នាំ២០៣០, (២). ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, (៣). បន្តពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន, (៤). ក្រសួងនឹងបន្តផ្តល់អាទិភាពក្នុងការផ្តល់សេវាសាធារណៈគ្រប់ប្រភេទក្រោមសមត្ថកិច្ចក្រសួង ដើម្បីបម្រើ និងគាំទ្រដល់វិស័យឯកជនឱ្យមានប្រសិទ្ធភាព, (៥). ក្រសួងនឹងបន្តជំរុញការលើកកម្ពស់សមត្ថភាព ផលិតភាព អនុលោមភាព និង សហគ្រិនភាពរបស់វិស័យ SMEs ក្នុងស្រុក និងជំរុញឧស្សាហកម្មប្រតិគមន៍ ដើម្បីពង្រឹង និងពង្រីកមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍឧស្សាហកម្ម, (៦). ពង្រឹងការប្រកួតប្រជែងដោយ ផ្តោតសំខាន់លើការលើកកម្ពស់ការងារស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងការវាយតម្លៃ ភាពអនុលោម ដើម្បីចូលរួមគាំទ្រការអភិវឌ្ឍវិស័យ ឧ.វ.ប.ន និងវិស័យពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព និងរីកចម្រើន ជាពិសេសគាំទ្រដល់ការជំរុញការធ្វើពាណិជ្ជកម្មនិងសមាហរណកម្ម ទំនិញកម្ពុជានៅក្នុងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ, (៧). ពង្រឹងការអនុវត្តឯកសារ គោលនយោបាយជាតិ ស្តីអំពីរបៀបវារៈស្រាវជ្រាវជាតិ ២០២៥ ក្នុងន័យលើកកម្ពស់ ការស្រាវជ្រាវតាមវិស័យដែលជាអាទិភាពរបស់កម្ពុជា ជាអាទិ៍ៈ ស្បៀងអាហារ ទឹកស្អាត ថាមពល អប់រំ បច្ចេកវិទ្យា អេឡិចត្រូនិក ឌីជីថល សុខភាព និងអព្យាក្រឹតភាពកាបូន ដែល អាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុជាដើម និង (៨).បន្តរៀបចំផែនទីបង្ហាញផ្លូវ ស្តីពី ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០។

ជាពិសេស ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងបន្តខិតខំ រៀបចំព្រឹត្តិការណ៍ជាតិសំខាន់ៗ រួមមានៈ ការរៀបចំទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ លើកទី៣, ការរៀបចំទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម, និងរួមចំណែក អនុវត្តឱ្យសម្រេចនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈ ជានា «ប្រសិទ្ធភាពសមិទ្ធកម្ម» តាមរយៈការអនុវត្តអភិក្រម «ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់» និងអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ» (Dynamics of Stakeholder System)៕

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

MINISTRY OF INDUSTRY, SCIENCE, TECHNOLOGY & INNOVATION

៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

ទូរស័ព្ទ : (855) 23 211 141
អ៊ីម៉ែល : info@misti.gov.kh

សូមស្កេន
QR Code
ដើម្បីទាញយក
របាយការណ៍
សន្និបាតនេះ